សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការលែងលះនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ថូ ពិសិដ្ឋ**
កញ្ញា **ថា ស្រីពេជ្រ**

ណែនាំដោយ
លោកជំទាវ **ម៉ូយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត**
ជំនាន់ទី២៩ (និស្សិតអាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# ការលែងលះនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ថូ ពិសិដ្ឋ**

កញ្ញា **ថា ស្រីពេជ្រ**

ណែនាំដោយ

លោកជំទាវ **ម៉ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៩ (និស្សិតអាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **ថូ ពិសិដ្ឋ** និងនាងខ្ញុំ **ថា ស្រីពេជ្រ** ជានិស្សិតអាហារូបករណ៍ជំនាន់ ទី២៩ ឆ្នាំសិក្សា ២០២០-២០២៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមក្រាបប្រណិប័តន៍ ដើម្បីសម្តែងការគោរព ដឹងគុណ កត្តញ្ញូតាធម៌ កតវេទី យ៉ាងជ្រាលជ្រៅចំពោះ៖

១. អ្នកមានគុណរបស់ខ្ញុំបាទ និងនាងខ្ញុំទាំងទ្វេ គឺ

- **លោកឪពុកឈ្មោះ ថូ ឈុនលីម និងអ្នកម្តាយឈ្មោះ អេង សុភី**
- **លោកឪពុកឈ្មោះ ផេង ថា និងអ្នកម្តាយឈ្មោះ សេន ស៊ីនួន**

ដែលលោកពិតជាមានគុណយ៉ាងជ្រាលជ្រៅធំធេងដល់ខ្ញុំបាទ និងនាងខ្ញុំ លោកបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សាតាំងពីកូននៅក្នុងពោះរហូតដល់ធំពេញវ័យ អប់រំ ទូន្មានប្រៀនប្រដៅ ផ្តល់ក្តីស្រឡាញ់ និងព្យាយាមអស់ពីកម្លាំងកាយចិត្តតស៊ូ មិនខ្លាចហត់នឿយក្តៅ ឬរងាដើម្បីការពារកូន។ លោកពិតជាបានជួបនូវការលំបាកជាច្រើន ទម្រាំចិញ្ចឹមបីបាច់ថែរក្សាកូនមកដល់ពេលនេះ កូនសូមសន្យាថានឹងធ្វើជាពលរដ្ឋល្អនៅក្នុងសង្គម និងបន្តសិក្សារៀនសូត្រដើម្បីអនាគតដ៏ភ្លឺថ្លា និងមិនធ្វើឱ្យលោកអស់សង្ឃឹមឡើយ។

២. **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេច កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រានី ហ៊ុន សែន រួមជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានបង្កឱ្យមានកាលានុវត្តភាពដ៏គាប់ប្រសើរ និងជម្រុញឱ្យសង្គមមានការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសសម្រាប់វិស័យការអប់រំ ក៏ដូចជាការសិក្សាស្រាវជ្រាវផ្សេងៗទៀត។ តាមរយៈ ការដឹកនាំដ៏ឈ្លាសវៃ ខិតខំប្តូរផ្តាច់ បង្រួបបង្រួមជាតិ របស់សម្តេច បានធ្វើឱ្យប្រទេសកម្ពុជាទទួលបាន សុខសន្តិភាព ស្ថេរភាព ហើយធ្វើឱ្យសិស្សនិស្សិតទទួលបានការអប់រំខ្ពង់ខ្ពស់គ្រប់គ្នា និងជាប្រយោជន៍សម្រាប់ការអភិវឌ្ឍប្រទេសជាតិឱ្យមានភាពរីកចម្រើនជានិរន្តរ៍។

៣. **ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យសាកលវិទ្យាធិការ លុយ ចណ្ណា** និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានលះបង់កម្លាំងកាយកម្លាំងចិត្ត ក្នុងការដឹកនាំគ្រប់គ្រង បង្ហាត់បង្រៀនដល់ខ្ញុំបាទ និងនាងខ្ញុំនូវមេរៀនទាក់ទងនឹងជំនាញនីតិសាស្ត្រ និងស្ថានភាពជាក់ស្តែងនៃសង្គម។

៤. **លោកជំទាវ ម៉ឹយ ធីតា** ដែលជាគ្រូណែនាំសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ ខ្ញុំបាទ និងនាងខ្ញុំដែលលោកបានប្រឹងប្រែលះបង់មិនខ្លាចនឿយហត់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ក្នុងការ

ណែនាំលើប្រធានបទសារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទ និងនាងខ្ញុំដោយលោកស្រីបានជួយអប់រំ បង្ហាញទិសដៅ ជួយជ្រោមជ្រែង ផ្ដល់គំនិតយោបល់ ព្រមទាំងលះបង់នៅពេលវេលាដ៏មានតម្លៃជួយកែសម្រួល រចនាបទ និងណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះប្រកបដោយជោគជ័យដ៏ត្រចះត្រចង់ថ្លៃថ្លា។ ប្រសិនបើគ្មាន លោកស្រីសាស្ត្រាចារ្យទេ ការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះក៏មិនអាចចេញជារូបរាងឡើយ។

៥. គណៈគ្រប់គ្រង ព្រមទាំងបុគ្គលិកនៃ បណ្ណាល័យនីតិសាស្ត្រ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានរៀបចំ និងគ្រប់គ្រងសៀវភៅ ព្រមទាំងបង្កភាពងាយស្រួលដល់ការសរសេរសារណាបញ្ចប់ការសិក្សារបស់សិស្សនិស្សិតនៃសកលវិទ្យាល័យទាំងមូល ព្រមទាំងខ្ញុំបាទ និងនាងខ្ញុំ។

ជាចុងក្រោយ ខ្ញុំបាទ និងនាងខ្ញុំសូមប្រសិទ្ធពរជ័យដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និង លោក លោកស្រី សាស្ត្រាចារ្យ ទាំងអស់នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមខ្ញុំបាទ និងនាងខ្ញុំជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្រ្តជំនាន់ទី២៩ (និស្សិតអាហារូបករណ៍)នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានសិក្សារយៈពេលចំនួនបួនឆ្នាំកន្លងមកនេះក្រោមការខិតខំស្វះស្វែង យកចិត្តទុកដាក់សិក្សាតាមរយៈ ការអាន ការស្តាប់ និងមធ្យោបាយសិក្សាផ្សេងៗ ព្រមទាំងមានការយកចិត្តទុកដាក់បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានធ្វើឱ្យខ្ញុំបាទ និងនាងខ្ញុំទទួលបាននូវចំណេះដឹងយ៉ាងទូលំទូលាយលើមុខវិជ្ជាសំខាន់ៗជាច្រើន ជាពិសេសប្រព័ន្ធច្បាប់ដែលអនុវត្តក្នុងប្រទេសកម្ពុជា។ ក្រោយពីបានសិក្សាអស់រយៈពេលបួនឆ្នាំទៅលើមុខវិជ្ជាជាច្រើនកន្លងមក ខ្ញុំបាទ និងនាងខ្ញុំបានចាប់អារម្មណ៍ជាខ្លាំងចំពោះមុខវិជ្ជានីតិរដ្ឋប្បវេណី និងបានសម្រេចចិត្តស្រាវជ្រាវចងក្រងសារណាអំពីប្រធានបទស្តីពី « **ការលែងលះនៅកម្ពុជា** » ដែលហាក់មានភាពស្មុគស្មាញ មាននីតិវិធីច្រើនដំណាក់កាល និងទាមទារឱ្យអ្នកសិក្សាទាំងអស់ធ្វើការយកចិត្តទុកដាក់ ខិតខំប្រឹងប្រែង និងស្រាវជ្រាវឱ្យបានច្រើន។ ដូចដែលបានជម្រាបជូនខាងលើខ្ញុំបាទ និងនាងខ្ញុំបានបង្កើតស្នាដៃនៃការសរសេរសារណានេះឡើង ក្នុងគោលបំណងធ្វើការបែងចែកជាចំណុចៗជាច្រើន និងធ្វើការបកស្រាយលម្អិតទៅលើចំណុចទាំងអស់នោះ ដោយបានបរិយាយយ៉ាងក្បោះក្បាយ និងស៊ីជម្រៅទៅលើប្រធានបទការលែងលះនៅកម្ពុជាមួយនេះ ដើម្បីបង្កឱ្យមានភាពងាយស្រួលក្នុងការសិក្សាឈ្វេងយល់។ ម្យ៉ាងវិញទៀត ការខិតខំស្រាវជ្រាវរបស់ខ្ញុំបាទ និងនាងខ្ញុំនេះដើម្បីទុកជាចំណងដៃអនុស្សាវរីយ៍សម្រាប់មិត្តនិស្សិតអ្នកអាន ក៏ដូចជាជួយសម្រួលដល់ការសិក្សាស្រាវជ្រាវឯកសារផ្សេងៗរបស់សិស្សនិស្សិតក្នុងសហសវត្សថ្មីនេះ។

ខ្ញុំបាទ និងនាងខ្ញុំសង្ឃឹមប្រកបដោយភាពជឿជាក់យ៉ាងមុតមាំថា ការខិតខំរបស់ខ្ញុំបាទ និងនាងខ្ញុំនឹងជួយសម្រួលដល់មិត្តអ្នកអាន ក៏ដូចជាសិស្សនិស្សិតក្នុងសហសវត្សថ្មីនេះបានច្រើននៅក្នុងការសិក្សារៀនសូត្រស្រាវជ្រាវចំណេះដឹងបន្ថែម។ នៅក្នុងនោះដែរនាងខ្ញុំ និងខ្ញុំបាទក៏ជឿជាក់ផងដែរថា បើទោះបីជាខ្ញុំបាទ និងនាងខ្ញុំបានធ្វើការខិតខំស្រាវជ្រាវ និងយកមកចងក្រងដោយប្រុងប្រយ័ត្នខ្ពស់យ៉ាងណាក៏ដោយក៏នៅតែអាចមានជាកំហុសឆ្គងដោយអចេតនា ត្រង់ប្រការណាមួយទៅលើអក្ខរាវិរុទ្ធ ឃ្លាប្រយោគ វេយ្យាករណ៍ និងកំហុសឆ្គងផ្សេងៗទៀត ដូច្នេះខ្ញុំបាទ និងនាងខ្ញុំសូមអធ្យាស្រ័យ សុំអភ័យទោសទុកជាមុនចំពោះកំហុសឆ្គងដោយអចេតនា។

ជាចុងបញ្ចប់ខ្ញុំបាទ និងនាងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវ **ម៉ឺយ ធីតា** ដែលបានណែនាំ និងផ្តល់ដំបូន្មានឱ្យខ្ញុំបាទ និងនាងខ្ញុំធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ ម្យ៉ាងទៀតខ្ញុំបាទនិងនាងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ លោកគ្រូ អ្នកគ្រូ បណ្ឌិត សាស្រ្តាចារ្យ សិស្សនិស្សិត ក៏ដូចជាមិត្តអ្នកអានឱ្យជួបតែសំណាងល្អ សុខភាពល្អរឹងមាំ សុខសុវត្ថិភាព និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

# មាតិកា


ទំព័រ

**ពាក្យគន្លឹះ** ........................................ vi

**សេចក្ដីផ្ដើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការលែងលះ**

**១.១. និយមន័យនៃអាពាហ៍ពិពាហ៍** ........................................ ៥

**១.២. និយមន័យនៃការលែងលះ** ........................................ ៦

**១.៣. ប្រភេទនៃការលែងលះ** ........................................ ៧

១.៣.១. ការលែងលះដោយមានការព្រមព្រៀង ........................................ ៧

១.៣.២. ការលែងលះដោយគ្មានការព្រមព្រៀងគ្នា ........................................ ៩

**១.៤. មូលហេតុនៃការលែងលះ** ........................................ ៩

១.៤.១. បានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ ........................................ ១០

១.៤.២. ករណីដែលបានបោះបង់សហព័ទ្ធចោលដោយគ្មានហេតុផលត្រឹមត្រូវ ........................................ ១០

១.៤.៣. ករណីដែលមិនដឹងច្បាស់ថាសហព័ទ្ធរបស់ខ្លួនស្លាប់ ឬ រស់អស់រយៈពេលជាង១(មួយ)ឆ្នាំ.... ១១

១.៤.៤. ករណីសហព័ទ្ធបានរស់នៅបែកគ្នា ........................................ ១១

១.៤.៥. មូលហេតុផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ........................................ ១២

១.៤.៥.១. ភាពមិនស្មោះត្រង់របស់ភាគីសហព័ទ្ធ ........................................ ១៣

១.៤.៥.២. រៀបការវ័យក្មេងពេករបស់សហព័ទ្ធទាំងសងខាង ........................................ ១៣

១.៤.៥.៣. កត្តាគ្រួសារ (ក្រីក្រពេក, ឪពុកម្ដាយ..) ........................................ ១៤

១.៤.៥.៤. ក្បៀយធន ........................................ ១៥

១.៤.៥.៥. ការប្រចណ្ឌសហព័ទ្ធ ........................................ ១៥

១.៤.៥.៦. ភាពសោះកក្រោះនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ ........................................ ១៦

១.៤.៥.៧. ការប្រើប្រាស់គ្រឿងញៀន ......... ១៧
១.៤.៥.៨. ញៀនស្រា និងល្បែង ......... ១៧
១.៤.៥.៩. បញ្ហាផ្លូវភេទ(មិនសំដៅលើអពលានុភាពនៃលិង្គ ប៉ុន្តែសំដៅលើចំណងផ្លូវភេទរបស់ភាគី និងការសហការគ្នា) ......... ១៨
**១.៥. មូលហេតុដែលមិនអាចលែងលះបាន** ......... ១៨
១.៥.១. ផ្តល់ផលប៉ះពាល់ដល់ការទ្រទ្រង់ជីវភាព ឬការឈឺចាប់របស់សហព័ទ្ធឬកូន ......... ១៨
១.៥.២. ការលែងលះដោយមានគំនិតទុច្ចរិត ......... ១៩

## ជំពូកទី២

## ការលែងលះដោយការព្រមព្រៀង

**២.១. នីតិវិធីនៃការលែងលះដោយការព្រមព្រៀង** ......... ២១
**២.១.១. ពាក្យសុំលែងលះ** ......... ២១
២.១.១.១. ពាក្យសុំលែងលះជាលាយលក្ខណ៍អក្សរ ......... ២២
២.១.១.២. ពាក្យសុំលែងលះដោយផ្ទាល់មាត់ ......... ២២
**២.១.២. សមត្ថកិច្ចដោះស្រាយ** ......... ២២
២.១.២.១. ឃុំ-សង្កាត់ ......... ២២
២.១.២.២. សាលាដំបូងរាជធានី ខេត្ត ......... ២៣
**២.១.៣. ដំណើរការនៃដំណោះស្រាយការលែងលះដោយការព្រមព្រៀង** ......... ២៣
២.១.៣.១. ការកោះហៅគូភាគី ......... ២៣
២.១.៣.២. ការផ្សះផ្សា ......... ២៤
២.១.៣.៣. នីតិវិធីនៃការសាកសួរ ......... ២៤
**២.២. ការសម្រេចសេចក្តី** ......... ២៤
២.២.១. អំពីដីកាសម្រេចតាមពាក្យសុំ ......... ២៤
២.២.២. ការជូនដំណឹងអំពីដីកាសម្រេច ......... ២៥
២.២.៣. ការចូលជាស្ថាពរនៃដីកាសម្រេច ......... ២៥

# ជំពូកទី ៣

# ការលែងលះដោយគ្មានការព្រមព្រៀង

**៣.១. នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង** ........ ២៧

៣.១.១. ការផ្តើមនៃបណ្តឹងលែងលះ ........ ២៧

៣.១.២. ការសរសេរពាក្យបណ្តឹង ........ ២៧

៣.១.៣ ទីកន្លែងដាក់ពាក្យបណ្តឹង និងការបង់ពន្ធ ........ ២៨

៣.១.៤. ការទទួលពាក្យបណ្តឹង ........ ៣០

៣.១.៥. ការពិនិត្យពាក្យបណ្តឹង និងការបញ្ជូនពាក្យបណ្តឹង ........ ៣១

៣.១.៦. ការផ្សះផ្សា ........ ៣២

**៣.២. សមត្ថកិច្ចដោះស្រាយ** ........ ៣២

៣.២.១. សមត្ថកិច្ចរបស់ឃុំ ឬសង្កាត់ ........ ៣៣

៣.២.២. សមត្ថកិច្ចរបស់តុលាការ ........ ៣៣

**៣.៣. វិធានការចាត់ចែងរក្សាការពារ** ........ ៣៤

៣.៣.១. វិធានការឱ្យសហព័ទ្ធត្រូវតែរស់នៅបែកគ្នា ........ ៣៥

៣.៣.២. វិធានការឱ្យមានការថែរក្សាកូនបណ្តោះអាសន្ន ........ ៣៥

៣.៣.៣. វិធានការស្តីពីការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន ........ ៣៦

៣.៣.៤. វិធានការផ្តល់ការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់សហព័ទ្ធ និងកូនជាបណ្តោះអាសន្ន ........ ៣៦

៣.៣.៥. ការរឹបអូសជាបណ្តោះអាសន្ន ........ ៣៧

**៣.៤. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ៣៧

៣.៤.១. ការរៀបចំការអះអាងរបស់សហព័ទ្ធទាំងពីរ ........ ៣៨

៣.៤.២. ការរៀបចំចំណុចវិវាទ ........ ៣៩

៣.៤.៣. ការរៀបចំពិនិត្យភស្តុតាង ........ ៣៩

៣.៤.៤. ការប្តឹងតបរបស់ចុងចម្លើយ ........ ៣៩

៣.៤.៥. កាលកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ៤០

៣.៤.៦. ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ................................ ៤២
**៣.៥. នីតិវិធីទាញហេតុផលផ្ទាល់មាត់** ................................ ៤៣
៣.៥.១. ការថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ................................ ៤៤
៣.៥.២. ការពិនិត្យភស្តុតាងដោយសមូហវិធី ................................ ៤៥
**៣.៦. ការសម្រេចសេចក្តី** ................................ ៤៦
៣.៦.១. ការចេញសាលក្រមលើបណ្តឹងលែងលះ ................................ ៤៦
៣.៦.២. ការសម្រេចមិនឱ្យមានការលែងលះ ................................ ៤៧
៣.៦.៣. ការចូលជាស្ថាពរនៃសាលក្រម ................................ ៤៧

## ជំពូកទី៤

## អានុភាពនៃការលែងលះ

**៤.១. ការកាត់ផ្តាច់ទំនាក់ទំនងញាតិ** ................................ ៤៩
**៤.១.១. ទំនាក់ទំនងគតិយុត្តចំពោះសហព័ទ្ធ** ................................ ៤៩
៤.១.១.១. សិទ្ធិ និងកាតព្វកិច្ចក្រោយការលែងលះរបស់សហព័ទ្ធ ................................ ៥០
៤.១.១.២. នាមត្រកូលរបស់សហព័ទ្ធ ................................ ៥០
៤.១.១.៣. មានសិទ្ធិទាមទារអនុវត្តការផ្តល់អាហាកាតព្វកិច្ច ................................ ៥១
៤.១.១.៤. សិទ្ធិទទួលបានអត្តាធីនភាព ................................ ៥១
**៤.១.២. ការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ** ................................ ៥១
**៤.២. ការបែងចែកទ្រព្យសម្បត្តិ** ................................ ៥២
៤.២.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ................................ ៥២
៤.២.២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ................................ ៥២
៤.២.២.១. ទ្រព្យសម្បត្តិដោយឡែក ................................ ៥៣
៤.២.២.២. ទ្រព្យសម្បត្តិរួម ................................ ៥៣
**៤.៣. អានុភាពលែងលះចំពោះកូន** ................................ ៥៤
៤.៣.១. ការកំណត់អំណាចមេបា ................................ ៥៤

៤.៣.២. អាហារកាតព្វកិច្ចចំពោះកូន ........................................................ ៥៦
**សេចក្តីសន្និដ្ឋាន** ........................................................ ៥៧
**អនុសាសន៍** ........................................................ ៥៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ពាក្យគន្លឹះ

- **ការលែងលះគ្នា** គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលបានរៀបការពេញច្បាប់ក្នុងពេលរស់នៅទាំងពីរនាក់។ (ប្រភព៖ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា ៣)
- **អាពាហ៍ពិពាហ៍** គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និង ស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននិងរួមសមគ្គសង្វាសជាមួយតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ (ប្រភព៖ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៩៨៩, មាត្រា ៣ វាក្យខណ្ឌទី ១)
- **សហព័ទ្ធ** សំដៅលើប្តី ឬ ប្រពន្ធ ឬទាំងប្តី ទាំងប្រពន្ធដែឡទទួលបានឋានៈជាសហព័ទ្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍។ (ប្រភព៖ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខរៀង ១៥០)
- **សមគ្គសង្វាស** សំដៅលើការរស់នៅរបស់ប្តីប្រពន្ធព្រមចិត្តគំនិតគ្នា ការនៅរួមសុខទុក្ខ។ (ប្រភព៖ វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត)
- **អត្តាធីនភាព** គឺជាស្ថានភាពមួយ ដែលផ្តល់ឱ្យអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់នីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចអនីតិជនដែរ។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង ប៉ូវ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី១១៥, បោះពុម្ពឆ្នាំ២០២១)
- **សេវនកិច្ច** គឺជាការរួមរស់ជាមួយគ្នាដូចប្តីប្រពន្ធ ដោយមានការរួមភេទ រស់នៅជាមួយគ្នា ឬការរួមសេវនកិច្ច។ (ប្រភព៖ ការបកស្រាយចម្ងល់ទាក់ទងនឹងច្បាប់ឯកពន្ធភាព(ភាគពីរ)ក្នុងវិទ្យុអាស៊ីសេរី របស់លោកមេធាវី គង់ រ៉ាឌី)
- **ញាតិពន្ធ** សំដៅលើចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិត របស់សហព័ទ្ធម្ខាងទៀត។ (ប្រភព៖ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខរៀង ៤១)
- **បុព្វញាតិ** សំដៅលើជនដែលស្ថិតក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន ឬបុព្វជាតិ។ (ប្រភព៖ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខរៀង ៩៣)

- **សាលក្រម** សំដៅលើសេចក្ដីសម្រេចរបស់តុលាការជាន់ទាបមានលក្ខណៈគ្រប់គ្រាន់ ទៅតាមទម្រង់ដែលច្បាប់បានកំណត់ដោយផ្អែកតាមការទាញហេតុផលផ្ទាល់។ (ប្រភព៖ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា ១៧៩, កថាខណ្ឌទី ១)
- **សាលដីកា** សំដៅលើសេចក្ដីសម្រេចរបស់សាលាជម្រះក្ដីជាន់ខ្ពស់ (សាលាឧទ្ធរណ៍ តុលាការកំពូល) ដែលមានលក្ខណៈគ្រប់គ្រាន់តាមទម្រង់ដែលច្បាប់កំណត់ដោយផ្អែកតាមការទាញហេតុផលដោយផ្ទាល់មាត់។ (ប្រភព៖ វចនានុក្រមតម្រាច្បាប់ )
- **ដីកាសម្រេច** គឺជាការសម្រេចសេចក្ដីដែលតុលាការ ឬចៅក្រមអាចធ្វើការដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាលើមាត់បាន ហើយមិនមែនជាសាលក្រម។ (ប្រភព៖ ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១៧៩, កថាខណ្ឌទី២)
- **ឆន្ទានុសិទ្ធិ** សំដៅដល់អំណាចដែលច្បាប់ប្រគល់ដល់ចៅក្រមឱ្យរើសយកមធ្យោបាយណាមួយ តាមការវាយតម្លៃរបស់ខ្លួនមកដោះស្រាយបញ្ហាណាមួយ។ អំណាចរបស់ចៅក្រមក្នុងការធ្វើសកម្មភាពក្នុងនីតិវិធីនៃបណ្ដឹង ដោយមិនបាច់មានពាក្យសុំរបស់ភាគី។ (ប្រភព៖ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខរៀង ៣៦)
- **ការកោះហៅ** គឺជាការបង្គាប់របស់តុលាការដែលតម្រូវឲ្យបុគ្គលណាមួយត្រូវតែមកបង្ហាញខ្លួននៅតុលាការតាមកាលបរិច្ឆេទដែលបានកំណត់។ ការកោះហៅ អាចធ្វើតាមវិធីបញ្ជូនដីកាកោះ ឬដោយជូនដំណឹងអំពីកាលបរិច្ឆេទ។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៨៥, បោះពុម្ពឆ្នាំ២០២១)
- **ភាគីដើមចោទ** សំដៅលើភាគីដែលជាអ្នកដាក់ពាក្យបណ្ដឹង។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៧០, បោះពុម្ពឆ្នាំ២០២១)
- **ភាគីចុងចម្លើយ** សំដៅលើភាគីដែលជាអ្នកទទួលរងនូវការប្ដឹង។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៧០, បោះពុម្ពឆ្នាំ២០២១)
- **សាលក្រមកំបាំងមុខ** គឺជាសាលក្រម ដែលតុលាការសម្រេចដោយគ្មានវត្តមានរបស់ដើមចោទ ឬចុងចម្លើយ ឬអ្នកតំណាងស្របច្បាប់របស់ដើមចោទ ឬចុងចម្លើយ។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៩៨, បោះពុម្ពឆ្នាំ២០២១)
- **ការផ្សះផ្សា** គឺជាការសម្រុះសម្រួលគូភាគីឱ្យសះជានឹងគ្នា។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៧០, បោះពុម្ពឆ្នាំ២០២១)

- **បដិទាន** គឺជាការស្តារឡើងវិញនូវស្ថានភាពដើម ឬការប្រគល់ត្រឡប់វិញ។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៦៥, បោះពុម្ពឆ្នាំ២០២១)
- **អ្នកតំណាងដោយអាណត្តិ** គឺជាអ្នកដែលទទួលសិទ្ធិតំណាងដោយអាណត្តិ។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី១០៥, បោះពុម្ពឆ្នាំ ២០២១)
- **អ្នកតំណាងដែលច្បាប់បានកំណត់** គឺជាបុគ្គលដែលទទួលសិទ្ធិតំណាងកំណត់ដោយច្បាប់ ដូចជាអ្នកមានអំណាចមេបា ឬអ្នកមានអំណាចមេបាជាដើម។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី១០៥, បោះពុម្ពឆ្នាំ២០២១)
- **សេចក្តីថ្លែងការណ៍** គឺជាសេចក្តីអះអាងដោយវាចាក្តី ដោយលាយលក្ខណ៍អក្សរក្តី ដែលរៀបរាប់អំពីអង្គហេតុ អំពីគោលបំណងណាមួយ។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៨៦, បោះពុម្ពឆ្នាំ២០២១)
- **ឯកសារត្រៀម** គឺជាឯកសារដែលសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន ដែលភាគីនឹងយកទៅអះអាងចំពោះមុខតុលាការ។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៧៩, បោះពុម្ពឆ្នាំ២០២១)
- **សមត្ថកិច្ចផ្តាច់មុខ** គឺជាអំណាចដែលផ្តល់ឱ្យតុលាការណាមួយជាកំណត់ក្នុងការទទួលបណ្តឹង វិនិច្ឆ័យរឿងក្តី ចេញសាលក្រម ឬសាលដីកា។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៨១, បោះពុម្ពឆ្នាំ២០២១)
- **សមូហវិធី** គឺជាការធ្វើឡើងនៅពេលតែមួយ និងដោយប្រមូលផ្តុំ។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៨៩, បោះពុម្ពឆ្នាំ២០២១)
- **លំនៅឋាន** គឺជាទីកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ។
(ប្រភព៖ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៤)
- **ទីសំណាក់** សំដៅលើកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ។

(ប្រភព៖ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៥)

- **ទំនាក់ទំនងគតិយុត្ត** គឺជាចំណងកើតឡើងរវាងបុគ្គលពីរនាក់ ឬច្រើននាក់តាមរយៈកិច្ចគតិយុត្ត ឬបញ្ញត្តិច្បាប់។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៦០, បោះពុម្ពឆ្នាំ២០២១)

- **អំណាចមេបា** គឺចាសិទ្ធិ និងករណីយកិច្ចដែលត្រូវចិញ្ចឹមបីបាច់រូបរាងកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៥៩, បោះពុម្ពឆ្នាំ២០២១)
- **ប្រទានកម្ម** សំដៅលើកិច្ចសន្យាមួយដែលត្រូវមានអានុភាពដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៥៥, បោះពុម្ពឆ្នាំ២០២១)
- **ទ្រព្យសម្បត្តិដែលជាតម្លៃតប** គឺជាទ្រព្យសម្បត្តិដែលមានមុនរៀបអាពាហ៍ពិពាហ៍ ឬទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៥៥, បោះពុម្ពឆ្នាំ ២០២១)
- **អាហារកាតព្វកិច្ច** គឺជាកិច្ចដែលត្រូវបំពេញតាមទម្រង់ច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅរបស់បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិនឹងគ្នា។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី៤៨, បោះពុម្ពឆ្នាំ២០២១)
- **មន្ត្រីអត្រានុកូលដ្ឋាន** គឺជាអ្នកដែលកាន់បញ្ជី កើត ស្លាប់ និងអាពាហ៍ពិពាហ៍នៃប្រជាជនក្នុងប្រទេស។ (ប្រភព៖ សាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, ទំព័រទី២៥, បោះពុម្ពឆ្នាំ២០២១)

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

សង្គមជាតិមួយអាចកើតឡើងបានដោយសារតែមានស្រទាប់នៃកោសិការបស់សង្គម ហើយកោសិកានោះទៀតសោតភាគីគឺកើតចេញពីគ្រួសារ ព្រោះថាមនុស្សបង្កើតគ្រួសារដើម្បីបណ្តុះនូវកោសិកាថ្មីដល់សង្គមដើម្បីចូលរួមក្នុងការអភិវឌ្ឍសង្គម។ កាលពីសម័យមុននៅក្នុងប្រទេសកម្ពុជាបានយកការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ហើយមានបងប្អូនដឹងឮថាច្បាប់នៃអាពាហ៍ពិពាហ៍ ប៉ុន្តែមកដល់ពេលបច្ចុប្បន្ននេ ដោយសារឆ្លងកាត់ជាច្រើនសម័យកាល និងរងឥទ្ធិពលពីប្រព័ន្ធច្បាប់ផ្សេងៗដែលដាក់អាណានិគមមកលើប្រទេសកម្ពុជា ជាហេតុធ្វើឱ្យប្រទេសកម្ពុជា ក៏មានការអនុវត្តន៍នូវច្បាប់ផ្សេងៗមួយទៀតដែលក្រៅពីច្បាប់តាមបែបប្រពៃណីដែលប្រជាជនតែងតែយកវាមកអនុវត្តកាលពីជំនាន់មុន នោះគឺច្បាប់ស៊ីវិលឡ។ ច្បាប់ស៊ីវិលឡក៏បានចែងផងដែរ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩។ ហេតុដូចនេះការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីគ្រាន់តែជាការចូលរួមថែរក្សាអភិរក្សនូវអរិយធម៌ និងវប្បធម៌ដែលដូនតាបានបន្សល់ទុកតាំងពីយូរលង់ណាស់មកហើយកុំឱ្យបាត់បង់តែងប៉ុណ្ណោះ។ ជាមួយគ្នាផងដែរ ដើម្បីឱ្យការរៀបអាពាហ៍ពិពាហ៍ស្របទៅនឹងច្បាប់ លុះត្រាតែគូស្វាមីដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវអនុវត្តទៅតាមនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍តាមច្បាប់ មានន័យថាជាការបញ្ជាឆន្ទៈក្នុងការបង្កើតចំណងគតិយុត្ត ចងភ្ជាប់រូបវន្តបុគ្គលឱ្យទៅជាសហព័ទ្ធស្របច្បាប់ តាមរយៈកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅមុខមន្ត្រីអត្រានុកូលដ្ឋាន។ ជាមួយគ្នានេះ បុរស និងស្ត្រីដែលរៀបអាពាហ៍ពិពាហ៍នឹងគ្នាត្រូវអនុវត្តទៅតាមនីតិវិធីដូចមានកំណត់ក្នុងច្បាប់ដូចមានចែងពីមាត្រា ៩៤៨ - ៩៥៤ ជាធរមាន មានដូចជា ត្រូវបំពេញលក្ខខណ្ឌសារធាតុ ដូចជាបុរស និងនារីដល់នីតិភាព មានឆន្ទៈពិតប្រាកដក្នុងការបង្កើតកិច្ចសន្យាអាពាហ៍ពិពាហ៍នឹងត្រូវធ្វើតាមនីតិវិធីច្បាប់ដូចជា ត្រូវទៅដាក់ពាក្យសុំទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់ខាងស្ត្រី និងមានបិទផ្សាយជាសាធារណៈ ១០ (ដប់) ថ្ងៃ មុនពេលរៀបអាពាហ៍ពិពាហ៍។ ចុងក្រោយមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅដ្ឋានខាងស្រីដែលបានចុះបញ្ជីរួច ត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ដល់គូស្វាមីភរិយានោះ ដោយហេតុនេះហើយ ទើបការរំលាយអាពាហ៍ពិពាហ៍ គឺមិនអាចធ្វើបានតាមទំនើងចិត្តបានឡើយ ហើយត្រូវដើរទៅតាមនីតិវិធីរបស់ច្បាប់ដោយមានការអនុវត្តពីតុលាការ ព្រោះបន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍ បន្ទាប់ពីប្តី និងប្រពន្ធបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាហើយ នោះចំណងគតិយុត្តជាច្រើននឹងកើតឡើងរវាងអ្នកទាំងពីរ ជាពិសេស ទំនាក់ទំនងនៃមនោសញ្ចេតនា ឋានៈបុគ្គល ញាតិ និងទំនាក់ទំនងទ្រព្យសម្បត្តិ។

ជាការពិតណាស់ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាហើយ គ្រប់គូស្វាមីភរិយាទាំងអស់ សុទ្ធតែប្រាថ្នាចង់ឱ្យជីវិតគូរបស់ខ្លួនរស់នៅប្រកបដោយ សុភមង្គល ភាពរីករាយ និងសុខសាន្តត្រាណជានិរន្តរ៍។ ប៉ុន្តែ

បើទោះបីជាគ្រប់គូទាំងអស់សុទ្ធតែមានសេចក្តីប្រាថ្នាដូចគ្នាក៏ដោយ ក៏នៅមានគូស្វាមីភរិយាមួយចំនួន មិនអាចសម្រេចបានតាមអ្វីដែលខ្លួនប្រាថ្នានោះដែរ ហើយក៏មានគូស្វាមីខ្លះទៀតត្រូវបានផ្តាច់ចំណងអាពាហ៍ពិពាហ៍នោះទៅវិញក៏មាន។ ហើយមូលហេតុនៃការផ្តាច់ចំណងអាពាហ៍ពិពាហ៍នោះវិញ ដោយសារតែភាពផ្លាស់ប្តូរនៅក្នុងជីវិតគូរបស់ពួកគេ ដែលពេលខ្លះ សហព័ទ្ធណាម្ខាងបានផិតក្បត់ ឬអាចជាការបាត់ដំណឹងរបស់សហព័ទ្ធណាម្នាក់ពីផ្ទះ ឬការដែលសហព័ទ្ធម្ខាងបានបោះបង់សហព័ទ្ធម្ខាងទៀត ឬរស់នៅបែកគ្នាអស់រយៈពេលយូរ ឬពេលខ្លះអាចទាំងពីរ ឬសហព័ទ្ធណាម្ខាងបានអស់មនោសញ្ចេតនាជាប្តីនិងប្រពន្ធ និងមិនអាចរស់នៅជាមួយគ្នាតទៅទៀតបាន។ ចុងបញ្ចប់នៃចំណងអាពាហ៍ពិពាហ៍របស់ពួកគេ មានជម្រើសនៃការបញ្ចប់បញ្ហាទាំងឡាយរបស់គូស្វាមីទាំងនោះ គឺការជ្រើសរើសយកការលែងលះជាផ្លូវនៃការផ្តាច់ចំណងអាពាហ៍ពិពាហ៍មួយនោះ។

បច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជារបស់យើងក៏ឃើញមាននូវបញ្ហានៃការលែងលះនោះកើតមានច្រើនផងដែរ ហើយចំពោះដំណោះស្រាយនៃបញ្ហានោះក៏មាននូវការចូលរួមពីសំណាក់អ្នកមានវិជ្ជាជីវៈផ្នែកច្បាប់ ដែលបានបំពេញការងារក្នុងវិស័យច្បាប់ មានជំនាញ មានចំណេះដឹង ព្រមទាំងមានបទពិសោធន៍ជាច្រើនអំពីបញ្ហាទាំងនោះចូលរួម។ បើទោះបីជាយ៉ាងនេះក៏ពិតមែន ក៏ប៉ុន្តែយើងនៅតែមើលឃើញថានូវមានប្រជាជនមួយចំនួនធំនៅមិនទាន់យល់ពីការលែងលះស្របច្បាប់នេះនៅឡើយទេ។ ជាពិសេសទៀតនោះគឺទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ទំនាក់ទំនងញាតិ ការប្រគល់អំណាចមេបា ការផ្តល់អាហារកាតព្វកិច្ចដល់សហព័ទ្ធ និងកូន និងការរៀបចំបញ្ជីអំពីការលែងលះ ការប្តឹងឡើងតុលាការផងដែរ។ ដោយសារតែមាននូវចម្ងល់ និងមន្ទិលសង្ស័យទាំងនោះហើយ ទើបមានការលើកឡើងនូវសំណួរជាច្រើនទាក់ទងនិងការលែងលះនៅកម្ពុជា ដែលរួមមាន៖

- តើអ្វីទៅជាការលែងលះ?
- តើមានមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យមានការលែងលះ?
- តើមានមូលហេតុណាខ្លះដែលមិនអាចលែងលះគ្នាបាន?
- តើការលែងលះដោយមានការព្រមព្រៀង និងដោយឯកតោភាគីមានបែបបទយ៉ាងដូចម្តេច?
- តើនីតិវិធីនៃការលែងលះដោយការព្រមព្រៀង និងដោយឯកតោភាគីត្រូវដោះស្រាយដូចម្តេច?
- តើនីតិវិធីទាក់ទង និងការបែងចែកទ្រព្យសម្បត្តិ ការប្រគល់អំណាចមេបា និងការផ្តល់អាហារកាតព្វកិច្ចផ្សេងៗទៀតមានអានុភាពដូចម្តេចនៅក្នុងនីតិវិធីនៃការលែងលះ?

ដោយសារតែនាងខ្ញុំ និងខ្ញុំបាទបានសង្កេតឃើញថា ការលែងលះនៅប្រទេសកម្ពុជាគឺមានលក្ខណៈស្មុគស្មាញ និងធ្វើឱ្យប្រជាពលរដ្ឋក៏ដូចជាមិត្តអ្នកសិក្សាស្រាវជ្រាវមានចម្ងល់ជាច្រើនទៅលើប្រធានបទមួយនេះ ទើបនាងខ្ញុំ និងខ្ញុំបាទបានធ្វើការចងក្រងជាសៀវភៅមួយនេះ ដើម្បីទុកជាស្នាដៃ និងចែករំលែកនូវចំណេះដឹង

ដែលនាងខ្ញុំ និងខ្ញុំបាទទាំងពីរទទួលបានពីលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ រួមទាំងសិស្សច្បង ព្រមទាំងការខិតខំស្រាវជ្រាវបន្ថែមទៅលើប្រធានបទនេះ យកមកចងក្រងទុកជាឯកសារឱ្យកាន់តែមានលក្ខណៈងាយស្រួលយល់ និងស៊ីជម្រៅបន្ថែមទៀតទៅលើបញ្ហានៃការលែងលះ និងចំណុចផ្សេងៗដែលពាក់ព័ន្ធនៅក្នុងនីតិវិធីច្បាប់។

គោលបំណងទាំងនោះរួមមានដូចខាងក្រោម៖

- ដើម្បីសិក្សាឱ្យបានកាន់តែស៊ីជម្រៅទៅលើបទដ្ឋានគតិយុត្តិទាំងឡាយណាដែលជាប់ពាក់ពន្ធ័ទៅនឹងការលែងលះ
- ដើម្បីស្វែងយល់ពីទិដ្ឋភាពទូទៅនៃទំនាក់ទំនងគតិយុត្តរបស់សហព័ទ្ធ
- ដើម្បីសិក្សាឱ្យបានច្បាស់លាស់ពីប្រភេទនៃការលែងលះនៅប្រទេសកម្ពុជា
- ដើម្បីស្វែងយល់ពីមូលហេតុនៃការលែងលះ
- ដើម្បីសិក្សាឱ្យបានស៊ីជម្រៅទៅលើនីតិវិធីនៃការលែងលះដោយការព្រមព្រៀង
- ដើម្បីសិក្សាឱ្យបានច្បាស់លាស់ទៅលើនីតិវិធីនៃការលែងលះដោយឯកតោភាគី
- ដើម្បីស្វែងយល់ពីអានុភាពនៃការលែងលះ
- ដើម្បីសិក្សាឱ្យបានកាន់តែស៊ីជម្រៅទៅលើការអនុវត្តជាក់ស្តែង ដែលឆ្លើយតបទៅនឹងទិដ្ឋភាពច្បាប់នានាដែលត្រូវបានយកមកអនុវត្តន៍
- ដើម្បីស្វែងយល់ពីនីតិវិធីនៃការលែងលះទៅតាមប្រភេទនៃការលែងលះ
- ដើម្បីយល់ឱ្យបានកាន់តែស៊ីជម្រៅទៅលើនីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិ ការប្រគល់អំណាចមេបា និងការផ្តល់អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ និងកូន ព្រមទាំងអានុភាពនៃការលែងលះ
- ដើម្បីចូលរួមជាផ្នែកមួយក្នុងការផ្តល់អនុសាសន៍ ក្នុងការធ្វើឱ្យមាននូវវឌ្ឍនភាពនៃការអនុវត្តច្បាប់ និងការចូលរួមក្នុងការបញ្ចេញមតិយោបល់នៅចំណុចណាដែលនាងខ្ញុំ និងខ្ញុំបាទបានសិក្សាស្រាវជ្រាវហើយមើលឃើញថាមានចំណុចខ្វះខាតផងដែរ។
- ជាចុងក្រោយ ដើម្បីចងក្រងទុកជាវត្ថុអនុស្សាវរីយ៍សម្រាប់មិត្តអ្នកអាន និងសិក្សាទាំងឡាយក្នុងការងាយស្រួលដល់ការសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមទៅលើប្រធានបទមួយនេះ។

ប្រធានបទ **ការលែងលះនៅកម្ពុជា** នេះមានវិសាលភាពគ្របដណ្តប់ទៅលើសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ដែលស្របច្បាប់ និងនីតិវិធីនៃលែងលះស្របតាមផ្លូវច្បាប់ដែលក្នុងនោះយើងសិក្សាទៅលើចំណុចមួយចំនួនដូចជា ទិដ្ឋភាពទូទៅនៃការលែងលះ មូលហេតុនៃការលែងលះ មូលហេតុដែលមិនអាចធ្វើឱ្យសហព័ទ្ធលែងលះបាន ប្រភេទនៃការលែងលះ សេចក្តីសម្រេចនៃការលែងលះ នីតិវិធីនៃការលែងលះដោយ

មានការព្រមព្រៀង នីតិវីធីនៃការលែងលះដោយមិនមានការព្រមព្រៀង ព្រមទាំងអានុភាពនៃលែងលះ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ ច្បាប់ស្តីពីបណ្តឹងទាក់ទង និងឋានៈបុគ្គលឆ្នាំ២០១០ ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ ២០១០ ដែលត្រូវបានយកមកអនុវត្តនៅក្នុងពេលបច្ចុប្បន្ននេះតែប៉ុណ្ណោះ។

ដូចនេះដើម្បីជាជំនួយ និងឆ្លើយទៅលើបញ្ហានៃភាពស្មុគស្មាញទាំងនោះ ខ្ញុំបាទ នាងខ្ញុំបានលើយកនូវប្រធានបទ " **ការលែងលះនៅកម្ពុជា** " ដោយមានការបែងចែកជា ៤(បួន) ជំពូកធំៗដែលក្នុងនោះរួមមាន៖

ជំពូកទី១ សញ្ញាទូទៅនៃការលែងលះ

១.១. និយមន័យនៃអាពាហ៍ពិពាហ៍

១.២. និយមន័យនៃការលែងលះ

១.៣. ប្រភេទនៃការលែងលះ

១.៤. មូលហេតុនៃការលែងលះ

ជំពូកទី២ ការលែងលះដោយការព្រមព្រៀង

២.១. នីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង

២.២. ការសម្រេចសេចក្តី

ជំពូកទី៣ ការលែងលះដោយគ្មានការព្រមព្រៀង

៣.១. សញ្ញាទូទៅនៃការលែងលះដោយគ្មានការព្រមព្រៀង

៣.២. នីតិវិធីនៃការលែងលះ

ជំពូកទី៤ អានុភាពនៃការលែងលះ

៤.១. ការកាត់ផ្តាច់ទំនាក់ទំនងញាតិ

៤.២. ការបែងចែកទ្រព្យសម្បត្តិ

៤.៣. អានុភាពលែងលះចំពោះកូន

# ជំពូកទី ១

# សញ្ញាណទូទៅនៃការលៃខលះ

# ជំពូកទី១

# សញ្ញាណទូទៅនៃការលែងលះ

មនុស្សគ្រប់គ្នាបានមើលឃើញថាអាពាហ៍ពិពាហ៍ជាការកើតចេញពីការស្ម័គ្រចិត្ត និងការព្រមព្រៀងគ្នារបស់មនុស្សពីរនាក់។ យ៉ាងណាមិញមនុស្សគ្រប់គ្នា មិនសូវមើលឃើញដល់ចំណងអាពាហ៍ពិពាហ៍នោះថាតើជាអាពាហ៍ពិពាហ៍ស្របច្បាប់ ឬមិនស្របច្បាប់នោះទេ ពួកគេមើលបានត្រឹមថាមនុស្សពីរនាក់បានស្ម័គ្រចិត្តរៀបចំពិធីមង្គលអាពាហ៍ពិពាហ៍ជាមួយគ្នាតាមបែបប្រពៃណីខ្មែរ ដោយមានចាស់ទុំ ឪពុកម្តាយ បងប្អូនសាច់ញាតិទាំងសងខាងដឹងឮ មានថ្លៃបណ្ណាការ និងមានភ្ញៀវកិត្តិយសចូលរួមយ៉ាងច្រើនកុះករក្នុងកម្មវិធីនោះតែប៉ុណ្ណោះ។

ដូច្នេះចំណងអាពាហ៍ពិពាហ៍ដែលមានអានុភាពទៅបាន លុះត្រាតែចំណងអាពាហ៍ពិពាហ៍នោះត្រូវបានបង្កើតឡើងដោយគោរពតាមលក្ខខណ្ឌច្បាប់ដែលបានកំណត់យ៉ាងត្រឹមត្រូវ។ បើទោះបីជាអាពាហ៍ពិពាហ៍នោះមានអានុភាពនឹងស្របតាមច្បាប់ក៏ដោយ ក៏ប៉ុន្តែចំណងអាពាហ៍ពិពាហ៍នោះក៏អាចរំលាយទៅវិញបានដូចគ្នា ដោយអាស្រ័យទៅលើលក្ខខណ្ឌច្បាប់ដែលបានកំណត់ និងតម្រូវ។ ការលែងលះគ្នា ត្រូវបានចាត់ទុកជាសាលក្រម ឬសាលដីការបស់តុលាការ ប្រកាសពីចំណងអាពាហ៍ពិពាហ៍ ដែលបានគោរពទៅតាមលក្ខខណ្ឌផ្លូវច្បាប់ត្រូវបានបញ្ចប់ ហើយសហព័ទ្ធទាំងពីរនឹងលែងមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាតទៅទៀតហើយ។

សាលក្រម ឬសាលដីកានេះ ជាសេចក្តីសម្រេចរបស់តុលាការ ដែលធ្វើការពិចារណាទៅលើភស្តុតាងមានឯកសារ ដែលមានជាប់ពាក់ព័ន្ធផ្សេងៗ និងបញ្ហានៃចំណងអាពាហ៍ពិពាហ៍ដែលតុលាការត្រូវសម្រេចនៅក្នុងវិវាទនៃចំណងអាពាហ៍ពិពាហ៍នោះ ថាត្រូវឱ្យលែងលះ ឬផ្សះផ្សាចំពោះចំណងអាពាហ៍ពិពាហ៍នោះ។[១]

## ១.១. និយមន័យនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលបានប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួន។

អាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកថាស្របច្បាប់ លុះត្រាណាតែបុរស និងនារីបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅឃុំ-សង្កាត់ដែលបានទទួលពាក្យរៀបអាពាហ៍ពិពាហ៍នោះ។[២]

---

[១] បណ្ឌិត ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍,ទំព័រទី ១៨៥, បោះពុម្ពឆ្នាំ២០១៣។

[២] ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣, មាត្រា ៧០, កថាខណ្ឌទី១។

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាពិសេសមួយ ដោយកិច្ចសន្យាអាពាហ៍ពិពាហ៍ត្រូវធ្វើឱ្យមានការព្រិតព្រៀងបំផុត ត្រូវគោរពតាមប្រពៃណី តាមលក្ខខណ្ឌច្បាប់ ព្រមទាំងត្រូវស្របទៅតាមគោលការណ៍នៃបទបញ្ញត្តិច្បាប់ដែលបានកំណត់។ មានន័យបុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃ ឃុំ-សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី។[៣] មានន័យថានៅក្នុងកិច្ចសន្យាក្នុងរឿងអាពាហ៍ពិពាហ៍ គឺមិនអាចធ្វើឡើងដោយត្រឹមតែផ្ទាល់មាត់បាននោះទេ ទោះបីជាមានសំណើសុំរៀបអាពាហ៍ពិពាហ៍ក៏ដោយ។[៤] ដូចនេះ ការរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការរៀបអាពាហ៍ពិពាហ៍ ដោយមន្ត្រីអត្រានុកូលដ្ឋានត្រូវផ្សព្វផ្សាយជាសាធារណៈអំពីអាពាហ៍ពិពាហ៍ តាមរយៈការបិទបណ្ណប្រកាស១ (មួយ) ច្បាប់នៅលំនៅឋានរបស់នារី និង១ (មួយ) ច្បាប់ទៀតនៅសាលាឃុំ-សង្កាត់នៃលំនៅឋានរបស់នារី និងត្រូវបញ្ជូនបណ្ណប្រកាសចំនួន២ (ពីរ )ច្បាប់ទៀតនៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ-សង្កាត់ដែលបុរសរស់នៅ ដើម្បីបិទបណ្ណប្រកាសនោះ១ (មួយ) ច្បាប់នៅលំនៅឋានរបស់បុរស និង១ (មួយ) ច្បាប់ទៀតនៅសាលាឃុំ-សង្កាត់នៃលំនៅឋានរបស់បុរស។[៥]

## ១.២. និយមន័យនៃការលែងលះ

ការលែងលះ គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលបានរៀបការពេញច្បាប់ក្នុងពេលរស់នៅទាំងពីរនាក់។ ការលែងលះ សំដៅដល់ការផ្លាស់ប្តូរទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធ នៅក្នុងរង្វង់ញាតិ និងសង្គម។ ម្យ៉ាងទៀតការលែងលះ គឺជាការដោះខ្លួនចេញពីចំណងនៃទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធដែលខ្លួនធ្លាប់ជាសហព័ទ្ធនឹងគ្នាកន្លងមក។ បើកាលណាគេនិយាយដល់ការដោះខ្លួនចេញពីចំណងអាពាហ៍ពិពាហ៍ គេនឹងនឹកឃើញដល់កិច្ចសន្យាអាពាហ៍ពិពាហ៍ ដែលគេនិយាយពីការប្តេជ្ញាចិត្តរបស់ប្តីប្រពន្ធទាំងពីរនាក់ក្នុងការរួមសមគ្គសង្វាសនឹងគ្នា។ បើទោះបីជា មានការប្តេជ្ញាចិត្តរបស់ប្តីប្រពន្ធទាំងពីរអ្នកក្នុងការរួមសមគ្គសង្វាសនឹងគ្នាក៏ពិតមែន ប៉ុន្តែកិច្ចសន្យាអាពាហ៍ពិពាហ៍នៅតែអាចរំលាយបានតាមរយៈការលែងលះ។ ហើយសហព័ទ្ធដែលបានលែងលះគ្នា នឹងអាចបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មីជាមួយនរណាម្នាក់ផ្សេងៗទៀតក៏បានផងដែរ។ ជាមួយគ្នានេះប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងសោហ៊ុយដើម្បីរក្សាជីវភាពរួមរស់របស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូន ព្រមទាំង

[៣] អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០, មាត្រា ២៨ វាក្យខណ្ឌទី ១។

[៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥៥។

[៥] ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣, មាត្រា ៦៩ កថាខណ្ឌទី១។

សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។ មិនតែប៉ុណ្ណោះប្តីប្រពន្ធទាំងសងខាងត្រូវតែអនុវត្តតាមកាតព្វកិច្ច និងករណីយកិច្ចផ្សេងទៀតដែលបានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀតដែលប្តី ឬប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរ ពីប្រពន្ធ ឬប្តីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[៦]

## ១.៣. ប្រភេទនៃការលែងលះ

ជាទូទៅការរៀបអាពាហ៍ពិពាហ៍ដើម្បីឱ្យមានអានុភាព លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០២៣ និងអនុក្រឹត្យលេខ១០៣ ឆ្នាំ២០០០។ ជាមួយគ្នានេះការលែងលះក៏ដូចគ្នា ប្តីប្រពន្ធ អាចធ្វើការលែងលះគ្នាបានក៏ត្រូវមានក្បួនខ្នាតដែលមានចែងក្នុងច្បាប់ដូចគ្នា។ ប្តីប្រពន្ធ អាចធ្វើការលែងលះគ្នាដោយមានការព្រមព្រៀងគ្នាទាំងសងខាងដោយគ្មានកំហុសរបស់ប្តី ឬប្រពន្ធឡើយ។ ផ្ទុយទៅវិញ ក៏មានគូស្វាមីខ្លះ បានបង្កើតកំហុសជារឿយៗដោយអត់ទ្រាំពុំបាន ដោយអស់សេចក្តីអត់ធ្មត់ ជាហេតុធ្វើឱ្យភាគីប្តី ឬប្រពន្ធរបស់ពួកគេបានធ្វើការដាក់ពាក្យប្តឹងសុំលែងលះ ក្នុងគោលបំណងបញ្ចប់ទំនាក់ទំនងប្តីប្រពន្ធ។ ដូច្នេះហើយបានជា ការលែងលះត្រូវបានបែងចែកជាពីរប្រភេទផ្សេងពីគ្នា គឺការលែងលះគ្នាដោយមានការព្រមព្រៀង និងការលែងលះគ្នាដោយមិនមានការព្រមព្រៀងគ្នា។

### ១.៣.១. ការលែងលះដោយមានការព្រមព្រៀង

ថ្វីត្បិតតែការរៀបអាពាហ៍ពិពាហ៍ គឺកើតឡើងដោយការព្រមព្រៀងរវាងបុរស និងស្ត្រី ដែលសច្ចាថានឹងរួមរស់ក្នុងជីវិតជាគូស្វាមីភរិយា ដើម្បីបង្កើតគ្រួសារមួយដែលមានសុភមង្គលក៏ដោយ ក៏ការសច្ចាប្រណិធានស្បថនេះមិនអាចគង់វង្សជានិរន្តរ៍ដែរ។ នៅក្នុងសង្គម គេមើលឃើញថាមានគូស្វាមីភរិយាច្រើនណាស់ ដែលមានគូស្វាមីខ្លះជាគូស្វាមីនីតិជន និងនីតិជន ខ្លះទៀតជាសហព័ទ្ធដែលមានម្ខាងជាអនីតិជន និងម្ខាងទៀតជានីតិជន និងថែមទាំងមានគូស្វាមីខ្លះទៀតជាអនីតិជនទាំងពីរថែមទៀតផង។ បើទោះបីជាគូស្វាមីមួយចំនួនយើងមើលឃើញថាគាត់រៀបការពេលវ័យជំទង់ និងវ័យក្មេងក៏ពិតមែន ក៏ប៉ុន្តែគ្រួសាររបស់ពួកគេខ្លះក៏រស់នៅយ៉ាងចុះសម្រុង និងមានសុភមង្គល។ យ៉ាងណាមិញនៅមានគ្រួសារមួយចំនួនទៀតដែលតែងតែមានជម្លោះក្នុងគ្រួសាររស់នៅមិនចុះសម្រុងគ្នា និងមានភាពរកាំរកូសជាច្រើននៅក្នុងជីវិតជាគូររបស់ពួកគេ ដែលធ្វើឱ្យពួកគេមានចិត្ត

[៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០០៧, មាត្រា ៩៧៥។

គំនិតផ្ទុយពីគ្នា មិនមានការអធ្យាស្រ័យគ្នា ប្រកាន់យកឈ្នះរៀងខ្លួន រហូតធ្វើឱ្យជីវិតគូរបស់ពួកគេមានផលវិបាកក្នុងការរស់នៅជាមួយគ្នាបន្តទៀត។ ម្យ៉ាងទៀត បញ្ហាទាំងអស់នេះបាននាំមកនូវផលវិបាកនៅក្នុងគ្រួសារ និងចំណងអាពាហ៍ពិពាហ៍របស់ពួកគេថែមទៀតផង ដែលពេលខ្លះក៏នឹងឈានដល់ការលែងលះគ្នាថែមទៀតផង។ លើសពីនេះ ប្រសិនបើការលែងលះរបស់ពួកគជាការលែងលះដោយទ្វេភាគី មានន័យថា មានការព្រមព្រៀងគ្នាក្នុងការបង្ហាញឆន្ទៈទាំងពីរនាក់ក្នុងការសម្រេចចិត្តលែងលះគ្នា។ ពោលគឺ ការលែងលះនោះត្រូវបានធ្វើឡើងដោយការព្រមព្រៀងគ្នារវាងគូស្វាមីដោយមិនមានភាគីណាមួយបង្ខិតបង្ខំ ឬការដាក់ពាក្យសុំលែងលះពីភាគីម្ខាងណាមួយឡើយ។

ក្នុងករណីនេះ ដោយមានការព្រមព្រៀងធ្វើការលែងលះគ្នាដោយភាគីទាំងសងខាង ហើយភាគីទាំងសងខាងគិតថាមិនអាចធ្វើបដិទានឡើងវិញបានទេ នោះសហព័ទ្ធទាំងពីរអាចសម្រេចចិត្តធ្វើការលែងលះ ដើម្បីបញ្ចប់ចំណងអាពាហ៍ពិពាហ៍របស់ខ្លួនបាន។[៧] បន្ទាប់ពីធ្វើការសម្រេចចិត្តរួចហើយ ភាគីរបស់សហព័ទ្ធនៃអាពាហ៍ពិពាហ៍ អាចដាក់ពាក្យសុំលែងលះទៅតុលាការបាន។ ក្នុងករណីដែលភាគីទាំងសងខាងពិតជាបានព្រមព្រៀងក្នុងការលះលែងគ្នាពិតប្រាកដមែន ហើយតុលាការនឹងធ្វើការពិចារណាទៅលើពាក្យសុំរបស់ភាគីសហព័ទ្ធថា ពិតជាបានបង្ហាញឆន្ទៈក្នុងការលែងលះ ដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍ពិតប្រាកដដែរទេ។ ក្នុងករណីនេះទោះបីជាគូស្វាមីទាំងសងខាងបានបង្ហាញឆន្ទៈតាមការនិយាយថាខ្លួនមានការព្រមព្រៀងក្នុងការលែងលះក៏ដោយ ក៏តុលាការមិនអាចសម្រេចចិត្តក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍នោះបានភ្លាមៗនោះដែរ ពោលគឺតុលាការនឹងធ្វើការស្វែងយល់ពីសហព័ទ្ធទាំងសងខាងដោយយកចិត្តទុកដាក់ ប្រសិនបើស្វែងយល់ឃើញថាសហព័ទ្ធទាំងពីរ ពិតជាមានឆន្ទៈដូចគ្នា ស្របគ្នាក្នុងការរំលាយអាពាហ៍ពិពាហ៍នោះពិតប្រាកដមែន នោះតុលាការនឹងអនុញ្ញាតឱ្យធ្វើការរំលាយចំណងអាពាហ៍ពិពាហ៍នោះបាន ដោយស្របតាមច្បាប់។ ប៉ុន្តែប្រសិនបើនៅក្នុងករណីដែលតុលាការបានស្វែងយល់ឃើញថា ការលែងលះនោះធ្វើឱ្យមានការលំបាក ឬធ្វើឱ្យមានផលប៉ះពាល់ដល់ការទ្រទ្រង់ជីវភាព និងផលប្រយោជន៍កូន ឬមានការឈឺចាប់ដែលមិនអាចទ្រាំទ្របានទេនោះ នោះតុលាការអាចធ្វើការច្រានចោលការស្នើរសុំលែងលះគ្នា ដោយពិនិត្យទៅលើស្ថានភាពខាងលើបាន។

**ឧទាហរណ៍៖** សុខ និង សប្បាយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា កាលពីឆ្នាំ២០២០ ហើយពួកគាត់ទាំងពីរបានរៀបការដោយស្របច្បាប់ដោយមានចុះសំបុត្រអាពាហ៍ពិពាហ៍។ បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍អស់រយៈពេល៤ឆ្នាំ អ្នកទាំងពីមិនមានកូននោះទេ ហើយថែមទាំងរស់នៅមិនចុះសម្រុងនឹងគ្នា មានជម្លោះឈ្លោះទាស់ទែងគ្នាជារឿយៗថែមទៀតផង។ ការរស់នៅមិនចុះសម្រុងគ្នានេះ បានធ្វើឱ្យប៉ះពាល់ដល់សុភមង្គលនៅ

[៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៩។

ក្នុងគ្រួសាររបស់ពួកគេ ដែលជាហេតុនាំឱ្យ សុខ និង សប្បាយ បានអស់មនោសញ្ចេតនាស្នេហាជាមួយនឹងគ្នា។ ដោយអ្នកទាំងពីរបានដឹងខ្លួនថា ពួកគេមិនអាចរស់នៅជាមួយគ្នាបានដោយហេតុថារស់នៅមិនចុះសម្រុងនឹងគ្នា ហើយថែមទាំងអស់មនោសញ្ចេតនាជាប្តីប្រពន្ធជាមួយគ្នាទៀត អ្នកទាំងពីរក៏បានបង្ហាញឆន្ទៈស្របគ្នា ហើយ សុខ ក៏បានដាក់ពាក្យស្នើសុំលែងលះទៅតុលាការ ដើម្បីធ្វើការសុំបញ្ចប់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេ។ ឆ្លងតាមសិក្សាស្វែងយល់ និងសម្អាងទៅលើហេតុផលរបស់អ្នកទាំងពីរ បើតុលាការបានពិនិត្យឃើញថាត្រឹមត្រូវតាមលក្ខខណ្ឌនៃច្បាប់ដោយអាចឱ្យអ្នកទាំងពីរនាក់លែងលះគ្នាបាន តុលាការក៏បានចេញសាលដីកាសម្រេចស្តីពីការលែងលះគ្នារវាង សុខ និងសប្បាយ។ មានន័យថាចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរត្រូវបានបញ្ចប់ពេលសាលក្រមចូលជាស្ថាពរ ហើយអ្នកទាំងពីរ មានសិទ្ធិក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មីបាន។

### ១.៣.២. ការលែងលះដោយគ្មានការព្រមព្រៀងគ្នា

បើទោះបីជាយើងមើលឃើញថា ការលែងលះគ្នាដោយមានការព្រមព្រៀងអាចនឹងមិនសូវស្មុគស្មាញ ពីព្រោះតែវាកើតឡើងដោយការបង្ហាញឆន្ទៈរបស់សហព័ទ្ធពិតមែន ក៏ប៉ុន្តែក៏មានការលែងលះមួយប្រភេទទៀត ដែលហាក់មានការស្មុគស្មាញច្រើនពីព្រោះ ការលែងលះនោះត្រូវបានធ្វើឡើងដោយគ្មានការព្រមព្រៀងពីភាគីម្ខាងទៀត ឬមានការបង្ហាញឆន្ទៈក្នុងការលែងលះដោយភាគីតែម្ខាងនៃសហព័ទ្ធនោះ។ ក្នុងករណីនេះ ភាគីម្ខាងនៃសហព័ទ្ធបានដាក់ពាក្យប្តឹងសុំលែងលះភាគីម្ខាងទៀតទៅតុលាការដោយឯកឯង ហើយដោយមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតឡើយ។ ក្នុងករណីនេះ ភាគីម្ខាងនៃសហព័ទ្ធដែលដាក់ពាក្យបណ្តឹងបានរកឃើញថាសហព័ទ្ធរបស់ខ្លួនបានប្រព្រឹត្តអំពើមិនគប្បីណាមួយមកលើខ្លួន ឬបានប្រព្រឹត្តអំពើផិតក្បត់ណាមួយ ដែលជាហេតុធ្វើឱ្យខ្លួនចង់បញ្ចប់ចំណងអាពាហ៍ពិពាហ៍របស់ខ្លួន។

**ឧទាហរណ៍៖** សុខ និងសប្បាយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាអស់រយៈពេល៤ឆ្នាំមកហើយ ហើយមកដល់ឆ្នាំចុងក្រោយនេះ សុខ បានរកឃើញថា សប្បាយ បានលួចលាក់មានសាហាយស្មន់ និងតែងតែប្រើអំពើហិង្សាមកលើខ្លួនដែលជាហេតុធ្វើឱ្យ សុខ មិនអាចទទួលយកបាន និងមិនអាចទ្រាំរួមរស់នៅជាមួយ សប្បាយ ទៀតបានឡើយ។ ពេលនោះសុខ ក៏បានដាក់ពាក្យសុំលែងលះទៅតុលាការដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍ជាមួយ សប្បាយ។

## ១.៤. មូលហេតុនៃការលែងលះ

ការលែងលះគ្នាដែលមានការព្រមព្រៀងគ្នាមិនចាំបាច់ត្រូវមានហេតុផលអ្វីច្រើននោះទេ ប៉ុន្តែប្រសិនបើការលែងលះមិនមែនជាការលែងលះដែលមានការព្រមព្រៀង ឬការលែងលះដោយសកម្មភាពឯកតោភាគីនោះ ការលែងលះនោះអាចធ្វើទៅបានលុះត្រាតែមានមូលហេតុត្រឹមត្រូវ និងច្បាស់លាស់ស្របតាមបញ្ញត្តិនៃច្បាប់។

ជាទូទៅ មូលហេតុដែលបណ្ដាលឱ្យមានការលែងលះទាំងនោះរួមមានៈ

- បានប្រព្រឹត្តិអំពើផិតក្បត់ទៅលើសហព័ទ្ធ
- បានបោះបង់សហព័ទ្ធចោលដោយគ្មានហេតុផលត្រឹមត្រូវ
- ករណីមិនដឹងច្បាស់ថាសហព័ទ្ធរបស់ខ្លួនស្លាប់ ឬ រស់អស់រយៈពេលជាង ១(មួយ) ឆ្នាំ
- ករណីសហព័ទ្ធបានរស់នៅបែកគ្នា
- ករណីផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់។[៨]

### ១.៤.១. បានប្រព្រឹត្តអំពើផិតនៅលើសហព័ទ្ធ

ចំណងអាពាហ៍ពិពាហ៍មួយ កើតឡើងដោយសារតែគូស្វាមីទាំងសងខាងបានយល់ព្រម បានព្រមព្រៀងគ្នា សច្ចាប្រណិធានជាមួយគ្នា មានការព្រមស្ម័គ្រចិត្តរួមរស់នៅជាមួយគ្នា និងស្មោះត្រង់ជាមួយគ្នា ធ្វើជាដៃគូជីវិតដ៏ល្អ ក៏ប៉ុន្តែបើទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមានគូស្វាមីខ្លះទៀត នៅតែមានការប្រព្រឹត្តផិតក្បត់ដដែល។ អំពើផិតក្បត់ ឬត្រូវចាត់ទុកថាផិត គឺជាការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្ដីរបស់ខ្លួន។[៩]

**ឧទាហរណ៍៖** ប្ដីបានលួចលាក់ចិញ្ចឹម និងទំនុកបម្រុងស្ត្រីណាម្នាក់ដែលជាស្ត្រីកំណាន់ចិត្តរបស់ខ្លួន។

### ១.៤.២. ករណីដែលបានបោះបង់សហព័ទ្ធចោលដោយគ្មានហេតុផលត្រឹមត្រូវ

អាពាហ៍ពិពាហ៍កើតឡើងក្នុងគោលបំណងដែលគូស្វាមីមួយគូ បានព្រមព្រៀងគ្នាក្នុងការរួមរស់នៅជាមួយគ្នា រួមសមគ្គសង្វាសជាមួយគ្នា និងបង្ហាញឆន្ទៈក្នុងការបង្កើតគ្រួសារមួយប្រកបដោយសេចក្ដីសុខសាន្ត និងសុភមង្គល។ ប្រសិនបើមានភាគីម្ខាងណានៃសហព័ទ្ធបានធ្វើការបោះបង់សហព័ទ្ធរបស់ខ្លួនចោលដោយគ្មានហេតុផលត្រឹមត្រូវនោះ ក៏ជាមូលហេតុដែលភាគីម្ខាងទៀតអាចដាក់ពាក្យសុំលែងលះទៅតុលាការបានផងដែរ។ ការបោះបង់សហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវនេះ ចង់សំដៅលើភាគីម្ខាងបានបង្ហាញឆន្ទៈក្នុងការមិនព្រមសហការ និងមិនសង្គ្រោះគ្នាទៅវិញទៅមក ដោយមានការបង្ហាញឆន្ទៈ ឬបង្ហាញពីសកម្មភាពណាមួយក្នុងការដែលមិនអាចរួមរស់នៅជាមួយគ្នា និងមិនចង់បន្តរួមរស់នៅក្នុងជីវភាពជាប្ដីប្រពន្ធបន្តទៀតបានឡើយ។[១០]

[៨] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ៥៦ ក្រ, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩, មាត្រា ៣៩។

[៩] ច្បាប់ស្ដីពីឯកពន្ធភាព, លេខ នស/ រកម/ ១០០៦/០២៦, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០០៦, មាត្រា ៧ វាក្យខណ្ឌទី១។

[១០] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៨, កថាខណ្ឌទី១, ចំណុច ខ។

**ឧទាហរណ៍៖** សុខ និងសប្បាយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាអស់រយៈពេល៤ឆ្នាំមកហើយ ហើយរយៈពេល២ឆ្នាំចុងក្រោយនេះ សុខបានចុះចេញពីទីលំនៅឋានទៅរស់នៅជាមួយម្ដាយឪពុករបស់ខ្លួនវិញ ដោយមិនមានមូលហេតុណាមួយច្បាស់លាស់ និងត្រឹមត្រូវឡើយ។ ក្នុងករណីនេះ សប្បាយអាចដាក់ពាក្យសុំលែងលះទៅកាន់តុលាការ ដើម្បីស្នើសុំធ្វើការលែងលះ និងសុំផ្ដាច់ចំណងអាពាហ៍ពិពាហ៍មួយនេះបានផងដែរ។

### ១.៤.៣. ករណីដែលមិនដឹងច្បាស់ថាសហព័ទ្ធរបស់ខ្លួនស្លាប់ ឬ រស់អស់រយៈពេលជាង ១(មួយ)ឆ្នាំ

ចំណងអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាមួយដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្ដេជ្ញាថារួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួននោះទេ។ ប៉ុន្តែបញ្ញត្តិច្បាប់នៃក្រមរដ្ឋប្បវេណី ក៏បានបញ្ញត្តិថាចំណងអាពាហ៍ពិពាហ៍នេះក៏អាចរំលាយក្នុងករណីដូចជាសហព័ទ្ធណាមួយស្លាប់ ឬមានសហព័ទ្ធណាម្នាក់បានបាត់ខ្លួនហួសពីមួយឆ្នាំដោយមិនបានទទួលដំណឹងអ្វីសោះ មិនដឹងថាស្លាប់ ឬរស់។ ក្នុងករណីនេះប្ដី ឬប្រពន្ធដែលបានចាកចេញពីផ្ទះអស់រយៈពេល១ឆ្នាំ ឬលើសមួយឆ្នាំ ដោយគ្មានដំណឹង ឬមិនបានផ្ដល់ដំណឹងត្រឡប់មកកាន់គ្រួសារវិញពីសុខទុក្ខរបស់ខ្លួនទាល់តែសោះ។ មានន័យថាសហព័ទ្ធអាចដាក់ពាក្យសុំប្ដឹងលែងលះ ឬជូនដំណឹងទៅឃុំ-សង្កាត់ឱ្យបានដឹងពីរឿងនេះបាន។[១១]

**ឧទាហរណ៍៖** សុខ និង សប្បាយ បានរៀបការជាមួយគ្នារួចហើយ ប៉ុន្តែដោយសារតែ សប្បាយ ជាអ្នកប្រកបមុខរបរនេសាទនៅក្នុងមហាសមុទ្រ។ ជារៀងរាល់សប្ដាហ៍ សប្បាយ តែងតែទាក់ទងតាមទូរសព្ទមកលេង សុខ និងបានសាកសួរពីសុខទុក្ខគ្នាទៅវិញទៅមក ពីព្រោះថា រៀងរាល់កន្លះឆ្នាំម្ដងទើប សប្បាយ បានត្រឡប់មកដីគោកវិញ។ ប៉ុន្តែដល់ពេលដែលត្រូវត្រឡប់មកផ្ទះវិញ សុខមិនបានឃើញសប្បាយមកវិញទេ ហើយថែមទាំងមិនអាចទាក់ទងបានទៀត។ មួយឆ្នាំក្រោយមក សុខក៏បានដាក់ពាក្យសុំលែងលះទៅតុលាការ ដោយហេតុថា សុខមិនទទួលបានដំណឹងរបស់សប្បាយនោះឡើយ មិនដឹងថាស្លាប់ ឬរស់អស់រយៈពេល១ឆ្នាំមកហើយ។

### ១.៤.៤. ករណីសហព័ទ្ធបានរស់នៅបែកគ្នា

ក្នុងករណីដែលគ្មានដំណឹងពីសហព័ទ្ធណាម្ខាង ឬដឹងថាស្លាប់ឬរស់ រយៈពេលលើសពី១ឆ្នាំហើយនោះ ភាគីម្ខាងនៃសហព័ទ្ធ អាចដាក់ពាក្យសុំលែងលះបាន ក៏ប៉ុន្តែប្រសិនបើនៅតែអាចទទួលបានដំណឹងហើយដឹងថាភាគីម្ខាងទៀតនៅរស់ក៏ដោយ ក៏ភាគីម្ខាងទៀតអាចដាក់ពាក្យសុំលែងលះបានដែរក្នុងករណីដែលសហព័ទ្ធម្ខាងទៀតរបស់ខ្លួនបានរស់នៅបែកគ្នា។ ក្នុងករណីនេះសហព័ទ្ធមិនមែនមិនផ្ដល់ដំណឹងនោះទេ ប៉ុន្តែសហព័ទ្ធ

[១១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៨, កថាខណ្ឌទី១, ចំណុច គ។

បានរស់នៅបែកគ្នាអស់រយៈពេលចាប់ពី១ឆ្នាំឡើងទៅហើយនោះ ភាគីម្ខាងទៀតអាចដាក់ពាក្យសុំលែងលះបាន ពីព្រោះថា ភាគីម្ខាងទៀតបានប្រព្រឹត្ត ឬបានអនុវត្តផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍។ យ៉ាងណាមិញ ចំពោះការចាកចេញទៅប្រកបរបរដើម្បីយកប្រាក់កម្រៃមកផ្គត់ផ្គង់គ្រួសារមិនត្រូវបានរាប់បញ្ចូលឡើយ។[១២]

**ឧទាហរណ៍៖** សុខ និងសប្បាយបានរៀបអាពាហ៍ពិពាហ៍នឹងគ្នារយៈពេលកន្លះឆ្នាំ ហើយអ្នកទាំងពីរក៏មានការឈ្លោះប្រកែកគ្នា រហូតដល់សុខសម្រេចចិត្តចាក់ចេញពីផ្ទះហើយរស់នៅបែកពីសប្បាយ។ អ្នកទាំងពីរបានរស់នៅបែកពីគ្នារយៈពេលមួយឆ្នាំ។ ក្នុងករណីនេះ ប្រសិនបើមានភាគីណាម្ខាងចង់ដាក់ពាក្យសុំលែងលះ ពួកគេអាចធ្វើទៅបានដោយគ្រាន់តែដាក់ពាក្យសុំលែងលះទៅតុលាការ និងបានបញ្ជាក់ពីមូលហេតុត្រឹមត្រូវនៃការដាក់ពាក្យសុំលែងលះដើម្បីឱ្យតុលាការធ្វើការពិចារណា និងវិនិច្ឆ័យទៅលើពាក្យសុំលែងលះរបស់ពួកគេ។

### ១.៤.៥. មូលហេតុផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់

ការលែងលះគ្នា គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលបានរៀបមង្គលការពេញច្បាប់ក្នុងពេលរស់នៅជាមួយគ្នាទាំងពីរនាក់។ ហើយការលែងលះទាំងនោះមានមូលហេតុមួយចំនួនដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណី ប៉ុន្តែក៏មានមូលហេតុផ្សេងៗទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ដោយសារតែគ្មានសង្ឃឹមថាអាចនឹងធ្វើបដិទាន ឬស្តារឱ្យដូចដើមឡើងវិញបាន។ រាល់ការដាក់ពាក្យសុំលែងលះទៅតុលាការតែងតែមានការបញ្ជាក់ពីមូលហេតុនៃការលែងលះដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីដើម្បីឱ្យចៅក្រមធ្វើការពិនិត្យទៅលើមូលហេតុទាំងនោះ ប៉ុន្តែក្នុងករណីផ្សេងៗនេះ ភាគីសហព័ទ្ធដែលដាក់ពាក្យសុំលែងលះត្រូវកំណត់ពីមូលហេតុនៃការដាក់ពាក្យសុំលែងលះ ហើយទុកឱ្យចៅក្រមធ្វើការវិនិច្ឆ័យថា តើករណីណាខ្លះដែលធ្វើឱ្យយើងជឿថា ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលបានរៀបការពេញច្បាប់មិនអាចធ្វើបដិទានឡើងវិញបាន។ ដើម្បីកំណត់ថាអាពាហ៍ពិពាហ៍នោះពិតជាគ្មានសង្ឃឹមក្នុងការស្តារឡើងវិញ ឬមិនអាចធ្វើបដិទានបាន ចៅក្រមត្រូវពិចារណាដល់ស្ថានភាពនានារបស់សហព័ទ្ធ ដូចជា អាកប្បកិរិយា សកម្មភាពរបស់គូស្វាមីភរិយាក្នុងពេលដែលមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា ឆន្ទៈនៅក្នុងការបង្កើត និងបន្តចំណងអាពាហ៍ពិពាហ៍ រួមទាំងសុខភាពផ្លូវកាយ ទាំងផ្លូវចិត្តក្នុងគ្រួសារ និងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។[១៣]

ចំពោះការប្រើប្រាស់អំពើហិង្សាណាមួយ ទៅលើរូបរាងផ្លូវកាយធ្វើឱ្យមានរបួសស្នាម និងបានធ្វើបាបទៅលើសុខភាពផ្លូវចិត្ត ការចាប់បង្ខំទៅលើសហព័ទ្ធរបស់ខ្លួន ក៏ត្រូវបានរាប់បញ្ចូលនៅក្នុងចំណុចនេះផងដែរ។

---

[១២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៨, កថាខណ្ឌទី១, ចំណុច ឃ។

[១៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៨, កថាខណ្ឌទី១, ចំណុច ង។

ទោះបីជាយើងឃើញថា មូលហេតុទាំងអស់នេះភាគីម្ខាងនៃសហព័ទ្ធអាចដាក់ពាក្យស្នើសុំលែងលះទៅតុលាការក៏ពិតមែន ក៏ប៉ុន្តែតុលាការអាចច្រានច្រាលពាក្យសុំនេះ ប្រសិនបើចៅក្រមបានរកឃើញថា មានភាគីម្ខាងនៃសហព័ទ្ធមិនបានចូលរួមធ្វើបដិទានឡើងវិញនៃចំណងអាពាហ៍ពិពាហ៍ ឬធ្វើផ្ទុយនឹងភាពសុចរឹត។[១៤]

ចំពោះមូលហេតុផ្សេងៗដែលមានចែងនៅក្នុងច្បាប់នោះភាគច្រើនត្រូវបានគេមើលឃើញតាមទម្រង់ដូចមាននូវខាងក្រោម៖

### ១.៤.៥.១. ភាពមិនស្មោះត្រង់របស់ភាគីសហព័ទ្ធ

ក្នុងការរៀបអាពាហ៍ពិពាហ៍ ភាពស្មោះត្រង់របស់សហព័ទ្ធទាំងសងខាងពិតជាមានសារសំខាន់ណាស់ក្នុងការសម្រេចចិត្តមុននឹងរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែប្រសិនបើភាគីទាំងសងខាង ឬភាគីណាម្ខាងមិនមានភាពស្មោះត្រង់ក្នុងការបង្កើតអាពាហ៍ពិពាហ៍នោះទេ នោះចំណងអាពាហ៍ពិពាហ៍នោះនឹងហាក់សោះអង្គើយ មិនមានទំនុកចិត្តចំពោះគ្នា មានការកុហកគ្នា មានការបោកប្រាស់គ្នា ការមិនគោរពផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមក ឬមានការផិតក្បត់ចិត្តលួចមានអ្នកផ្សេង ហើយចំណងអាពាហ៍ពិពាហ៍នោះនឹងឈានដល់ការបែកបាក់ជាមិនខាន។

**ឧទាហរណ៍៖** សុខ និងពិសី បានរៀបការជាមួយគ្នារយៈពេល២ឆ្នាំ ដោយរស់នៅក្នុងជីវភាពសមរម្យមួយ ប៉ុន្តែមួយរយៈក្រោយមក ពួកគេតែងតែឈ្លោះទាស់ទែង ប្រកែកគ្នា ដោយសារតែសុខដែលជាប្តីតែងតែធ្វើការចាយវាយលើសពីចំណូលដែលរកបាន ឬចាយវាយខ្ជះខ្ជាយ មិនចេះសន្សំទុកដាក់ ដែលជាហេតុធ្វើឱ្យ ពិសី ជាប្រពន្ធមានការសង្ស័យទៅលើសុខ និងរករឿងសុខ។ ដោយសារតែមានការសង្ស័យ ពិសី ក៏បានចាប់ផ្តើមតាមដាន សុខ ហើយក៏រកឃើញថា សុខ បានលួចលាក់មានអ្នកថ្មី ហើយរាល់ចំណូលដែលសុខរកបាន និងប្រាក់ដែលយកពីផ្ទះទៅ ភាគច្រើនគឺយកទៅផ្គត់ផ្គង់ឱ្យអ្នកថ្មី។ ពិសី បានដឹងថាសុខមិនមានភាពស្មោះត្រង់នឹងខ្លួន និងបានក្បត់ចិត្តខ្លួន ហើយទង្វើរបស់ សុខ បានធ្វើឱ្យពិសីពិបាកទទួលយក ពិសីក៏ដាក់ពាក្យសុំលែងលះជាមួយ សុខ ដើម្បីផ្តល់សិទ្ធិសេរីភាពដល់ខ្លួនឯង និងយល់ព្រមឱ្យសុខទៅបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី។

### ១.៤.៥.២. រៀបការវ័យក្មេងពេករបស់សហព័ទ្ធទាំងសងខាង

ការរៀបការដែលធ្វើឡើងដោយភាគីទាំងសងខាងនៅវ័យក្មេងពេកជារឿងដែលពិបាក ព្រោះវាទាក់ទងជាមួយការសិក្សា ការអប់រំ និងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ ដែលបង្កជាហានិភ័យខ្ពស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ នៅក្នុងនោះក៏មានក្មេងស្រីមួយចំនួនដែលមានអាយុត្រឹម ១៥ឆ្នាំ ប៉ុណ្ណោះ ក៏ត្រូវបានឪពុកម្តាយយល់ព្រមឱ្យរៀបការ ដែលជាហេតុធ្វើឱ្យពួកគេពិបាកសូម្បីតែការគ្រប់គ្រងហិរញ្ញវត្ថុ និងចំណេះដឹងទាក់ទង

[១៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៨, កថាខណ្ឌទី១, ចំណុច ខ និងឃ។

ជាមួយនឹងការគ្រប់គ្រងហិរញ្ញវត្ថុ។ ម្យ៉ាងទៀត ការរៀបការវ័យក្មេងក៏អាចជាកត្តាមួយដែលរួមចំណែកដល់ការប្រើប្រាស់ហិង្សា ពីព្រោះថាពួកគេនៅវ័យក្មេងពេក រីឯការយោគយល់ និងការអនុគ្រោះក៏នៅមានកម្រិតដូចគ្នា។ មិនតែប៉ុណ្ណោះចំពោះក្មេងស្រីដែលមានវ័យក្មេងពេក ហើយមានផ្ទៃពោះ គឺមានផលប៉ះពាល់ខ្លាំងដល់សុខភាពរបស់ពួកគេ ព្រមទាំងចំណេះដឹងក្នុងការថែទាំកូនផងដែរ។ យ៉ាងណាមិញ ការរៀបអាពាហ៍ពិពាហ៍ដែលមានវ័យនៅក្មេងពេកមិនមានផលល្អសម្រាប់គ្រួសារ និងចំណងអាពាហ៍ពិពាហ៍នោះទេ ពោលគឺមានមនុស្សភាគច្រើនបានមើលឃើញថាវាបង្កជាហានិភ័យសម្រាប់អនីតិជន និងផ្តល់ផលពិបាកក្នុងការគ្រប់គ្រងគ្រួសារជាដើម។

**ឧទាហរណ៍៖** លី និងសី បានរៀននៅសាលាជាមួយគ្នា ហើយអ្នកទាំងពីរបានស្រឡាញ់គ្នាតាំងពីរៀនថ្នាក់ទី៨ ដោយសារតែសេចក្តីស្រលាញ់អ្នកទាំងពីរ បានសុំឪពុកម្តាយរៀបការ នៅពេលដែលខ្លួនរៀននៅត្រឹមថ្នាក់ទី១១ ហើយឪពុករបស់លីបានយល់ព្រម ដោយសារតែឪពុករបស់លី មានមុខរបរស្រាប់ ហើយនឹងចែកឱ្យលីធ្វើបន្ទាប់ពីរៀបការ ក្រោយការពិភាក្សាគ្នារបស់ឪពុកម្តាយទាំងសងខាង អ្នកទាំងពីរបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគ្នា នៅវ័យ១៧ឆ្នាំ ពួកគេបានរស់នៅជាមួយគ្នាអស់រយៈពេល៥ឆ្នាំ ហើយអ្នកទាំងពីរមានកូនប្រុសម្នាក់ ។ ដោយសារតែលីនៅក្មេងពេក មិនសូវមានជំនាញក្នុងការស្វែងរកអតិថិជន និងរក្សាអតិថិជន ព្រោះតាំងធ្វើការដោយប្រើអារម្មណ៍ ដែលជាហេតុធ្វើឱ្យមុខរបររបស់លីរកប្រាក់លែងសូវបាន ហើយលី និងសី ចាប់ផ្តើមមានជម្លោះក្នុងគ្រួសារដោយលីថាឱ្យសី មិនចេះជួយរកប្រាក់ និងមិនចេះគ្រប់គ្រងទ្រព្យសម្បត្តិ។ ដោយសារតែអ្នកទាំងពីរនៅវ័យក្មេងដូចគ្នា ពិបាកក្នុងការគ្រប់គ្រងអារម្មណ៍ សី ក៏បានតបទៅលីវិញ និងប្រមាណមើលងាយថាឱ្យលី និងថាគ្រប់យ៉ាងមកពីលីមិនចេះធ្វើការទើបលែងសូវមានអតិថិជន។ ដោយសារចិត្តខឹង និងចិត្តឆេវឆាវអ្នកទាំងពីរបានប្រើប្រាស់ហិង្សាទៅលើគ្នា ហើយអ្នកទាំងពីរតែងតែមានរឿងឈ្លោះប្រកែកបែបនេះជាញឹកញាប់រហូតដល់អ្នកទាំងពីរគិតថាមិនអាចរស់នៅចុះសម្រុងនឹងគ្នា ហើយសម្រេចចិត្តលែងលះគ្នាទាំងវ័យក្មេង។

**១.៤.៥.៣. កត្តាគ្រួសារ** ( **ក្រីក្រពេក, ឪពុកម្តាយ**.. )

ការរៀបការមួយចំនួនត្រូវបានបង្កើតឡើងដោយសារតែជីវភាពនៅក្នុងគ្រួសារមានភាពលំបាក និងក្រីក្រខ្លាំងពេកជាហេតុធ្វើឱ្យឪពុកម្តាយបង្ខំកូនដែលនៅវ័យក្មេងមានអាយុត្រឹម១៦ឆ្នាំ ១៧ឆ្នាំរៀបការដើម្បីអាចមានលទ្ធភាពក្នុងការជួយសម្រួលដល់បន្ទុកគ្រួសារ ឬគ្រួសារមួយចំនួនបានបង្ខំកូនឱ្យរៀបការដោយសារតែគ្រួសារម្ខាងទៀតជាគ្រួសារធូរធារ ឬទទួលបានផលប្រយោជន៍ផ្សេងៗពីការរៀបអាពាហ៍ពិពាហ៍របស់កូនជាដើម។

**ឧទាហរណ៍៖** សាយ ជាសិស្សនៅវិទ្យាល័យមួយកន្លែង ហើយបច្ចុប្បន្នសុខរៀនថ្នាក់ទី១០ ដោយសារតែជីវភាពគ្រួសារក្រីក្រខ្លាំងពេកមិនអាចផ្គត់ផ្គង់ការសិក្សារបស់សុខបន្តទៀតបានឡើយ។ សាយ ក៏បានឈប់រៀនហើយបានជួយស្វែងរកប្រាក់ចំណូលឱ្យគ្រួសារដើម្បីដោះស្រាយជីវភាព។ នៅថ្ងៃមួយមានអ្នកមានម្នាក់បាន

មកដណ្ដឹងសាយ ប៉ុន្តែកូនកំលោះមានអាយុច្រើនជាងសាយរហូតដល់ទៅ៤៥ឆ្នាំ។ ដោយសារតែកត្តាជីវភាពគ្រួសារ ឪពុកម្ដាយរបស់សាយបានយល់ព្រមលើកសាយឱ្យទៅលោកតា។ ដោយសារតែសាយនៅវ័យក្មេងពេក សាយ មានរូបសម្រស់ស្រស់ស្អាតថែមទៀត ប្ដីវ័យចំណាស់របស់នាងតែងតែប្រច័ណ្ឌនឹងសាយ និងបានវាយធ្វើបាបសាយជារៀងរាល់ថ្ងៃ។ ដោយសារតែមិនអាចទ្រាំទ្រនឹងការធ្វើទារុណកម្មពីសំណាក់ស្វាមីវ័យចំណាស់របស់ខ្លួនបាន សាយបានទៅដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការស្របពេលជាមួយនឹងខ្លួនមានទម្ងន់ជិតគ្រប់ខែ។

**១.៤.៥.៤. ក្ស័យធន**

ការរៀបអាពាហ៍ពិពាហ៍ ត្រូវបានប្រារព្ធឡើងយ៉ាងឱឡារិក ហើយជាការស្ម័គ្រស្មោះ និងសច្ចាប្រណិធានថានឹងរួមរស់ជាមួយគ្នា ក៏ពិតមែន ក៏ប៉ុន្តែក៏គេមើលឃើញថាមានការរៀបអាពាហ៍ពិពាហ៍មួយចំនួនបង្កើតឡើងដោយសារតែមើលឃើញពីផលប្រយោជន៍រៀងខ្លួន។ នៅក្នុងនោះដែរមនុស្សភាគច្រើន ពួកគេបានមើលឃើញពីភាពសុខសាន្តនៃទ្រព្យសម្បត្តិស្ដុកស្ដម្ភ និងការសោយសុខទៅលើវានៅក្នុងពេលបច្ចុប្បន្ន និងអនាគត ក៏ប៉ុន្តែទ្រព្យសម្បត្តិទាំងនោះក៏អាចបាត់បង់ទៅវិញយ៉ាងឆាប់រហ័សនៅថ្ងៃណាមួយក៏ថាបាន។ កត្តាដែលមើលឃើញពីទ្រព្យសម្បត្តិស្ដុកស្ដម្ភទាំងអស់នោះហើយ ដែលជាកត្តាចម្បងធ្វើឱ្យចំណងអាពាហ៍ពិពាហ៍របស់ពួកគេចាប់ផ្ដើមបែកបាក់នៅពេលណាដែលទ្រព្យសម្បត្តិទាំងនោះត្រូវបានបាត់បង់ ឬក្ស័យធន។ ចំណែកឯគូស្វាមីខ្លះទៀតបានកសាងពីបាតដៃទទេរហូតដល់មានបាន ប៉ុន្តែនៅពេលដែលមានការប្រែប្រួល ឬការរកចំណូលមិនបានដូចមុន ចំណាយច្រើនជាងចំណូលក៏បណ្ដាលឱ្យមានការឈ្លោះទាស់ទែងគ្នា រហូតដល់ការលែងលះក៏មានផងដែរ។

**ឧទាហរណ៍៖** បញ្ញា ជាគ្រួសារអ្នកជំនួញធំមួយ ហើយ នីតា ក៏ជាគ្រួសារអ្នកជំនួញដូចគ្នា។ ដោយសារតែឪពុករបស់អ្នកទាំងពីរសុទ្ធតែជាអ្នកមានស្ដុកស្ដម្ភ និងចង់បង្កើតចំណងមិត្តភាព និងមុខជំនួញរបស់ខ្លួនឱ្យកាន់តែរឹងមាំ ឪពុកអ្នកទាំងពីរ បានរៀបចំអាពាហ៍ពិពាហ៍ឱ្យបញ្ញា និងនីតា។ ៥ឆ្នាំក្រោយមក ដោយសារតែកប៉ាល់ទំនិញដែលគ្រួសាររបស់បញ្ញាផ្ទុកឥវ៉ាន់ត្រូវបានលិច ហើយគ្រួសាររបស់ បញ្ញា ត្រូវសងសំណងជាច្រើនដល់អតិថិជន ដោយរួមផ្សំនឹងការខាតបង់ធ្ងន់ធ្ងរ អតិថិជនលែងមានទំនុកចិត្ត គ្រួសាររបស់បញ្ញាក៏ក្ស័យធន។ ដោយហេតុថាខ្លាចឪពុករបស់ បញ្ញា មកពឹងពាក់ និងគិតថាមិនអាចជួយស្រោចស្រង់គ្រួសាររបស់ បញ្ញា បាន ហើយថែមទាំងខ្លាចគ្រួសាររបស់ខ្លួននឹងក្ស័យធនដែរ នោះឪពុករបស់នីតាក៏បានឱ្យ នីតា និងបញ្ញាលែងលះគ្នា ហើយឪពុករបស់ នីតា បានធ្វើការបញ្ចប់គ្រប់ចំណងទំនាក់ទំនងទាំងអស់ជាមួយនឹងគ្រួសាររបស់បញ្ញា។

**១.៤.៥.៥. ការប្រចណ្ឌសហព័ទ្ធ**

ការប្រចណ្ឌ គឺជាអារម្មណ៍មួយរបស់ភាគីម្ខាងនៃសហព័ទ្ធដែលខឹង ឬបារម្ភហួងហែងទៅលើប្ដី ឬប្រពន្ធរបស់គាត់ ឬជាការយល់ច្រឡំទៅលើភាគីម្ខាងទៀតនៃសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ ព្រោះតែខ្លាច

បាត់បង់សហព័ទ្ធរបស់ខ្លួន រហូតដល់បង្កឱ្យមានទំនាស់ និងធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងរបស់អ្នកទាំងពីរព្រមទាំងគ្រួសារផងដែរ។ ប្រសិនបើការប្រចណ្ឌហួងហែងទាំងនោះកាន់តែខ្លាំង រហូតដល់ការបិទសិទ្ធសេរីភាពសូម្បីតែទៅនេះទៅនោះក៏មិនបាន ហើយមិនអាចជួបមនុស្សស្គាល់គ្នា ឬអ្នកធ្វើការងារជាមួយបាន គឺពិតជាច្បាស់ណាស់ថាភាគីម្ខាងទៀតនឹងមិនអាចទ្រាំទ្រនូវអារម្មណ៍បែបនោះបានទេ។ បើកាលណាមានភាពតានតឹងកាន់តែកើនឡើង ការឈ្លោះប្រកែកទាស់ទែងគ្នា ការមិនទុកចិត្តគ្នាក៏កាន់តែកើតឡើង ហើយការរកវិធីសាស្ត្រដោះស្រាយក៏មិនមានលទ្ធផលល្អទៀត នោះការលែងលះគ្នានឹងអាចកើតមានឡើងជាក់ជាមិនខានឡើយ។

**ឧទាហរណ៍៖** តារា និងពិសី អ្នកទាំងពីរស្រឡាញ់គ្នាខ្លាំងណាស់ ហើយពេលអ្នកទាំងពីរបានរៀបការជាមួយគ្នាហើយអ្នកទាំងពីរកាន់តែស្រឡាញ់គ្នាខ្លាំងថែមទៀត។ ប៉ុន្តែដោយសារតែការស្រឡាញ់ ពិសី ខ្លាំងពេក តារាមិនឱ្យពិសីទៅធ្វើការទេ ព្រោះតារាប្រចណ្ឌ ពិសី ជាមួយនឹងមិត្តរួមការងាររបស់ពិសី ហើយបើទោះបីជា ពិសីបានបកស្រាយនឹងពន្យល់យ៉ាងណាក៏ដោយ ក៏តារាមិនស្ដាប់ ហើយថែមទាំងមិនឱ្យ ពិសីចេញទៅណាមកទៀត សូម្បីតែអ្នកជិតស្និតជាមួយពិសីពីមុន ក៏តារាហាមឃាត់មិនឱ្យទៅជួបផងដែរ ហើយតារាតែងតែរករឿងឈ្លោះជាមួយពិសីដោយឥតមូលហេតុថែមទៀតផង។ ដោយសារតែមិនអាចទ្រាំទ្រនឹងស្ថានភាពបំបិទសិទ្ធិសេរីភាពបែបនេះបានតទៅទៀត ពិសីក៏បានសម្រេចចិត្តទៅដាក់ពាក្យសុំលែងលះជាមួយនឹងតារានៅតុលាការ។

### ១.៤.៥.៦. ភាពសោះកក្រោះនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍

មនុស្សជាច្រើនបានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគ្នា ហើយក៏បានធ្វើការលែងលះគ្នាទៅវិញដោយសារហេតុផលផ្សេងៗគ្នា។ ប៉ុន្តែភាពសោះកក្រោះក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ក៏ជាកត្តាបែកបាក់មួយក្នុងចំណងអាពាហ៍ពិពាហ៍ផងដែរ។ យ៉ាងណាមិញ នៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍មួយដែលមានភាពសោះកក្រោះ និងមិនមានការយកចិត្តទុកដាក់ទៅលើចំណងអាពាហ៍ពិពាហ៍មួយនោះ វាពិតជាប្រឈមមុខខ្លាំងណាស់ ឬមួយក៏ការយល់ឃើញខុសគ្នា ឬការរំពឹងទុកផ្សេងគ្នាក៏ជាកត្តាដែលនាំឱ្យមានភាពសោះកក្រោះនោះផងដែរ។ ម្យ៉ាងទៀតប្រសិនបើករណីទាំងនោះបានកើតឡើងហើយភាគីទាំងសងខាងរឹតតែមិនសហការគ្នាក្នុងការស្វែងរកដំណោះស្រាយថែមទៀតនោះ វាពិតជាកាន់តែធ្វើឱ្យទំនាក់ទំនងនោះឃ្លាតឆ្ងាយពីគ្នាថែមទៀត។

**ឧទាហរណ៍៖** កល្យាណ និងសុខ បានរៀបការជាមួយគ្នា ដោយការផ្សំផ្គុំពីសំណាក់ឪពុកម្ដាយ ហើយចំណងអាពាហ៍ពិពាហ៍នោះកើតឡើងដោយសារតែ សុខជាអ្នកស្រឡាញ់កល្យាណតែម្នាក់ឯង។ សុខបានសន្យាថានឹងធ្វើគ្រប់យ៉ាងដើម្បីឱ្យ កល្យាណ មានសេចក្ដីសុខ និងបង្កើតគ្រួសារមួយដែលមានសុភមង្គល។ ផ្ទុយទៅវិញបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ហើយបាន ៣ឆ្នាំ អ្នកទាំងពីរមានកូនស្រីម្នាក់ តែបើមើលពីទំនាក់ទំនងចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរវិញ ហាក់កាន់តែសោះកក្រោះពីព្រោះថា សុខតែងតែចាកចេញពីផ្ទះទៅ

រកលុយ ហើយគិតតែពីរកចំណូលមកផ្គត់ផ្គង់គ្រួសារ និងមិនដែលមានពេលវេលាសម្រាប់គ្រួសារ សម្រាប់ប្រពន្ធ កូន ដែលធ្វើឱ្យ កល្យាណ និងកូន ក៏ដូចជាគ្រួសារទាំងមូលហាក់គ្មានភាពកក់ក្តៅសោះឡើយ។ ដោយគិតថាមិនអាចរស់នៅដោយមានសុភមង្គល និងសេចក្តីសុខបាន កល្យាណក៏បានដាក់ពាក្យសុំលែងលះ សុខ។

### ១.៤.៥.៧. ការប្រើប្រាស់គ្រឿងញៀន

គ្រឿងញៀន គឺជាវត្ថុខុសច្បាប់មួយស្រាប់ទៅហើយ ហើយចំពោះអ្នកដែលប្រព្រឹត្ត ការលក់ ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន គឺជាអំពើខុសច្បាប់ ដែលត្រូវបានផ្តន្ទាទោស និងពិន័យជាសាច់ប្រាក់ទៅតាមប្រភេទនឹងភាពជាក់ស្តែងនៃបទល្មើស។ លើសពីនេះទៅទៀតការប្រើប្រាស់គ្រឿងញៀនវាបានធ្វើឱ្យមានផលប៉ះពាល់ដល់ប្រព័ន្ធប្រសាទ ហើយប្រសិនបើភាគីណាម្ខាងដែលបានប្រើប្រាស់វា នោះប្រាកដណាស់ថាភាគីម្ខាងទៀតនឹងព្យាយាមធ្វើគ្រប់បែបយ៉ាងដើម្បីអាចធ្វើឱ្យខ្លួនមានលទ្ធភាពក្នុងការទៅប្រើប្រាស់គ្រឿងញៀន។ ហើយទង្វើដែលភាគីសហព័ទ្ធបានប្រព្រឹត្ត ឬធ្វើនោះវាច្បាស់ណាស់ថានឹងធ្វើឱ្យភាគីម្ខាងទៀត មិនអាចរួមរស់នៅជាមួយគ្នាប្រកបដោយសុភមង្គលបាននោះទេ ហើយសហព័ទ្ធនោះអាចដាក់ពាក្យសុំលែងលះក្នុងករណីនេះបានផងដែរ។

**ឧទាហរណ៍៖** សុខ បានរៀបការជាមួយ ពុធ ហើយពេលនោះសុខដែលជាប្តីមិនបានធ្វើការប្រើប្រាស់គ្រឿងញៀននោះទេ។ នៅពេលដែលរៀបការជាមួយគ្នាអស់រយៈពេល៣ឆ្នាំ ហើយមានកូនប្រុសម្នាក់ទើប ពុធដឹងថា សុខ បានប្រើប្រាស់គ្រឿងញៀនជាមួយបក្សពួក។ តាំងពីពេលដែលពុធបានដឹងរឿងមក សុខ កាន់តែហ៊ានប្រើប្រាស់ហិង្សា និងធ្វើគ្រប់បែបយ៉ាងដើម្បីអាចយកវត្ថុ ឬលុយពីពុធទៅដោះដូរនឹងគ្រឿងញៀន។ ដោយមិនអាចទ្រាំរស់នៅជាមួយនឹង សុខ បាន ហើយអាណិតដល់កូន ពុធក៏បានដាក់ពាក្យសុំលែងលះជាមួយសុខ។

### ១.៤.៥.៨. ញៀនស្រា និងល្បែង

ជាការពិតណាស់ ការរៀបអាពាហ៍ពិពាហ៍ គូស្វាមីទាំងពីរត្រូវតែរួបរួមគ្នា កាន់ដៃគ្នា គឺក្នុងគោលបំណងកសាងសុភមង្គល និងភាពរីកចម្រើននៅក្នុងគ្រួសារ។ ប៉ុន្តែប្រសិនបើ នៅក្នុងគ្រួសារមួយនោះប្តី គិតតែពីផឹកស៊ីដាច់យប់ ដើរលេង ហើយប្រពន្ធលែងល្បែងថែមទៀតនោះ នោះពួកគេនឹងបាត់បង់ភាពជាម្ចាស់ការលើប្រភពនៃហិរញ្ញវត្ថុ ឬចំណូលរបស់ពួកគេ ដែលនឹងបង្កជាជម្លោះទាស់ទែងនៅក្នុងគ្រួសាររបស់ពួកគេជាក់ជាមិនខាន។

**ឧទាហរណ៍៖** សៅ និងចន្ទ បានរៀបការជាមួយគ្នាហើយអ្នកទាំងពីរ បានចាប់ដៃគ្នារកស៊ីតាំងពីបាតដៃទទេរហូតដល់មានបាន។ បន្ទាប់ពីពួកគេមានជីវភាពធូរធារមក ពួកគេលែងសូវខ្វល់ពីប្រភពចំណូលទៀតហើយសៅគិតតែពីដើរផឹកស៊ី រីឯចន្ទវិញគិតតែពីលេងល្បែង ហើយអ្នកទាំងពីរក៏ចាប់ផ្តើមរស់នៅទាស់ទែងគ្នា និងមិនចុះសម្រុងគ្នាដូចមុនទេ។ លើសពីនេះទៅទៀត អ្នកទាំងពីរចាប់ផ្តើមបាត់បង់ទ្រព្យសម្បត្តិដែលបានខិតខំស្វះស្វែងរកបានមកកាលពីមុន និងរហូតដល់បាត់បង់អារម្មណ៍មនោសញ្ចេតនាជាប្តីប្រពន្ធថែមទៀតផង។

#### ១.៤.៥.៩. បញ្ហាផ្លូវភេទ( មិនសំដៅលើអពលានុភាពនៃលិង្គ ប៉ុន្តែសំដៅលើចំណង់ផ្លូវភេទរបស់ភាគី និងការសហការគ្នា)

អាពាហ៍ពិពាហ៍បង្កើតឡើងមិនមែនត្រឹមតែជាការប្រព្រឹត្តកម្មវិធីឱឡារឹក និងស្មោះត្រង់គ្នារវាងគូស្វាមីភរិយានោះទេ ប៉ុន្តែក៏ត្រូវគិតដល់អារម្មណ៍របស់គូភាគី និងបញ្ហាផ្លូវភេទផងដែរ។ គ្រួសារខ្លះពេលដែលរៀបការហើយ អាចនឹងមិនមានកូន ចំណែកឯគ្រួសារខ្លះទៀតនៅពេលដែលរៀបការហើយអាចមានកូន ក៏ប៉ុន្តែក៏មានគ្រួសារខ្លះទៀតបានប្រើប្រាស់អំពើហិង្សាផ្លូវភេទទៅលើភាគីម្ខាងទៀត ដោយសារតែចំណង់ផ្លូវភេទរបស់ខ្លួនហើយភាគីម្ខាងទៀតអាចនឹងមិនសូវមានចំណង់ផ្លូវភេទ ក៏បង្កើតបានជាជម្លោះ ឬមានអំពើផិតក្បត់ជាដើម។

**ឧទាហរណ៍៖** លោក សុខ បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកនាង ឌី។ អ្នកទាំងពីរបានរៀបការជាមួយគ្នាបានរយៈពេល១ឆ្នាំ អ្នកទាំងពីរក៏បានដាក់ពាក្យសុំលែងលះគ្នាវិញ ដោយសារតែការមិនចុះសម្រុងគ្នាលើបញ្ហាផ្លូវភេទ ដែលជាហេតុបង្កឱ្យមានជម្លោះ ការឈ្លោះប្រកែកទាស់ទែងគ្នា និងមានអំពើហិង្សាក្នុងគ្រួសារ។

### ១.៥. មូលហេតុដែលមិនអាចលែងលះបាន

ចំណងអាពាហ៍ពិពាហ៍ដែលបង្កើតឡើងដោយស្របច្បាប់ ក៏ត្រូវបានបញ្ចប់ទៅវិញដោយស្របច្បាប់ដូចគ្នា។ ជាក់ស្តែង នៅក្នុងច្បាប់បានកំណត់រួចមកហើយពីមូលហេតុនៃការលែងលះរបស់គូស្វាមីភរិយា ប៉ុន្តែជាមួយគ្នានេះ នៅក្នុងច្បាប់ក៏បានកំណត់ផងដែលពីមូលហេតុដែលមិនអាចលែងលះបាន។ បើកាលណានិយាយថា វាប្រព្រឹត្តទៅតាមច្បាប់ ឬស្របច្បាប់ ប្រាកដណាស់ថានឹងការលែងលះនោះត្រូវបានប្រព្រឹត្តឡើងដោយមានការចូលរួម ត្រួតពិនិត្យ និងវិនិច្ឆ័យដោយតុលាការ។ ដូច្នេះ មុននឹងតុលាការអនុញ្ញាតឱ្យលែងលះតុលាការគប្បីគិតគូរថ្លឹងថ្លែងឱ្យច្បាស់លាស់ប្រកបដោយវិចារណញ្ញាណអំពីផលល្អ និងប្រកបដោយវិជ្ជាជីវៈ។

#### ១.៥.១. ផ្តល់ផលប៉ះពាល់ដល់ការទ្រទ្រង់ជីវភាព ឬការឈឺចាប់របស់សហព័ទ្ធឬកូន

មុននឹងឈានដល់ការសម្រេចចិត្តធ្វើការលែងលះច្បាស់ណាស់ថា ភាគីដែលបានដាក់ពាក្យសុំប្រាកដជាមាននូវមូលហេតុ ឬមានហេតុផលច្បាស់លាស់ ក្នុងការដាក់ពាក្យសុំលែងលះនោះ ប៉ុន្តែប្រសិនបើតុលាការបានពិនិត្យឃើញថា ការលែងលះនោះមានផលប៉ះពាលខ្លាំងដល់គ្រួសារនោះទាំងមូល រួមទាំងជីវភាពក្នុងគ្រួសារ និងកូនៗ ឬក៏មានករណីខ្លះទៀតដែលធ្វើឱ្យភាគីណាម្ខាងមិនអាចទ្រាំទ្របាន នោះតុលាការអាចច្រានចោលការដាក់ពាក្យសុំលែងលះនោះបាន ដោយពិចារណាទៅលើស្ថានភាពរបស់គ្រួសារ និងសហព័ទ្ធនោះ។[១៥]

[១៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៨, កថាខណ្ឌទី២

ប្រសិនបើតុលាការយល់ព្រមអនុញ្ញាតឱ្យការលែងលះគ្នានោះកើតឡើង គឺនៅពេលដែលតុលាការបាន រកឃើញថាការលែងលះនោះកើតឡើងនឹងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គ្រួសារ ឬសហព័ទ្ធណាម្ខាង។ នោះ អាចនឹងមើលឃើញថា តុលាការហាក់ព្យាយាមដាក់បន្ទុកនៃភាពក្រីក្រលើគ្រួសារនោះ ជាពិសេសភាគីដែលខាង រងគ្រោះជាពិសេស ប្រពន្ធ និងកូន។

### ១.៥.២. ការលែងលះដោយមានគំនិតទុច្ចរិត

ទោះបីជាមូលហេតុនៃការលែងលះត្រូវបានកំណត់នៅក្នុងចំណុចដែល សហព័ទ្ធបានរស់នៅបែកបាក់ គ្នាអស់រយៈពេលជាង១ឆ្នាំ អាចដាក់ពាក្យសុំលែងលះបានក៏ពិតមែន ក៏ប៉ុន្តែចំណុចនេះភាគីដែលដាក់ពាក្យសុំ គឺត្រូវតែមិនមានគំនិតទុច្ចរិត និងទាមទារទៅតាមសុច្ចរិតភាព គឺមានន័យថា ភាគីបានដាក់ពាក្យសុំដោយហេតុ ថា គូស្វាមីរបស់ខ្លួនបានអនុវត្តន៍ផ្ទុយពីគោលបំណងអាពាហ៍ពាហ៍ ឬទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ខ្លួនត្រូវ បានបែកបាក់ និងគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាននោះទេ។ ប៉ុន្តែប្រសិនបើតុលាការ បានពិនិត្យ ឃើញថាការទាមទារនោះផ្ទុយទៅនឹងសុច្ចរិតភាព ដោយភាគីណាម្ខាងមានគោលបំណងនៅក្នុងការលែងលះ ដោយធ្វេសប្រហែលយ៉ាងខ្លាំង និងមិនសហការក្នុងការជួយសង្គ្រោះចំពោះសហព័ទ្ធរបស់ខ្លួន នោះតុលាការ អាចច្រានចោលការទាមទារការលែងលះនោះដោយឆន្ទានុសិទ្ធិ។[១៦] នៅត្រង់ចំណុចនេះបានបង្ហាញឱ្យឃើញ កាន់តែច្បាស់ពីប្រសិទ្ធិភាព និងវិសាលភាពនៃច្បាប់ ក្នុងការការពារកុំឱ្យមានជនខិលខូចមួយចំនួនតូចលើក យកនូវបញ្ហាផ្សេងៗដើម្បីលែងលះ ដើម្បីឱ្យខ្លួនអាចទទួលបាននូវផលប្រយោជន៍ផ្សេងៗពីការលែងលះនោះមក ដល់ខ្លួន ពោលគឺចង់បានផលចំណេញ និងគិតតែពីផលប្រយោជន៍របស់ខ្លួនទៅតាមភាពលោភលន់របស់ខ្លួន។

ក្រៅពីមូលហេតុនៃការលែងលះ និងមូលហេតុដែលមិនអាចលែងលះបានដូចដែលបានលើកឡើងពី ខាងលើ ដើម្បីឱ្យមានការលែងលះមួយស្របច្បាប់ គឺទាមទារនូវការប្រតិបត្តិរបស់សហព័ទ្ធនីមួយៗ ចំពោះការ អនុវត្តច្បាប់ជាធរមាន។ ម្យ៉ាងវិញទៀត គូភាគីគួរគប្បីយល់ដឹងអំពីនីតិវិធីក្នុងការលែងលះ ទើបអាចឱ្យភាគីទាំង សងខាងមានការទុកចិត្ត មានការជឿជាក់ចំពោះអានុភាពនៃសាលក្រមលែងលះ ដោយមិនចាំបាច់មានការភ័យ ព្រួយ ឬបារម្ភខ្លាចក្រែងមានទង្វើមិនគប្បីណាមួយកើតឡើងពីសំណាក់ភាគីម្ខាងទៀតឡើយ។ បើកាលណាគូ ភាគីបានដើរទៅតាមនីតិវិធីច្បាប់ហើយនោះ ច្បាប់នឹងការពារពីភាពសុចរិតដល់គូភាគីទាំងសងខាង។

**ឧទាហរណ៍៖** សុខ និងសប្បាយ បានបង្កើតចំណងអាពាហ៍ពិពាហ៍ជាមួយនឹងគ្នាកាលពីឆ្នាំ២០០៥។ ពួកគេមានកូនប្រុស ស្រី ២នាក់។ លុះដល់ឆ្នាំ២០១០ អ្នកទាំងពីរបានឈ្លោះទាស់ទែងគ្នា ដោយសារតែមាន

[១៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៨, កថាខណ្ឌទី៣

រឿងមួយចំនួននៅក្នុងគ្រួសារ ហើយក៏មានការអាក់អន់ស្រពន់ចិត្តនឹងគ្នា។ បន្ទាប់ពីមានការអន់ចិត្ត សុខបាន ចាកចេញពីផ្ទះទៅរស់នៅខេត្តផ្សេង និងប្រកបរបរនៅខេត្តផ្សេង ដោយមិនមានប្រាប់ដំណឹងមកសប្បាយឡើយ ហើយសប្បាយក៏មិនបានធ្វើការទាក់ទងទៅសុខ ដើម្បីធ្វើការស្វែងរកសុខដូចគ្នា។ បន្ទាប់ពីសុខបានចាកចេញ ពីផ្ទះអស់រយៈពេលមួយឆ្នាំកន្លះមក សុខក៏បានស្គាល់ រីករាយ ហើយក៏ចង់បង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី ជាមួយរីករាយ ប៉ុន្តែខ្លួនមិនទាន់បានបញ្ចប់ចំណងអាពាហ៍ពិពាហ៍ជាមួយនឹងសប្បាយនៅឡើយ។ ពេលនោះ សុខក៏បានដាក់ពាក្យសុំលែងលះទៅតុលាការដោយសម្អាងថា បានរស់នៅបែកគ្នាអស់រយៈពេលជាងមួយឆ្នាំ ហើយអស់មនោសញ្ចេតនាជាប្តីប្រពន្ធ និងមិនអាចធ្វើបដិទានបាន។ ប៉ុន្តែសប្បាយ មិនយល់ព្រមលែងលះនោះ ទេ ដោយហេតុថា ខ្លួនមិនទាន់អស់មនោសញ្ចេតនាជាប្តីប្រពន្ធជាមួយនឹងសុខ ព្រោះខ្លួនគ្រាន់តែឈ្លោះប្រកែក គ្នា និងអាក់អន់ស្រពន់ចិត្តនឹងគ្នា សប្បាយបានចិត្តចិញ្ចឹមកូនដែលជាអនីតិជនម្នាក់ឯងជាងមួយឆ្នាំ នៅពេល ដែលសុខមិននៅផ្ទះ ហើយសប្បាយ ក៏គ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការស្វែងរកទ្រព្យសម្បត្តិមកផ្គត់ផ្គង់គ្រួសារ ឡើយ។ ក្នុងករណីនេះ តុលាការបានធ្វើការកំណត់អំពីមូលហេតុ និងភាពច្បាស់លាស់នៃពាក្យសុំលែងលះ តុលាការបានរកឃើញថា ភាគីម្ខាងនៃសហព័ទ្ធដែលជា សុខ ដែលបានដាក់ពាក្យសុំលែងលះបានប្រព្រឹត្តផ្ទុយ នឹងភាពសុចរឹត និងមិនបានចូលរួមក្នុងការសង្គ្រោះ ឬមានការធ្វេសប្រហែលជាខ្លាំងក្នុងការសហការគ្នាក្នុងការ ជួយសង្គ្រោះសហព័ទ្ធរបស់ខ្លួន។ ក្នុងករណីនេះមានន័យថា ភាគីម្ខាងទៀតមិនបានចូលរួមក្នុងការធ្វើបដិទាន ឡើងវិញនោះទេ ហើយថែមទាំងដាក់ពាក្យសុំលែងលះ ដោយហេតុថាខ្លួនចង់បង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី។ ដូចនេះ តុលាការអាចធ្វើការច្រានចោលពាក្យសុំលែងលះរបស់សុខបាន ដោយប្រើឆន្ទានុសិទ្ធិរបស់ខ្លួន។

# ជំពូកទី ២

# ការលេងល្បែងដោយការព្រមព្រៀង

# ជំពូកទី២

# ការលែងលះដោយការព្រមព្រៀង

អាពាហ៍ពិពាហ៍ ជាសមគ្គសង្វាសស្របច្បាប់ របស់បុរសម្នាក់ និងនារីម្នាក់ដែលកើតចេញពីការប្រកាសយ៉ាងឱឡារិក ដើម្បីបង្កើតជាគ្រួសារ។ ហើយអាពាហ៍ពិពាហ៍មួយ អាចមានអានុភាពទៅបានលុះត្រាតែមានការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ការរំលាយចំណងអាពាហ៍ពិពាហ៍តាមរយៈការលែងលះដោយការព្រមព្រៀង គឺជាការលែងលះ ដែលកើតឡើងដោយឆន្ទៈ ដោយមានការព្រមព្រៀងពីគូភាគីទាំងសងខាងនៃសហព័ទ្ធក្នុងការរំលាយនូវចំណងអាពាហ៍ពិពាហ៍ ហើយការលែងលះដោយការព្រមព្រៀងនេះ គឺជាការរំលាយនូវចំណងអាពាហ៍ពិពាហ៍ដោយស្របច្បាប់របស់គូភាគី។ រឿងក្តីនៃការលែងលះដោយមានការព្រមព្រៀងមានតែគូភាគីប៉ុណ្ណោះដែលអាចដាក់ពាក្យសុំលែងលះទៅតុលាការ និងជាអ្នកចាប់ផ្តើមដំណើរការនីតិវិធីដោះស្រាយ។

តើនៅក្នុងដំណើរការនីតិវិធីនៃការលែងលះដោយមានការព្រមព្រៀង ត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះចំពោះសហព័ទ្ធ? តើការលែងលះដោយមានការព្រមព្រៀងមានអានុភាពដូចម្តេចខ្លះចំពោះសហព័ទ្ធ?

## ២.១. នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

### ២.១.១. ពាក្យសុំលែងលះ

ការលែងលះដោយការព្រមព្រៀង គឺជាការរំលាយនូវចំណងអាពាហ៍ពិពាហ៍ដោយស្របតាមឆន្ទៈពិតប្រាកដរបស់គូស្វាមីក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេដោយស្របច្បាប់។ ហើយដំណើរការនីតិវិធីនៃការលែងលះដោយមានការព្រមព្រៀងនេះ ត្រូវចាប់ផ្តើមដោយមានការដាក់ពាក្យស្នើសុំលែងលះរបស់ភាគីម្ខាងទៅតុលាការជាមុនសិន ដោយសរសេរទៅតាមទម្រង់ដែលច្បាប់បានកំណត់ បើគូភាគីមិនបានបំពេញ ឬអនុវត្តតាមទម្រង់ដែលច្បាប់បានកំណត់ និងច្បាប់បានបញ្ញត្តិទេ ពាក្យសុំដែលបានដាក់ ត្រូវឱ្យធ្វើការកែតម្រូវជាថ្មី ឬលើកពាក្យសុំចោល។ម្យ៉ាងទៀត គូភាគីដែលដាក់ពាក្យសុំអាចធ្វើជាលាយលក្ខណ៍អក្សរ ឬត្រូវធ្វើដោយផ្ទាល់មាត់ក៏បាន ក៏ប៉ុន្តែក៏មានការលើកលែងចំពោះករណីណាដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់។[១៧]

[១៧] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា ២៦, កថាខណ្ឌទី១។

#### ២.១.១.១. ពាក្យសុំលែងលះជាលាយលក្ខណ៍អក្សរ

ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬច្បាប់ផ្សេងទៀត។[១៨] នៅក្នុងលិខិតនៃការដាក់ពាក្យសុំការលែងលះដោយមានការព្រមព្រៀង ត្រូវមានសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងៗទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ។
- អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ។

#### ២.១.១.២. ពាក្យសុំលែងលះដោយផ្ទាល់មាត់

ពាក្យសុំអាចធ្វើដោយផ្ទាល់មាត់បាន ហើយដើម្បីអាចដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗដែលទាក់ទង និងបានកំណត់នៅក្នុងកថាខណ្ឌទី២ មាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០ នៅចំពោះមុខក្រឡាបញ្ជី។ ក្នុងករណីនេះក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ ចុះហត្ថលេខា ហើយកំណត់ហេតុនោះចាត់ទុកជាលិខិតពាក្យសុំរបស់ភាគី។

### ២.១.២. សមត្ថកិច្ចដោះស្រាយ

#### ២.១.២.១. ឃុំ-សង្កាត់

ភាគីអាចដាក់ពាក្យសុំលែងលះគ្នា ទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ខាងលំនៅដ្ឋាន ឬទីសំណាក់ ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ និងទី៣ នៃមាត្រា ១០(សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តីអំពីបុគ្គលភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។ នៅក្នុងករណីនេះផងដែរ ក្រុមប្រឹក្សាឃុំ-សង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នាបាន ក្នុងអំឡុងពេល១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ។ បើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ជូនពាក្យបណ្តឹងនោះ ទៅកាន់តុលាការជាបន្ទាន់។ ក្នុងករណីដែលក្រុមប្រឹក្សាឃុំ-សង្កាត់ មិនអាចសម្រេចធ្វើការផ្សះផ្សាបានទេ នោះត្រូវបញ្ជូនពាក្យសុំលែងលះទៅតុលាការមានសមត្ថកិច្ចនៅក្នុងរឿងក្តីលែងលះ។

[១៨] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា ២៦, កថាខណ្ឌទី២។

#### ២.១.២.២. សាលាដំបូងរាជធានី ខេត្ត

ពាក្យសុំលែងលះគ្នា អាចដាក់ទៅតុលាការដែលមានសមត្ថកិច្ច ដោយយោងតាមបញ្ញត្តិមាត្រា ១០ (សមត្ថកិច្ចសាលាជម្រះក្តីពិសេសលើរឿងក្តីលែងលះគ្នា និងរឿងក្តីបុត្តភាព) នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។ ហើយពាក្យសុំលែងលះនេះ មិនមែនគ្រប់តុលាការទាំងអស់សុទ្ធតែមានសមត្ថកិច្ចក្នុងការដោះស្រាយលើរឿងក្តីលែងលះនោះទេ គេត្រូវមើលទៅលើប្រភេទនៃរឿងក្តីនោះ មានន័យថា តុលាការមានសមត្ថកិច្ចត្រូវតែស្ថិតនៅលំនៅដ្ឋានរបស់ភាគីប្តី ឬប្រពន្ធ។ ជារួមមក នៅមុនពេលដាក់ពាក្យសុំលែងលះទៅតុលាការក្នុងរឿងក្តីលែងលះនេះ គូភាគីត្រូវតែបំពេញកាតព្វកិច្ច និងភារកិច្ចមួយចំនួនដែលទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណីផងដែរ។

ជាមួយគ្នានេះដែរ នៅពេលដែលតុលាការទទួលបានពាក្យសុំលែងលះរួចហើយ តុលាការនឹងធ្វើការសាកល្បងផ្សះផ្សាភាគីទាំងពីរទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាក៏ដោយ។ ប៉ុន្តែប្រសិនបើការផ្សះផ្សាពុំអាចសម្រេចបានទេ តុលាការត្រូវយកបណ្តឹងលែងលះគ្នាមកធ្វើការវិនិច្ឆ័យ ហើយធ្វើការប្រកាសសាលក្រម។[១៩]

### ២.១.៣. ដំណើរការនៃដំណោះស្រាយការលែងលះដោយការព្រមព្រៀង

នៅពេលដែលពាក្យសុំបានដាក់ជូនដល់តុលាការរួចរាល់ហើយ រដ្ឋបាលនឹងបញ្ជូនពាក្យសុំនោះបន្តទៅក្រឡាបញ្ជីដែលទទួលបន្ទុករឿងក្តីលែងលះដោយការព្រមព្រៀង នោះនីតិវិធីត្រូវបានដំណើរការជាបន្តបន្ទាប់។ ស្របពេលនេះ ក្រឡាបញ្ជីនឹងធ្វើការត្រួតពិនិត្យពាក្យសុំនោះ ហើយប្រសិនបើមានភាពត្រឹមត្រូវហើយនោះ នោះតុលាការនឹងដំណើរការដំណោះស្រាយការលែងលះដោយការព្រមព្រៀងនោះទៅតាមនីតិវិធីនៃច្បាប់។

#### ២.១.៣.១. ការកោះហៅគូភាគី

បន្ទាប់ពីក្រឡាបញ្ជីធ្វើការត្រួតពិនិត្យទៅលើពាក្យសុំរួចរាល់ និងត្រឹមត្រូវអស់ហើយ ក្រឡាបញ្ជីនឹងធ្វើការចុះសំណុំរឿងក្តីនៃការលែងលះនេះចូលទៅក្នុងបញ្ជី និងបញ្ជូនបន្តទៅចៅក្រមដែលទទួលបន្ទុកក្នុងរឿងក្តីនោះដើម្បីធ្វើការជំនុំជម្រះតាមនីតិវិធី។ ជាមួយគ្នានេះ ចៅក្រមអាចកោះហៅគូភាគី ឬជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់ ដោយកំណត់កាលបរិច្ឆេទ ដើម្បីប្រមូលព័ត៌មានអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ។[២០]

---

[១៩] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៨៥។

[២០] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា ២៩ កថាខណ្ឌទី២។

**២.១.៣.២. ការផ្សះផ្សា**

ការផ្សះផ្សា គឺជាចំណាត់ការមួយរបស់តុលាការ ដើម្បីឱ្យស្វាមីភរិយាធ្វើបដិទានឡើងវិញ។ នៅក្នុងដំណាក់កាលនៃការផ្សះផ្សានេះ គេបានឃើញថា កើតឡើងម្តងរួចមកហើយ នៅពេលដែលការលែងលះត្រូវបានដាក់ពាក្យសុំលែងលះទៅឃុំ-សង្កាត់ ។ បើទោះបីជាការផ្សះផ្សាបានកើតឡើង ឬ មិនកើតឡើងនៅពេលដែលពាក្យសុំលែងលះដាក់ទៅឃុំ-សង្កាត់ហើយក៏ដោយក៏តុលាការត្រូវតែសាកល្បងផ្សះផ្សាជាមុនសិនផងដែរ ដើម្បីឈានដល់នីតិវិធីបន្តបន្ទាប់ទៀត។

នៅក្នុងនីតិវិធីនៃការផ្សះផ្សានេះ ទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាក៏ដោយតុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន។ ហើយប្រសិនបើការផ្សះផ្សាពុំអាចសម្រេចបានទេតុលាការត្រូវយកបណ្តឹងលែងលះគ្នា មកធ្វើការវិនិច្ឆ័យ ហើយធ្វើការប្រកាសសាលក្រម។[២១]មានន័យថា ទោះបីជាភាគីទាំងសងខាងព្រមព្រៀងក្នុងការលែងលះ ឬបង្ហាញឆន្ទៈក្នុងការលែងលះក៏ដោយ ក៏តុលាការត្រូវព្យាយាមក្នុងការសម្របសម្រួល បញ្ចុះបញ្ចូល និងផ្សះផ្សាគូស្វាមីភរិយានោះជាមុនសិន។

**២.១.៣.៣. នីតិវិធីនៃការសាកសួរ**

នីតិវិធីនៃការសាកសួរ ត្រូវបានកើតឡើងបន្ទាប់ពីនីតិវិធីនៃការផ្សះផ្សា មានន័យថាការសាកសួរ ត្រូវបានកើតឡើងបន្ទាប់ពីតុលាការបានធ្វើការសាកល្បងក្នុងការផ្សះផ្សា។ នីតិវិធីនៃការសាកសួរនេះ គឺធ្វើឡើងដើម្បីឱ្យភាគីទាំងសងខាងបញ្ជាក់ពីឆន្ទៈរបស់ខ្លួនបន្ទាប់ពីបានឆ្លងកាត់ការសាកល្បងផ្សះផ្សារួចមក។ ចំពោះនៅត្រង់ចំណុចនេះ តុលាការអាចយកអង្គហេតុដែលអ្នកដាក់ពាក្យសុំលែងលះ និងភាគីម្ខាងទៀតមិនបានអះអាងមកធ្វើជាមូលហេតុនៃដីកាសម្រេចបាន។[២២]

## ២.២. ការសម្រេចសេចក្តី

### ២.២.១. អំពីដីកាសម្រេចតាមពាក្យសុំ

ក្នុងករណីដែលតុលាការបានព្យាយាមធ្វើការផ្សះផ្សារួចហើយ ប៉ុន្តែនៅតែមិនទទួលបានផលល្អ ហើយគូភាគីទាំងសងខាងនៅតែទាមទារក្នុងការលែងលះ ដូចនេះតុលាការអាចយកអង្គហេតុដែលមិនបានអះអាង

[២១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៨៤។

[២២] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា ២៧, កថាខណ្ឌទី២។

ដោយអ្នកដែលដាក់ពាក្យសុំ ឬដោយភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីការសម្រេចបាន។[២៣] ម្យ៉ាងវិញទៀត ដើម្បីចេញដីការសម្រេចនេះ តុលាការពុំចាំបាច់ការឆ្លងកាត់ការទាយយកហេតុផលដោយផ្ទាល់មាត់នោះទេ ហើយនៅក្នុងករណីដែលមិនអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន តុលាការអាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់បាន។[២៤] ក្រៅពីនេះតុលាការក៏ត្រូវពិនិត្យ ដោយមើលផងដែរថាតើ ការលែងលះនោះកើតចេញដោយឆន្ទៈពិតប្រាកដរបស់គូភាគីដែរឬទេ ហើយប្រសិនបើ ស្របតាមឆន្ទៈ នោះតុលាការអាចសម្រេចឱ្យគូភាគីលែងលះគ្នាបាន ផ្ទុយទៅវិញប្រសិនបើមិនស្របតាមឆន្ទៈ របស់គូភាគីទេនោះ តុលាការនឹងមិនអនុញ្ញាតឱ្យគូភាគីធ្វើការលែងលះគ្នាឡើយ។[២៥]

### ២.២.២. ការជូនដំណឹងអំពីដីការសម្រេច

ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់ នេះ ត្រូវជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេចនេះ។ ការជូនដំណឹងអំពីដីកាសម្រេចនេះត្រូវធ្វើឡើងតាម រយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីការសម្រេចនោះ។[២៦] ការជូនដំណឹងនេះមិនត្រូវចាំបាច់ ឱ្យក្រឡាបញ្ជីត្រូវប្រគល់ដោយផ្ទាល់ទេ ហើយក្រឡាបញ្ជីអាចធ្វើឡើងតាមរយៈប្រៃសណីយ៍ធម្មតាក៏បានដែរ។

### ២.២.៣. ការចូលជាស្ថាពរនៃដីកាសម្រេច

ដីកាសម្រេចមិនចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់នោះទេ ហើយដីកា សម្រេចមិនមានអានុភាពឡើយ បើសិនមិនទាន់ចូលជាស្ថាពរទេនោះ។[២៧] ប្រសិនបើជនដែលអាចប្តឹងជំទាស់ បានទទួលការជូនដំណឹងអំពីដីកាសម្រេច បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយ គិតចាប់ពីថ្ងៃដែលបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ។ អំឡុងពេលនៃបណ្តឹងជំទាស់ពុំអាចពន្យា

[២៣] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា ២៧, កថាខណ្ឌទី១។

[២៤] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា ២៨។

[២៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៣។

[26] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា ៣៦។

[27] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា ៣៧, កថាខណ្ឌទី១ និងកថាខណ្ឌទី៣។

បានឡើយ។[២៨] ក្នុងករណីដែលគ្មានបណ្តឹងទាស់ទេ នោះដីកាសម្រេចលែងលះដោយការព្រមព្រៀងនឹងចូលជាស្ថាពរ។

[២៨] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា ៤០, កថាខណ្ឌទី១ និងកថាខណ្ឌទី៤។

# ជំពូកទី៣

# ការលេងលះដោយគ្មានការព្រមព្រៀង

# ជំពូកទី ៣

# ការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដោយគ្មានការព្រមព្រៀង ឬជាការលែងលះតាមពាក្យបណ្តឹងលែងលះ គឺជាការទាមទារលែងលះដោយឯកតោភាគី ពោលគឺភាគីណាមួយដែលជាសហព័ទ្ធ ប្តី ឬប្រពន្ធ មានបំណងពិតប្រាកដក្នុងការចង់ផ្តាច់ចំណងអាពាហ៍ពិពាហ៍ ដោយភាគីម្ខាងមិនបានធ្វើការព្រមព្រៀងគ្នាអំពីសិទ្ធិ និងកាតព្វកិច្ចផ្សេងៗ។ នៅពេលដែលមានការលែងលះ ឬដោយផ្អែកលើមូលហេតុត្រឹមត្រូវ ឬការរស់នៅជាមួយគ្នាពុំមានសុភមង្គលនោះ អាចដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ចដើម្បីសុំលែងលះ។ ការលែងលះដោយគ្មានការព្រមព្រៀង គឺស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ហើយត្រូវឆ្លងកាត់ដំណាក់កាលនីតិវិធីរដ្ឋប្បវេណីជាច្រើន ដែលធ្វើឱ្យការលែងលះដោយគ្មានការព្រមព្រៀងប្រើរយៈពេលយូរ។

## ៣.១. នីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀង

### ៣.១.១. ការផ្តើមនៃបណ្តឹងលែងលះ

ដំណើរការនៃការលែងលះដោយគ្មានការព្រមព្រៀង ចាប់ផ្តើមនៅពេលដែលសហព័ទ្ធណាម្នាក់បានដាក់ពាក្យសុំប្តឹងលែងលះ ដោយអនុលោមទៅតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០ និងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ បណ្តឹង គឺជាឯកសារផ្លូវច្បាប់ដែលភាគីម្ខាងបានដាក់ ក្នុងគោលបំណងប្រឆាំងនឹងភាគីម្ខាងទៀតដែលបានថ្លែងកើតទុក្ខមិនសុខចិត្ត និងដើម្បីឱ្យប្រព័ន្ធច្បាប់ជួយធ្វើការដោះស្រាយ។ ដើម្បីដោះស្រាយ និងសម្រេចបានត្រឹមត្រូវតាមច្បាប់ ករណីនៃការលែងលះគ្នានៃការរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមលក្ខណៈច្បាប់ ភាគីត្រូវដាក់ពាក្យប្តឹង និងត្រូវដោះស្រាយតាមផ្លូវតុលាការ ចំណែកការរៀបអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ តុលាការមិនទទួលការដោះស្រាយបណ្តឹងលែងលះគ្នាឡើយ ដែលជាហេតុធ្វើឱ្យមានផលវិបាកមួយចំនួន។[២៩] ភាគីណាមួយដែលសុំប្តឹងលែងលះត្រូវភ្ជាប់មកជាមួយនឹងឯកសារ និងភស្តុតាងដែលពាក់ព័ន្ធផ្សេងៗ ដើម្បីដំណើរការនីតិវិធីនៃការប្តឹងលែងលះ និងមានដំណើរការដូចខាងក្រោម។

### ៣.១.២. ការសរសេរពាក្យបណ្តឹង

ពាក្យបណ្តឹងលែងលះ គឺត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានការរៀបរាប់អំពីមូលហេតុ ឬហេតុផលត្រឹមត្រូវ និងពិតប្រាកដ ដែលសហព័ទ្ធណាម្ខាងបានស្នើសុំលែងលះ ហើយត្រូវតែចុះហត្ថលេខា

[២៩] បណ្ឌិត ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍,ទំព័រទី ២០៨, ភាគ ១, បោះពុម្ពឆ្នាំ២០២១។

ដោយសហព័ទ្ធដែលជាអ្នកប្តឹង។ ការប្តឹង ត្រូវធ្វើដោយដាក់ពាក្យបណ្តឹង ជាលាយលក្ខណ៍អក្សរទៅតុលាការ។ យោងតាមបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ពីព្រោះថាចំណងអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធ មិនមែនជាកិច្ចសន្យាធម្មតានោះទេ ពោលវាគឺជាកិច្ចសន្យាមួយដ៏ឱឡារិក ដែលធ្វើឡើងដោយប្តីប្រពន្ធតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយបានតាមទំនើងចិត្តរបស់ខ្លួនបានឡើយ។ ហេតុដូច្នេះបណ្តឹងលែងលះចាំបាច់ត្រូវតែដោះស្រាយតាមរយៈតុលាការដែលមានសមត្ថកិច្ច ដោយភាគីដែលជាដើមចោទត្រូវដាក់ពាក្យបណ្តឹងទៅកាន់តុលាការ ដែលមានសមត្ថកិច្ចគឺតុលាការនៅទីលំនៅឋានរបស់សហព័ទ្ធណាម្ខាង។[៣០]

នៅក្នុងលិខិតសម្រាប់សរសេរពាក្យបណ្តឹង គូភាគីត្រូវសរសេរបញ្ជាក់នូវចំណុច ដូចខាងក្រោមនេះ៖

- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋាន របស់ភាគី ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- ខ្លឹមសារ នៃសាលក្រម ដើមចោទ ទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់
- ដើម្បីដាក់ពាក្យបណ្តឹងសុំលែងលះ ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុ ដែលជាមូលហេតុនៃការទាមទារលែងលះ និងតាមចំណុចដែលត្រូវសរសេរបញ្ជាក់ភស្តុតាង គឺគប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុ ជាមូលហេតុនៃការទាមទារ និងភស្តុតាង។
- ពាក្យបណ្តឹងសុំលែងលះគ្នា ដែលមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួនត្រូវបានចាត់ទុកជាឯកសារត្រៀមផងដែរ។

### ៣.១.៣ ទីកន្លែងដាក់ពាក្យបណ្តឹង និងការបង់ពន្ធ

អាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់ គឺមានទីកន្លែងដាក់ពាក្យបណ្តឹងពីរ ដើម្បីឱ្យគូភាគីជ្រើសរើសដាក់ពាក្យប្តឹងសុំលែងលះ។ ភាគីដើមបណ្តឹងអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅកាន់តុលាការរាជធានី ឬខេត្តខាងលំនៅឋានរបស់ភាគីចុងចម្លើយ ឬក៏ភាគីដើមចោទអាចដាក់ពាក្យប្តឹងជាមួយនឹងមេឃុំ ឬចៅសង្កាត់ខាងលំនៅឋានរបស់ភាគីចុងចម្លើយក៏បាន។ ក្នុងករណីដែលភាគីចុងចម្លើយមិនមានលំនៅឋាន ឬមានលំនៅឋានមិនពិតប្រាកដនៅក្នុងប្រទេសកម្ពុជា អាចប្តឹងនៅទីសំណាក់របស់ភាគីចុងចម្លើយ។ នៅក្នុងករណីដែលមិនមានទីសំណាក់ ឬមានទីសំណាក់មិនពិតប្រាកដនោះទេ គេអាចប្តឹងនៅលំនៅឋានចុងក្រោយរបស់ភាគីចុងចោទ

[៣០] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, មាត្រា ៥។

នោះតែម្តង។[៣១] នៅក្នុងករណីដែលលំនៅឋានរបស់គូភាគីមិនស្ថិតនៅក្នុងប្រទេសកម្ពុជាទេ ឬលំនៅឋាននៅប្រទេសកម្ពុជាមិនពិតប្រាកដទេ តុលាការដែលមានសមត្ថកិច្ចជម្រះក្តីជាអ្នកកំណត់តាមទីសំណាក់របស់ភាគីចុងចម្លើយ។ ប្រសិនបើពុំមានទីសំណាក់ ឬទីសំណាក់មិនពិតប្រាកដទេ នោះតុលាការត្រូវតែកំណត់ទៅតាមលំនៅឋានចុងក្រោយ។[៣២] ហេតុផលនៃតម្រូវការទាំងអស់នេះ គឺដើម្បីធានាឱ្យបានថាចុងចម្លើយនឹងបានទទួលការជូនដំណឹង ឬបានដឹងថាប្តី ឬប្រពន្ធរបស់ពួកគេបានដាក់ពាក្យប្តឹងសុំលែងលះទៅលើរូបគេហើយ។

**ឧទាហរណ៍៖** បុរស ក និងនារី ខ ជាប្តីប្រពន្ធនឹងគ្នា។ អ្នកទាំងពីរមានលំនៅឋានក្នុងរាជធានីភ្នំពេញ។ ប៉ុន្តែ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានរយៈពេល២ឆ្នាំកន្លងផុតទៅ បុរស ក បានចុះចេញពីផ្ទះទៅរស់នៅជាមួយនឹងឪពុកម្តាយរបស់គាត់វិញគឺនៅឯខេត្តពោធិ៍សាត់ ក្រោយពីមានទំនាស់ជាមួយនឹងប្រពន្ធរបស់ខ្លួន។ ឧបមាថា នារី ខ មានបំណងចង់ប្តឹងលែងលះបុរស ខដែលជាប្តី ដូច្នេះ នារី ខ អាចដាក់ពាក្យបណ្តឹងសុំលែងលះនៅសាលាដំបូងរាជធានីភ្នំពេញក៏បាន ឬនៅសាលាដំបូងខេត្តពោធិ៍សាត់ក៏បានដែរ។

ការដាក់ពាក្យបណ្តឹង ឬសិទ្ធិក្នុងការធ្វើពាក្យបណ្តឹងលែងលះគឺមានតែសហព័ទ្ធទាំងពីរប៉ុណ្ណោះ ដែលមានសិទ្ធិ ហើយតតិយជនពុំអាចធ្វើបណ្តឹង ឬធ្វើជាតំណាងឱ្យសហព័ទ្ធណាមួយដូចបណ្តឹងរដ្ឋប្បវេណីដទៃទៀតទេ ប៉ុន្តែសហព័ទ្ធអាចមកធ្វើការពឹងពាក់មេធាវីឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិរបស់ខ្លួនបានផងដែរ។

នៅពេលដែលដាក់ពាក្យបណ្តឹង ត្រូវបង់ពន្ធលើពាក្យបណ្តឹង ដែលមានចំនួនទឹកប្រាក់ដោយគណនាតាមតម្លៃនៃបណ្តឹងដែលបានកំណត់ដោយច្បាប់។[៣៣] ការគណនាពន្ធលើពាក្យបណ្តឹង គឺយកតម្លៃនៃកម្មវត្ថុនៃបណ្តឹងមកធ្វើជាមូលដ្ឋានដើម្បីធ្វើការគណនា[៣៤] ប៉ុន្តែដោយសារបណ្តឹងលែងលះ គឺជាប្រភេទនៃកម្មវត្ថុបណ្តឹងដែលទាមទារច្រើនចំណុច និងមានការពិបាកក្នុងការគណនាតម្លៃ ហេតុនេះតុលាការ ត្រូវកំណត់តម្លៃនោះដោយឆន្ទានុសិទ្ធិសមហេតុផល នោះត្រូវចាត់ទុកថាកម្មវត្ថុបណ្តឹងមានចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀលដែលដើមចោទត្រូវបង់ពន្ធលើពាក្យបណ្តឹងលែងលះនោះ ចំនួន ៥៥.០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល។[៣៥]

ចំពោះការបង់ពន្ធ ត្រូវធ្វើដោយការបង់ជាប្រាក់ នៅកន្លែងទទួលពាក្យ នៅតុលាការ។

[៣១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៨។

[៣២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១០។

[៣៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៦១, កថាខណ្ឌទី១។

[៣៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៦១។

[៣៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៦០។

ចំពោះពាក្យសុំដែលមិនបានបង់ពន្ធ នៅពេលដែលដាក់ទេ ត្រូវចាត់ទុកថាជាពាក្យសុំមិនស្របច្បាប់។ ដោយយោងទៅតាមពាក្យសុ របស់អ្នកដែលបានបង់ តុលាការនឹងត្រូវសងនូវពន្ធក្នុងៈ

- ករណីដែល បង់ពន្ធលើស សងពន្ធដែលបានបង់លើសទៅវិញ។
- ករណីដែលការផ្សះផ្សាបានលទ្ធផល មុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅករណីដែលដកពាក្យបណ្តឹងមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង និងករណីដែលសេចក្តីសម្រេចលើកចោលពាក្យបណ្តឹង ដោយមិនឆ្លងកាត់ការទាញហេតុផលចូលជាស្ថាពរត្រូវសងពាក់កណ្តាលនៃពន្ធដែលបានបង់ទៅវិញ។[៣៦]

### ៣.១.៤. ការទទួលពាក្យបណ្តឹង

នៅពេលដែលសហព័ទ្ធណាម្ខាង បានដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីចាប់ផ្តើមនីតិវិធីនៃបណ្តឹងនោះក្រឡាបញ្ជីដែលទទួលបន្ទុកក្នុងការទទួលពាក្យបណ្តឹង ត្រូវបោះត្រា ដែលបានបញ្ជាក់ថ្ងៃ ខែ ឆ្នាំ ដែលទទួលពាក្យបណ្តឹងនោះ ដើម្បីបញ្ជាក់ឱ្យដឹងច្បាស់លាស់ថា បណ្តឹងនោះត្រូវបានដាក់ពេលណា ហើយត្រូវធ្វើសំណុំរឿងនៃបណ្តឹងនោះដោយបន្ថែមក្រប ព្រមទាំងចុះលេខបណ្តឹងជាដើមថែមទៀត។ បន្ទាប់មកក្រឡាបញ្ជីត្រូវបែងចែកសំណុំរឿងនៃបណ្តឹងនោះទៅឱ្យចៅក្រមដែលត្រូវទទួលបន្ទុកនូវរឿងក្តីនោះ ទៅតាមលំដាប់នៃការបែងចែករឿងក្តី ដែលកំណត់ប្រចាំឆ្នាំជាមុនដោយប្រធានតុលាការ។ បន្ថែមពីនេះទៅទៀត គេបានអនុញ្ញាតឱ្យក្រឡាបញ្ជីមានយោបល់ចំពោះបញ្ហានៃការខ្វះខាតបានក្នុងការពន្យល់ ណែនាំ និងការផ្តល់យោបល់ខ្លះៗដល់អ្នកដែលបានដាក់ពាក្យបណ្តឹង ដើម្បីជៀសវាងពាក្យបណ្តឹងមានលក្ខណៈខ្វះខាតនូវចំណុចផ្សេងៗដូចជាឈ្មោះរបស់ភាគី អាសយដ្ឋានមិនច្បាស់លាស់ មូលហេតុមិនត្រឹមត្រូវ គ្មានភស្តុតាង គឺផ្អែកនឹងកថាខណ្ឌទី២ នៃមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីជៀសវាងការយឺតយ៉ាវដំណើរការនៃនីតិវិធីការលែងលះនេះ។

ប្រសិនបើចៅក្រមនោះមានធុរៈដោយមិនអាចចាត់ការបណ្តឹងនោះបានទេ ត្រូវតែបែងចែកទៅឱ្យចៅក្រមផ្សេងទៀត ទៅតាមលំដាប់សម្រាប់ជំនួសដែលត្រូវបានកំណត់ជាមុនដោយប្រធានតុលាការ។ លំដាប់នេះ អាចប្តូរបាននៅពាក់កណ្តាលឆ្នាំដោយដីកាសម្រេចរបស់ប្រធានតុលាការ លុះត្រាតែមានមូលហេតុដែលពុំអាចជៀសវាងបាន។[៣៧]

[៣៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៦១។

[៣៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ២៦។

### ៣.១.៥. ការពិនិត្យពាក្យបណ្តឹង និងការបញ្ជូនពាក្យបណ្តឹង

នៅពេលដែលចៅក្រម ដែលទទួលនូវការបែងចែករឿងក្តីពីក្រឡាបញ្ជី ចៅក្រមត្រូវពិនិត្យមើលថាតើក្នុងពាក្យបណ្តឹងនោះ មានសរសេរនូវចំណុចដែលចាំបាច់ត្រូវសរសេរ ព្រមទាំងតើសហព័ទ្ធដើមចោទបានបង់ពន្ធសម្រាប់ការដាក់ពាក្យបណ្តឹងដែរឬទេ? ការពិនិត្យនេះ គឺជាការពិនិត្យស្តីអំពីភាពស្រប ឬមិនស្របនឹងលក្ខខណ្ឌនៃទម្រង់តែប៉ុណ្ណោះ ហើយមិនអនុញ្ញាតឱ្យពិនិត្យមើលថាតើស្របនឹងលក្ខខណ្ឌផលប្រយោជន៍នៃបណ្តឹង ឬក៏ការទាមទារតាមផ្លូវបណ្តឹងនោះមានមូលហេតុត្រឹមត្រូវដែរឬទេ?

ក្នុងករណីដែលមានការកង្វះខាតទៅលើចំណុចណាមួយនៃលក្ខខណ្ឌទម្រង់ ឬករណីដែលមិនទាន់បង់ពន្ធ ឬកង្វះពន្ធដែលត្រូវបង់នោះចៅក្រមត្រូវបង្គាប់ឱ្យកែតម្រូវដោយកំណត់អំឡុងពេលសមរម្យមួយ។ ក្នុងករណីដែលសហព័ទ្ធដើមចោទមិនបានកែតម្រូវតាមការបង្គាប់ឱ្យកែតម្រូវទេ នោះតុលាការត្រូវលើកបណ្តឹងចោលតាមដីកាសម្រេច។[៣៨]

ក្រោយពីតុលាការបានពិនិត្យពាក្យបណ្តឹងលែងលះរួចហើយ តុលាការយល់ឃើញថាលើពាក្យបណ្តឹងលែងលះនោះ ត្រឹមត្រូវតាមទម្រង់គ្រប់គ្រាន់ហើយតុលាការត្រូវបញ្ជូនពាក្យបណ្តឹងទៅសហព័ទ្ធចុងចម្លើយជាចាំបាច់[៣៩] ព្រោះថា ការបញ្ជូនពាក្យបណ្តឹងនេះ គឺជាការផ្តល់ឱកាសឱ្យភាគីម្ខាងទៀតបានដឹងអំពីបណ្តឹងថា តើបុគ្គលណាជាអ្នកប្តឹងកម្មវត្ថុបណ្តឹងគឺជាអ្វីហើយវាក៏ជាឱកាសឱ្យសហព័ទ្ធចុងចម្លើយឆ្លើយដោះសារ និងរៀបចំមធ្យោបាយសម្រាប់ការពារខ្លួនផងដែរ។ បន្ថែមពីនេះ ដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹង ត្រូវទាមទារឱ្យសហព័ទ្ធដើមចោទត្រៀមនូវឯកសារចម្លងនៃពាក្យបណ្តឹងលែងលះនោះទៅតាមចំនួន ដែលត្រូវការតាមចំនួននៃសហព័ទ្ធចុងចម្លើយ ហើយត្រូវបញ្ជូនឯកសារចម្លងនៃពាក្យបណ្តឹងនោះទៅឱ្យសហព័ទ្ធចុងចម្លើយ។

ក្នុងករណីដែលមិនអាចធ្វើការបញ្ជូនបានទេ ដោយសារតែអាសយដ្ឋានរបស់សហព័ទ្ធចុងចម្លើយដែលមានសរសេរក្នុងពាក្យបណ្តឹងលែងលះគ្នានោះមិនត្រឹមត្រូវ នោះតុលាការត្រូវបង្គាប់ឱ្យធ្វើការកែតម្រូវឡើងវិញដោយកំណត់អំឡុងពេលដើម្បីកែតម្រូវដូចក្នុងករណីដែលមានកង្វះក្នុងការសរសេរពាក្យបណ្តឹង ឬក្នុងករណីដែលសហព័ទ្ធដើមចោទមិនបានធ្វើការបង់សោហ៊ុយចាំបាច់ជាមុន សម្រាប់ធ្វើការបញ្ជូនពាក្យបណ្តឹងលែងលះ។[៤០] ម្យ៉ាងទៀត ទោះបីជាសហព័ទ្ធដើមចោទបានខំប្រឹងប្រែងស្រាវជ្រាវរកអាសយដ្ឋាន លំនៅឋាន ឬទី

[៣៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៧៨។

[៣៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៧៩, កថាខណ្ឌទី១។

[៤០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៧៩។

កន្លែងផ្សេងទៀត ដើម្បីធ្វើការបញ្ជូនពាក្យបណ្ដឹងក៏ដោយ តែរកមិនឃើញទេ សហព័ទ្ធដើមចោទអាចដាក់ពាក្យបណ្ដឹងសុំឱ្យធ្វើការបញ្ជូនតាមរយៈការផ្សាយជាសាធារណៈបាន ក្រោយពីបានការអនុញ្ញាតពីតុលាការ។[៤១]

ការបញ្ជូនពាក្យបណ្ដឹងដល់សហព័ទ្ធចុងចម្លើយបង្កើតឱ្យមានទំនាក់ទំនងគតិយុត្ត រវាងសហព័ទ្ធដើមចោទ សហព័ទ្ធចុងចម្លើយ និងតុលាការ ហើយសហព័ទ្ធចុងចម្លើយនឹងក្លាយជាប្រធាននៃនីតិវិធីនៃបណ្ដឹង។

### ៣.១.៦. ការផ្សះផ្សា

ជាទូទៅ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបានទោះបីជាបណ្ដឹងនោះស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។[៤២] បើទោះបីជាភាគីណាម្ខាងទាមទារយ៉ាងខ្លាំងចំពោះការលែងលះគ្នាក៏ដោយ ក៏តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន។[៤៣] ក្រោយពេល ដែលក្រុមប្រឹក្សាឃុំ-សង្កាត់ ឬតុលាការបានទទួលពាក្យបណ្ដឹងជាផ្លូវការដែលសហព័ទ្ធទាំងពីរទាមទារលែងលះគ្នាហើយ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងតុលាការត្រូវមាននីតិវិធីសំខាន់មួយគឺធ្វើការផ្សះផ្សា។ ការផ្សះផ្សាត្រូវធ្វើឡើងដោយមានការដាក់កំហិតយ៉ាងតឹងរឹងស្រមតាមឆន្ទៈសេរីរបស់ភាគីទាំងពីរ ដូច្នេះមានន័យថាត្រូវធ្វើឡើងតាមការស្ម័គ្រចិត្តជាដាច់ខាត។

ការផ្សះផ្សា គឺជាអំពើរបស់ប្ដីប្រពន្ធជាដើមចោទក្នុងរឿងលែងលះ ឬបំបែកសមគ្គសង្វាស ដែលសុខចិត្តលើកលែងកំហុសឱ្យសហព័ទ្ធរបស់ខ្លួន ហើយសុខចិត្តរួមរស់ជាមួយគ្នាបន្តទៅទៀត។ ការផ្សះផ្សាបានសម្រេចនាំឱ្យបញ្ចប់នីតិវិធីប្ដឹងផ្ដល់។ ការផ្សះផ្សាទោះបីជាមានសេចក្ដីសម្រេចឱ្យបំបែកសមគ្គសង្វាសពីគ្នារួចទៅហើយក៏ដោយអាចនៅតែធ្វើទៅបានដដែល ចំណែកឯអាពាហ៍ពិពាហ៍គឺនៅគង់វង្សគ្រប់លក្ខណៈ។ ម្យ៉ាងវិញទៀតនោះ ការផ្សះផ្សា គឺជាវិធានការចាត់ចែងការងាររបស់តុលាការដើម្បីសម្រុះសម្រួលបញ្ចុះបញ្ចូលឱ្យសហព័ទ្ធទាំងពីរព្រមព្រៀងសះជានឹងគ្នា រួមរស់នៅជាមួយគ្នាជាប្ដី ប្រពន្ធប្រកបដោយសេចក្ដីសុខ សុភមង្គលដូចដើមវិញ។

## ៣.២. សមត្ថកិច្ចដោះស្រាយ

នៅក្នុងរឿងអាពាហ៍ពិពាហ៍ សហព័ទ្ធដែលមានបំណងចង់លែងលះគ្នាត្រូវដាក់ពាក្យបណ្ដឹងលែងលះគ្នាទៅសមត្ថកិច្ចក្រុមប្រឹក្សាឃុំ-សង្កាត់ ឬតុលាការដែលមានសមត្ថកិច្ច(សាលាដំបូង រាជធានី ខេត្ត )។

---

[៤១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ២៥៥, កថាខណ្ឌទី១, ចំណុច ក។

[៤២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៩៧។

[៤៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៨៤, កថាខណ្ឌទី១។

### ៣.២.១. សមត្ថកិច្ចរបស់ឃុំ ឬសង្កាត់

ក្រុមប្រឹក្សាឃុំ-សង្កាត់ អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជានឹងគ្នាបានក្នុងអំឡុងពេល១៥ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹងសុំនោះ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើការជូនដំណឹងទៅដល់សហព័ទ្ធទាំងសងខាងដើម្បីចូលខ្លួនមកធ្វើការរៀបរាប់អំពីមូលហេតុដែលខ្លួនសុំលែងលះគ្នា ឬវិបត្តិនានាដែលនាំឱ្យមានការកាត់ផ្តាច់នូវចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។ នៅក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវប្រើប្រាស់យុទ្ធសាស្ត្រគ្រប់បែបយ៉ាងរបស់ខ្លួន គឺដើម្បីធ្វើការផ្សះផ្សា និងបញ្ចុះបញ្ចូលឱ្យសហព័ទ្ធទាំងពីរសះជានឹងគ្នាវិញនោះ ក្រុមប្រឹក្សាឃុំ-សង្កាត់ពុំចាំបាច់បញ្ជូនពាក្យបណ្តឹងសុំលែងលះគ្នាទៅតុលាការនោះទេ។ ផ្ទុយទៅវិញ ប្រសិនបើក្រុមប្រឹក្សាឃុំ-សង្កាត់ មិនអាចបញ្ចុះបញ្ចូលឱ្យសះជានឹងគ្នាបានទេនោះ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជូនពាក្យបណ្តឹងសុំលែងលះនោះ ទៅតុលាការជាបន្ទាន់។[៤៤]

### ៣.២.២. សមត្ថកិច្ចរបស់តុលាការ

ក្រោយពេលដែលក្រុមប្រឹក្សាឃុំ-សង្កាត់បានខិតខំប្រើប្រាស់យុទ្ធសាស្ត្រនានាគ្រប់បែបយ៉ាងដើម្បីធ្វើការបញ្ចុះបញ្ចូលផ្សះផ្សាឱ្យសហព័ទ្ធទាំងពីរសះជានឹងគ្នាវិញ។ ប៉ុន្តែប្រសិនបើការផ្សះផ្សានោះមិនបានសម្រេចផល ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូនពាក្យបណ្តឹងសុំលែងលះគ្នាទៅតុលាការដែលមានសមត្ថកិច្ច។ តុលាការមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្តឹងវិនិច្ឆ័យលើរឿងក្តី ហើយចេញសាលក្រម ឬសាលដីកាបាន។[៤៥]

បន្ទាប់ពីតុលាការទទួលពាក្យបណ្តឹងដោយផ្ទាល់ពីភាគី ឬតាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់ តុលាការនឹងចេញដីកាជូនដំណឹងជាផ្លូវការមួយឱ្យដើមចោទចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ប្រសិនបើជាការគួរតុលាការនឹងសាកល្បងបញ្ចុះបញ្ចូលដើមបណ្តឹងឱ្យឈប់ប្តឹង។[៤៦] ប្រសិនបើដើមចោទនៅតែទទូចសុំលែងលះតុលាការត្រូវចេញសេចក្តីជូនដំណឹងផ្លូវការមួយអញ្ជើញប្តីប្រពន្ធ ឱ្យមកបង្ហាញខ្លួននៅតុលាការដើម្បីធ្វើការផ្សះផ្សានៅថ្ងៃកំណត់ណាមួយ។[៤៧] ប្រសិនបើសហព័ទ្ធទាំងពីរ មិនបានព្រមព្រៀងបន្តការរួមរស់ជាមួយគ្នាទៀតបន្ទាប់ពីការសាកល្បងផ្សះផ្សាលើកទី១មក តុលាការអាចសាកល្បងផ្សះផ្សាសហព័ទ្ធទាំងនោះជាលើកទីពីរ។

---

[៤៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៨២។

[៤៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៧។

[៤៦] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា ៤៣។

[៤៧] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា ៤៥។

ការផ្សះផ្សាម្តងៗឱ្យឃ្លាតពីគ្នា១ខែយ៉ាងឆាប់ និង២ខែយ៉ាងយូរ។[៤៨] នៅរាល់ពេលផ្សះផ្សាគ្រប់លើកតុលាការត្រូវកត់ត្រានៅកំណត់ត្រាផ្សះផ្សា ទោះបីជាភាគីទាំងនោះយល់ព្រម ឬមិនយល់ព្រមសះជាក៏ដោយ។ ទោះបីជាច្បាប់ចែងថា តុលាការត្រូវសាកល្បងផ្សះផ្សាតែពីរលើកក៏ដោយ ក្នុងការអនុវត្តជួនកាលតុលាការធ្វើការផ្សះផ្សាលើសពីពីរដង។ មេធាវីរបស់ភាគីទាំងពីរមិនត្រូវបានអនុញ្ញាតឱ្យចូលរួមស្តាប់ក្នុងការផ្សះផ្សានោះទេ។[៤៩]

## ៣.៣. វិធានការចាត់ចែងរក្សាការពារ

ពេលខ្លះដើម្បីបានការលែងលះគ្នា គឺត្រូវការពេលវេលាមួយយ៉ាងវែង ជាពិសេសគឺនៅពេលមានការសាកល្បងជាច្រើនលើកដើម្បីផ្សះផ្សាសហព័ទ្ធទាំងនោះ។ នៅពេលមានករណីខ្លះដូច្នេះតុលាការ អាចនឹងចេញវិធានការបណ្តោះអាសន្ន «វិធានការចាត់ចែងរក្សាការពារ» ដើម្បីដោះស្រាយបញ្ហាខ្លះរវាងសហព័ទ្ធនោះក្នុងពេលដែលគេរង់ចាំសាលក្រមស្ថាពរនៃការលែងលះ។ វិធានការនេះ គឺជាការណែនាំ ឬបញ្ជាដែលតុលាការបង្គាប់ទៅភាគីទាំងអស់ដែលតុលាការត្រូវចុះក្នុងកំណត់ត្រារបស់តុលាការ។ វិធានការនេះមានលក្ខណៈបណ្តោះអាសន្ន ព្រោះមានប្រសិទ្ធភាពតែក្នុងរយៈពេលសំណុំរឿងលែងលះនៅក្នុងស្ថានភាពរង់ចាំ។ នៅពេលដែលតុលាការចេញសាលក្រមស្ថាពរ សាលក្រមស្ថាពរនោះនឹងជំនួសឱ្យវិធានការបណ្តោះអាសន្នរបស់តុលាការ។[៥០]

ក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ គឺបានអនុញ្ញាតឱ្យតុលាការចេញនូវវិធានការបណ្តោះអាសន្ន «ការចាត់ចែងរក្សាការពារ»យ៉ាងប្រញាប់ បន្ទាប់ពីបានទទួលពាក្យបណ្តឹងសុំលែងលះ។ មេធាវីនៃគូភាគីត្រូវបានអនុញ្ញាតឱ្យចូលរួមស្តាប់នៅក្នុងសវនាការដើម្បីសម្រេចថាចាំបាច់ត្រូវមាន ឬមិនត្រូវមានវិធានការចាត់ចែងរក្សាការពារ។[៥១] ច្បាប់អនុញ្ញាតឱ្យតុលាការចេញវិធានការចាត់ចែងរក្សាការពារ ៥យ៉ាងដូចតទៅនេះ ទី១ វិធានការឱ្យសហព័ទ្ធត្រូវរស់នៅបែកគ្នា ទី២ វិធានការដាក់ឱ្យមានការថែរក្សាកូនបណ្តោះអាសន្ន ទី៣ វិធានការទាក់ទងដល់ការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន ទី៤ វិធានការទាក់ទងទៅនឹងការផ្គត់ផ្គង់សហព័ទ្ធ ឬផ្គត់ផ្គង់កូន និងទី៥ វិធានការរឹបអូសជាបណ្តោះអាសន្ន។

[៤៨] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា ៥១។

[៤៩] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា ៦៣។

[៥០] បណ្ឌិត ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍,ទំព័រទី២២២ និងទំព័រទី២២៣, ភាគ ១, បោះពុម្ពឆ្នាំ២០២១។

[៥១] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, មាត្រា ២១។

### ៣.៣.១. វិធានការឱ្យសហព័ទ្ធត្រូវតែរស់នៅបែកគ្នា

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ អនុញ្ញាតឱ្យតុលាការចេញវិធានការឱ្យភាគីទាំងពីររស់នៅបែកគ្នាបណ្តោះអាសន្នក្នុងកំឡុងពេលនៃនីតិវិធីលែងលះគ្នា ក្នុងករណីភាគីទាំងពីរមានប្រើអំពើហិង្សាក្នុងគ្រួសារ។ ប៉ុន្តែក្រមរដ្ឋប្បវេណីថ្មី មិនមានចែងអំពីវិធានការឱ្យសហព័ទ្ធត្រូវតែរស់នៅបែកគ្នាបណ្តោះអាសន្នទេ។ ក្នុងករណីភាគីទាំងពីរមានប្រើអំពើហិង្សាក្នុងគ្រួសារ និងបានប្តឹងលែងលះគ្នាតើតុលាការត្រូវដោះស្រាយបណ្តឹងសម្អាងលើច្បាប់អ្វី? នៅក្នុងករណីនេះពួកគេពឹងផ្អែកលើច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដែលផ្តល់អំណាចទៅឱ្យមេឃុំ ចៅសង្កាត់ក្នុងដំណាក់កាលនៃការជួយអន្តរាគមន៍លើកដំបូង។[៥២]

មាត្រា ១៤ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានផ្តល់សិទ្ធិអំណាចទៅដល់មេឃុំ ចៅសង្កាត់អាចចាត់វិធានការបណ្តោះអាសន្នដែលមានដូចជា៖

- ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង។
- ហាមបំផ្លាញទ្រព្យសម្បត្តិ ឬណែនាំកុំឱ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬរបស់ជនរងគ្រោះ ឬរបស់ញាតិសាលោហិតរបស់ជនរងគ្រោះ។
- ហាមជនមុខសញ្ញាចូលទៅជិត ឬចូលទៅក្នុងទីលំនៅរួមកន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច។
- ចាត់វិធានការស្របច្បាប់ផ្សេងទៀតដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពជនរងគ្រោះ និងសមាជិកគ្រួសារ ឬជនដែលពាក់ព័ន្ធ។

ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះក៏អាចធ្វើការដាក់ពាក្យបណ្តឹងទៅតុលាការរាជធានី ខេត្តដើម្បីសុំចេញដីកាការពារ។ តុលាការដែលទទួលបណ្តឹងដើម្បីចាត់ការអាចចេញដីកាការពារដោយមានវត្តមាន ឬពុំចាំបាច់មានវត្តមានសហព័ទ្ធដែលបានប្រើអំពើហិង្សា។

### ៣.៣.២. វិធានការឱ្យមានការថែរក្សាកូនបណ្តោះអាសន្ន

ការលែងលះរបស់ឪពុកម្តាយបានផ្តល់ផលប៉ះពាល់ និងបានជះឥទ្ធិពលមិនល្អដល់កូនដូចជា កូនខ្វះភាពកក់ក្តៅពីឪពុកម្តាយ ខ្វះការអប់រំ មានវិបិត្តផ្លូវចិត្តជាដើម។ ហេតុនេះហើយទើបតុលាការអនុញ្ញាតឱ្យមានវិធានគ្រប់គ្រងកូនដើម្បីការពារសុវត្ថិភាព និងការរស់នៅរបស់ពួកគេ ព្រោះថាភាគីលែងលះសុទ្ធតែប្តឹងទាមទារកូនរៀងៗខ្លួន។ ប្រសិនបើភាគីទាំងពីរ មិនព្រមព្រៀងគ្នាលើការថែរក្សាកូនក្នុងកំឡុងពេលនៃនីតិវិធីលែងលះគ្នា

[៥២] បណ្ឌិត ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍,ទំព័រទី២២៤ និងទំព័រទី២២៥, ភាគ១, បោះពុម្ពឆ្នាំ២០២១។

ចៅក្រមអាចចេញវិធានការកំណត់ថា តើឪពុក ឬម្តាយដែលត្រូវថែរក្សាកូនជាបណ្តោះអាសន្ន។ ឪពុកម្តាយដែលទទួលភារៈថែរក្សាកូន ជាទូទៅមានន័យថាជាឪពុកម្តាយដែលមានអំណាចធ្វើសេចក្តីសម្រេចទាក់ទងនឹងកូនដែលច្បាប់ហៅថាឪពុកម្តាយមានអំណាចមេបា ហើយជាឪពុកម្តាយដែលរស់នៅជាមួយកូននោះ។[៥៣]

### ៣.៣.៣. វិធានការស្តីពីការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន

ចៅក្រមមានអំណាចចេញវិធានការបណ្តោះអាសន្នស្តីពីការថែរក្សាការពារ និងប្រើប្រាស់ទ្រព្យសម្បត្តិក្នុងអំឡុងពេលនីតិវិធីនៃការលែងលះ។ ការនេះសំខាន់ណាស់ ពីព្រោះថាសហព័ទ្ធណាមួយ អាចព្យាយាមយកឬក៏លក់ ឬផ្ទេរទ្រព្យសម្បត្តិមុនពេលតុលាការមានឱកាសស៊ើបអង្កេត និងធ្វើការបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌។ ម្យ៉ាងទៀត ក៏ជួយការពារមិនឱ្យភាគីម្ខាងទៀត លក់ ធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនោះ។ ប្រសិនបើ សហព័ទ្ធទាំងពីរជាម្ចាស់ផ្ទះ ចៅក្រមអាចសម្រេចថាអ្នកណានឹងរស់នៅក្នុងផ្ទះនោះក្នុងអំឡុងពេលនៃដំណើរការនីតិវិធីការលែងលះគ្នានោះ។[៥៤]

### ៣.៣.៤. វិធានការផ្តល់ការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់សហព័ទ្ធ និងកូនជាបណ្តោះអាសន្ន

ការផ្តល់ការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់សហព័ទ្ធ និងកូនជាបណ្តោះអាសន្ន គឺជាវិធានការមួយដែលជួយរក្សាជីវភាពរស់នៅរបស់សហព័ទ្ធណាម្ខាង និងការជួយទំនុកបម្រុងលើតម្រូវការរបស់កូនក្នុងអំឡុងពេលលែងលះ។ តុលាការមានអំណាចចេញវិធានការបណ្តោះអាសន្នស្តីពីការផ្គត់ផ្គង់កូនបណ្តោះអាសន្ន ហើយក្នុងករណីចាំបាច់ តុលាការក៏អាចសម្រេចឱ្យមានការផ្គត់ផ្គង់ដល់សហព័ទ្ធផងដែរ។ បច្ចុប្បន្ន នៅមិនឃើញមានបញ្ញត្តិដែលចែងលម្អិតនៅក្នុងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីជួយឱ្យចៅក្រមក្នុងការសម្រេចកំណត់ចំនួនទឹកប្រាក់ សម្រាប់ផ្គត់ផ្គង់ប៉ុន្មានដែលសហព័ទ្ធមួយត្រូវបង់ឱ្យសហព័ទ្ធមួយទៀតដើម្បីផ្គត់ផ្គង់កូននោះទេ។ ជាទូទៅនៅក្នុងប្រទេសកម្ពុជា ក៏ដូចនៅប្រទេសផ្សេងទៀត តុលាការនឹងពិចារណាលើកត្តា ៣ យ៉ាង ដូចតទៅនេះ ទី១ សេចក្តីត្រូវការរបស់កូន ទី២ លទ្ធភាពខាងហិរញ្ញវត្ថុរបស់ឪពុក ឬម្តាយដែលត្រូវបានគេស្នើឱ្យសុំឱ្យបង់ប្រាក់ដើម្បីផ្គត់ផ្គង់ និងទី៣ ស្ថានភាពហិរញ្ញវត្ថុរបស់ឪពុក ឬម្តាយដែលកូនត្រូវរស់នៅជាមួយ។[៥៥]

តុលាការក៏អាចផ្តល់ការផ្គត់ផ្គង់បណ្តោះអាសន្នដល់សហព័ទ្ធដែលត្រូវការប្រាក់ ក្នុងអំឡុងពេលនីតិវិធីនៃការលែងលះគ្នា។ ម្យ៉ាងទៀត ច្បាប់មិនបានណែនាំតុលាការតើត្រូវសម្រេចផ្តល់ការផ្គត់ផ្គង់ដល់សហព័ទ្ធ ឬក៏មិនផ្តល់ ឬមានទឹកប្រាក់ចំនួនប៉ុន្មានដែរ សហព័ទ្ធមួយត្រូវបង់ទៅឱ្យសហព័ទ្ធមួយទៀតជាបណ្តោះអាសន្នទេ។

---

[៥៣] បណ្ឌិត ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍,ទំព័រទី២២៦, ភាគ ១, បោះពុម្ពឆ្នាំ២០២១។

[៥៤] បណ្ឌិត ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍,ទំព័រទី២២៧ និងទំព័រទី២២៨, ភាគ ១, បោះពុម្ពឆ្នាំ២០២១។

[៥៥] បណ្ឌិត ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍,ទំព័រទី២២៨, ភាគ ១, បោះពុម្ពឆ្នាំ២០២១។

ជាទូទៅតុលាការចេញវិធានការបណ្ដោះអាសន្នបើអាចធ្វើបានដើម្បីរក្សាកម្រិតជីវភាពសហព័ទ្ធ ដែលធ្លាប់ទទួលបានការផ្គត់ផ្គង់ដូចនៅក្នុងពេលដែលមានចំណងអាពាហ៍ពិពាហ៍។ ហើយចំពោះវិធានស្ដីពីការផ្គត់ផ្គង់សហព័ទ្ធជាបណ្ដោះអាសន្ននេះ មិនអនុវត្តជាចាំបាច់ចំពោះការផ្គត់ផ្គង់សហព័ទ្ធជាអចិន្ត្រៃយ៍នោះទេ។[៥៦]

### ៣.៣.៥. ការរឹបអូសជាបណ្ដោះអាសន្ន

ក្នុងករណីមានបណ្ដឹងលែងលះគ្នា តុលាការក៏អាចចេញវិធានការឱ្យធ្វើការរឹបអូសជាបណ្ដោះអាសន្ននូវទ្រព្យសម្បត្តិដែលជាចលនទ្រព្យ ឬអចលនទ្រព្យរបស់សហព័ទ្ធ ឬវត្ថុតាងណាមួយដោយឆន្ទានុសិទ្ធិបានដែរ ទោះបីភាគីមិនបានស្នើសុំក៏ដោយ។ វិធាននេះមានសារៈសំខាន់យ៉ាងខ្លាំងដើម្បីថែរក្សាទ្រព្យសម្បត្តិ ឬភស្តុតាងនានាដើម្បីបង្កាកុំឱ្យសហព័ទ្ធម្ខាងទៀតបំផ្លាញ ឬធ្វើឱ្យមានការខូចខាតទ្រព្យសម្បត្តិ ឬមានការចាត់ចែង ដូចជាការលក់ ការជួល ឬការបញ្ចាំ ប្រទានកម្ម ការធ្វើអំណោយជាដើម។[៥៧]

## ៣.៤. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

គោលបំណងនៃនីតិវិធីត្រៀមទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្ដីអះអាងរបស់ភាគីដើម្បីបំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីមិនយល់ស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចរឿងក្ដីលែងលះនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យក្នុងនីតិវិធីត្រៀមទាញហេតុផលឱ្យបានល្អិតល្អន់។[៥៨] នីតិវិធីត្រៀមទាញហេតុផលគឺអាចធ្វើនៅបន្ទប់ធម្មតាណាមួយដែលមានការដាក់ឈ្មោះថា ជាបន្ទប់ត្រៀមក៏បានដែរ ប៉ុន្តែតុលាការពុំចាំបាច់ហាមឃាត់អ្នកផ្សេងចូលរួមទេ។ នៅពេលមុនពេលតុលាការត្រូវសាកល្បងផ្សះផ្សា ឬទុកសិទ្ធិឱ្យគូភាគីផ្សះផ្សារវាងភាគី និងភាគី ឬមេធាវី និងគូភាគីផ្សះផ្សាជាដំបូងសិន បើមានមេធាវីចូលរួមតំណាងអាណត្តិឱ្យគូភាគី។ ប៉ុន្តែបើតុលាការយល់ឃើញថាការផ្សះផ្សា មិនមានភាពសមរម្យ និងការផ្សះផ្សាមិនអាចឱ្យគូភាគីបញ្ចប់វិវាទបានទេនោះ តុលាការពុំបាច់ចាប់ផ្ដើមការផ្សះផ្សាទេ នោះតុលាការមានសិទ្ធិចាប់ផ្ដើមនីតិវិធីត្រៀមទាញហេតុផលតែម្ដងក៏បាន។[៥៩] ហេតុដូចនេះហើយ តុលាការអាចកោះហៅភាគីទាំងពីរឱ្យមកធ្វើការបំភ្លឺម្នាក់ម្ដងដែលកាលបរិច្ឆេទត្រូវបានកំណត់សមរម្យទៅតាមពេលវេលាដែលគូភាគីអាចចូលរួមបាន។[៦០] ដោយសារតែរឿងក្ដីលែងលះគឺជាវិវាទមួយដែលត្រូវតែមានវត្តមានរបស់ភាគីទាំងសងខាងក្នុងពេលស៊ើបសួរ ទើបធ្វើឱ្យមានការកាត់សេចក្ដីរបស់

[៥៦] បណ្ឌិត ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍,ទំព័រទី២២៩, ភាគ ១, បោះពុម្ពឆ្នាំ២០២១។

[៥៧] បណ្ឌិត ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍,ទំព័រទី២៩, ភាគ១, បោះពុម្ពឆ្នាំ២០២១។

[៥៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១០៣។

[៥៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១០៤។

[៦០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១០៥។

តុលាការអាចធានាបាន ថាសមហេតុផលប្រកបដោយភាពសត្យានុម័ត។ កាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផល តុលាការអាចចេញដីកាសម្រេចដែលទាក់ទងទៅនឹងការស្នើសុំពិនិត្យភស្តុតាង ឬដីកាសម្រេចផ្សេងទៀតដែលអាចសម្រេចបានក្រៅពីការពិនិត្យភស្តុតាងឯកសារដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង។[៦១]

### ៣.៤.១. ការរៀបចំការអះអាងរបស់សហព័ន្ធទាំងពីរ

ការអះអាង គឺជាសេចក្តីថ្លែងការណ៍មួយមិនមែនជាការឆ្លើយតបនឹងសេចក្តីថ្លែងការណ៍របស់សហព័ទ្ធម្ខាងទៀតហើយរៀបរាប់អំពីអង្គហេតុឯករាជ្យ ឬមតិយោបល់តាមផ្លូវច្បាប់។

នៅពេលចាប់ផ្តើមធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយតុលាការពិនិត្យឃើញថាអង្គហេតុដែលបានសរសេរនៅក្នុងពាក្យបណ្តឹងក៏ដូចជានៅក្នុងឯកសារត្រៀមមានមិនច្បាស់លាស់។ ដូចនេះ ដើម្បីឱ្យចំណុចវិវាទនៃអង្គហេតុ និងអង្គច្បាប់ដែលទាក់ទងនឹងបណ្តឹងមានភាពច្បាស់លាស់តុលាការអាចសាកសួរសហព័ទ្ធទាំងពីរ ឬសហព័ទ្ធទាំងពីរអះអាងបញ្ជាក់ភស្តុតាងចំពោះចំណុចនោះនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[៦២]

មាត្រា ៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ បានកំណត់ថា នៅក្នុងនីតិវិធីនៃបណ្តឹង តុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបាននោះឡើយ។[៦៣] ដើម្បីឱ្យសហព័ទ្ធទាំងសងខាងអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបាន នោះតុលាការអាចសួរអំពីចំណុចមិនច្បាស់លាស់នៃអង្គហេតុដែលភាគីបានអះអាង ឬចំណុចដែលមានភាពបដិវាទកម្មហើយតុលាការអាចជម្រុញឱ្យសហព័ទ្ធទាំងសងខាងធ្វើការអះអាងនូវអង្គហេតុសមរម្យថ្មីទៀត ឬការដាក់ភស្តុតាងថ្មីបានក្នុងករណីខ្លះដើម្បីឱ្យការជម្រះក្តីមួយមានភាពត្រឹមត្រូវ និងមានសមភាពការប្រើប្រាស់សិទ្ធិឱ្យបំភ្លឺនេះ គឺជាករណីយកិច្ចរបស់តុលាការផងដែរ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ គឺតម្រូវសហព័ទ្ធទាំងសងខាងបំភ្លឺចំណុចវិវាទរបស់ខ្លួនដែលបានលើកឡើងមិនស្របគ្នាតែប៉ុណ្ណោះ ហើយនិងធ្វើការរៀបចំមធ្យោបាយតទល់ ឬការពារខ្លួននោះជាពិសេស ត្រូវរៀបចំសេចក្តីអះអាងរបស់សហព័ទ្ធទាំងសងខាងដើម្បីកំណត់ចំណុចវិវាទពិតប្រាកដនៃរឿងក្តី ហើយតុលាការត្រូវរៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទ ដែលត្រូវធ្វើការពិនិត្យនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។

[៦១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១០៦។

[៦២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៩០។

[៦៣]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៩៥។

### ៣.៤.២. ការរៀបចំចំណុចវិវាទ

ចំណុចវិវាទ គឺជាចំណុចនៃទំនាស់ដែលត្រូវបំភ្លឺដើម្បីចេញសាលក្រម។ ចំណុចវិវាទអាចជាចំណុចវិវាទលើអង្គហេតុ ឬចំណុចវិវាទលើអង្គច្បាប់។

ជាគោលការណ៍តុលាការត្រូវចាត់ចែងរៀបចំការអះអាងរបស់សហព័ទ្ធទាំងសងខាង ដើម្បីកំណត់ឱ្យបានច្បាស់នូវចំណុចវិវាទនៃរឿងតាមនីតិវិធីដាស់តឿនឱ្យសហព័ទ្ធទាំងពីរដកចេញនូវអង្គហេតុ ដែលមិនមានការពាក់ព័ន្ធ ឬមិនមានសារៈសំខាន់ចំពោះការវិនិច្ឆ័យ អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង ហើយដកចេញនូវអង្គហេតុទាំងឡាយណាដែលសហព័ទ្ធទាំងសងខាងបានយល់ស្រប និងត្រូវគ្នាចេញពីកម្មវត្ថុនៃការពិនិត្យភស្តុតាង។

### ៣.៤.៣. ការរៀបចំពិនិត្យភស្តុតាង

ការរៀបចំភស្តុតាង គឺជាការប្រមូលនូវភស្តុតាងដែលពាក់ព័ន្ធទៅនឹងរឿងក្តីការអះអាងរបស់សហព័ទ្ធទាំងសងខាង ឬពាក់ព័ន្ធនឹងចំណុចវិវាទដែលត្រូវបំភ្លឺ និងសម្រាប់ជាមូលដ្ឋានក្នុងការវិនិច្ឆ័យនៅពេលទាញហេតុផលដោយផ្ទាល់មាត់។

ការរៀបចំភស្តុតាងមិនមែនជានីតិវិធីពិនិត្យភស្តុតាងនោះទេ ពោលគឺតុលាការគ្រាន់តែស្តាប់ពីការអះអាងរបស់សហព័ទ្ធទាំងពីរ និងកំណត់ចំណុចវិវាទដែលភាគីនៃរឿងក្តីមិនស្របគ្នាហើយរៀបចំភស្តុតាងដែលពាក់ព័ន្ធនឹងការអះអាងនោះប៉ុណ្ណោះលើកលែងក្នុងករណីចាំបាច់ ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី តុលាការអាចពិនិត្យភស្តុតាងជាឯកសារបាន ឬការចាត់ចែងរក្សាភស្តុតាង។

### ៣.៤.៤. ការប្តឹងតបរបស់ចុងចម្លើយ

បណ្តឹងតប គឺជាបណ្តឹងសាត្រឡប់របស់ចុងចម្លើយអាចប្តឹងតបរហូតដល់ពេលចប់ការទាះហេតុផលផ្ទាល់មាត់បាន លុះត្រាតែកម្មវត្ថុនៃបណ្តឹងតបនោះ ទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬជាមធ្យោបាយការពារខ្លួនសម្រាប់បណ្តឹងដើម។ ចំពោះបណ្តឹងតប គឺជាបណ្តឹងដែលដាក់ដោយដើមចោទហើយកំពុងតែត្រូវបានចាត់ការនោះហៅថា បណ្តឹងដើម។

មាត្រា ៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ បានបញ្ញត្តិថា ចុងចម្លើយអាចប្តឹងតបទៅតុលាការដែលកំពុងចាត់ការបណ្តឹងដើមរហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែទាមទារដែលជាកម្មវត្ថុនៃបណ្តឹងតបនោះ ទាក់ទងនឹងការទាមទារដែលជាកម្មវត្ថុនៃបណ្តឹងដើម ឬមធ្យោបាយការពារខ្លួន

សម្រាប់បណ្ដឹងជាដើម។ ចំពោះករណីដែល ការទាមទារនៃបណ្ដឹងតបមិនត្រូវស្ថិតនៅ ក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការដទៃទៀតតាមច្បាប់ ឬនីតិវិធីបណ្ដឹងមិនមានការយឺតយ៉ាវខ្លាំងដោយសារការដាក់បណ្ដឹងតប។

### ៣.៤.៥. កាលកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ដើម្បីជៀសវាង នូវការយឺតយ៉ាវក្នុងការដោះស្រាយរឿង តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូងក្នុងអំឡុងពេល ៣០ ថ្ងៃបន្ទាប់ពីថ្ងៃដែលសហព័ទ្ធដើមចោទបានដាក់ពាក្យបណ្ដឹងសុំលែងលះគ្នា។[៦៤]

មាត្រា ១០៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៦ បានបញ្ញត្តិថានីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលសហព័ទ្ធទាំងសងខាងអាចចូលរួមបាន។ មានន័យថា គោលការណ៍ចំពោះមុខ ត្រូវបានធានាយ៉ាងពេញលេញនៅក្នុងនីតិវិធីនេះ។ ហេតុនេះ បន្ទាប់ពីបានកំណត់កាលបរិច្ឆេទ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ តុលាការត្រូវកោះហៅសហព័ទ្ធទាំងសងខាង។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ទោះបីជាសហព័ទ្ធម្ខាងមិនមានវត្តមានក៏ដោយ ក្នុងករណីដែលតុលាការ បានបញ្ជូនដីកាកោះ និងបានផ្ដល់ឱកាសឱ្យសហព័ទ្ធទាំងសងខាងនោះបង្ហាញខ្លួន។

កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលគឺធ្វើឡើងក្នុងគោលបំណងរៀបចំ នូវការអះអាងរបស់សហព័ទ្ធទាំងសងខាងដើម្បីធ្វើការបញ្ជាក់នូវចំណុចវិវាទ និងដើម្បីរៀបចំភស្តុតាងដើម្បីពិនិត្យតែប៉ុណ្ណោះ។ ដូចនេះនៅក្នុងកាលបរិច្ឆេទនេះផងដែរ នីតិវិធីមិនចាំបាច់ធ្វើជាសាធារណៈនៅក្នុងបន្ទប់សវនាការនោះឡើយ។ មានន័យថា សកម្មភាពនេះមិនទាមទារឱ្យបើកចំហជាសាធារណៈសម្រាប់សាធារណជននោះទេ ប៉ុន្តែតុលាការអាចធ្វើការអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថា សមរម្យនឹងចូលរួមធ្វើជាអ្នកសង្កេតការណ៍បាន។[៦៥] សកម្មភាពដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះត្រូវបានធ្វើសេចក្ដីថ្លែងការណ៍ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់នាពេលក្រោយ និងត្រូវបំភ្លឺអំពីបញ្ហាទាំងអស់នេះនៅក្នុងសវនាការជាសាធារណៈ។[៦៦]

---

[៦៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៨០, កថាខណ្ឌទី២។

[៦៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១០៥, កថាខណ្ឌទី២, វាក្យខណ្ឌទី២។

[៦៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១៦។

ចំពោះការអនុញ្ញាត ឬមិនអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ចូលស្តាប់ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ហើយតុលាការត្រូវធ្វើការពិចារណា អំពីមូលហេតុនៃការស្នើសុំឱ្យចូលរួមស្តាប់ព្រមទាំងមតិរបស់សហព័ទ្ធទាំងសងខាងផងដែរ។ ប៉ុន្តែក្នុងករណីដែលយល់ឃើញថាសហព័ទ្ធណាម្ខាង អាចរងការប៉ះពាល់ផ្លូវចិត្តដោយសារតែ វត្តមានរបស់បុគ្គលដែលពាក់ព័ន្ធនោះ តុលាការមិនត្រូវអនុញ្ញាតឱ្យបុគ្គលនោះចូលស្តាប់ទេ។

មាត្រា ១០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ បានចែងថា តុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុនូវរាល់ការបរិច្ឆេទនីមួយៗនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[៦៧] នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចគឺ៖

- សញ្ញាណរឿងក្តី។
- ឈ្មោះចៅក្រម និង ក្រឡាបញ្ជី។
- ឈ្មោះសហព័ទ្ធទាំងសងខាង អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន។
- ពេលវេលា និង ទីកន្លែង។

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលបានកំណត់ហេតុនោះ។[៦៨]

នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើការកត់ត្រានូវសេចក្តីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចដូចខាងក្រោមនេះ៖

- ខ្លឹមសារនៃសាលក្រមដែលសហព័ទ្ធដើមចោទទាមទារឱ្យតុលាការចេញ និងចម្លើយតបរបស់សហព័ទ្ធចុងចម្លើយ ចំពោះការទាមទារនោះ។
- ខ្លឹមសារនៃអង្គហេតុ ដែលបានអះអាង និងការស្នើសុំឱ្យពិនិត្យភស្តុតាង។
- ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់សហព័ទ្ធទាំងសងខាងចំពោះអង្គហេតុដែលបានអះអាងដោយសហព័ទ្ធម្ខាងទៀត និងការទទួលស្គាល់មិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ។
- ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និងការទទួលស្គាល់ការទាមទារ។

[៦៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១០៩។

[៦៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១០។

- ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រាតាមការទាមទាររបស់ភាគី។
- ការសម្រេចសេចក្តីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះដោយមិនធ្វើជាលាយលក្ខណ៍អក្សរ។[៦៩]

ក្នុងករណីដែលសហព័ទ្ធ ប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ក្រឡាបញ្ជីត្រូវកត់ត្រាសេចក្តីប្តឹងតវ៉ានោះនៅក្នុងកំណត់ហេតុនោះ។[៧០]

### ៣.៤.៦. ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្រោយពីទទួលពាក្យបណ្តឹង តុលាការត្រូវចាត់តាំងចៅក្រមណាមួយរូបដើម្បីធ្វើការផ្សះផ្សា។ នៅពេលដែលតុលាការកោះហៅសហព័ទ្ធទាំងសងខាងឱ្យចូលខ្លួន តុលាការត្រូវធ្វើការសាកល្បងផ្សះផ្សាជាដំបូងសិនលើកលែងតែយល់ឃើញថាមិនសមរម្យនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[៧១]

ជាគោលការណ៍ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។[៧២] លើសពីនេះ ការផ្សះផ្សាអាចធ្វើឡើងក្រៅទីតាំងតុលាការក៏បានដែរ ប្រសិនបើតុលាការយល់ឃើញថាសមរម្យ។[៧៣]

ទោះបីជាប្តី ប្រពន្ធណាម្ខាងទាមទារលែងលះគ្នាខ្លាំងក្លាយ៉ាងណាក៏ដោយ តុលាការអាចណែនាំឱ្យធ្វើការផ្សះផ្សាបានដោយឆន្ទានុសិទ្ធិ។ ជាពិសេស តុលាការធ្វើការលើកទឹកចិត្តឱ្យមានការសះជានឹងគ្នា នៅពេលដែលប្តីប្រពន្ធមានកូនជាអនីជន ឬនៅក្នុងករណីដែលមានស្ថានភាពដែលសហព័ទ្ធម្ខាងនឹងជួបប្រទះនូវភាពលំបាកលំបិនផ្នែកសេដ្ឋកិច្ច។ ប៉ុន្តែក្នុងករណីដែលសហព័ទ្ធទាំងសងខាង មិនអាចឈានដល់ការសះជានឹងគ្នាទេ ទោះបីជាតុលាការបានសាកល្បងធ្វើការផ្សះផ្សាហើយក៏ដោយ ក៏តុលាការត្រូវយកបណ្តឹងលែងលះគ្នាមកធ្វើការវិនិច្ឆ័យហើយធ្វើការប្រកាសសាលក្រម។[៧៤] ប្រសិនបបើការផ្សះផ្សាមានការត្រូវរ៉ូវគ្នានោះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុស្តីពីការសះជា។

[៦៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១១។
[៧០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១២។
[៧១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១០៤។
[៧២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៩៧។
[៧៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ២២០។
[៧៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៨៤។

កំណត់ហេតុស្តីពីការសះជា គឺជាលិខិតដែលកត់ត្រាអំពីលទ្ធផលនៃការផ្សះផ្សាដែលភាគីបានព្រមព្រៀងគ្នា និងនាំឱ្យមានការបញ្ចប់រឿងក្តី។ កំណត់ហេតុស្តីពីការសះជាមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរដែរ។ ពេលខ្លះបណ្តឹងក៏អាចបញ្ចប់នៅក្នុងនីតិវិធីត្រៀមនេះ ដោយសារការសះជានឹងគ្នាការលះបង់នូវការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ហេតុនេះ ហើយមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរផងដែរ។[៧៥]

## ៣.៥. នីតិវិធីទាញហេតុផលផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់រួចរាល់អស់ហើយ តុលាការត្រូវតែកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយត្រូវកោះហៅគូភាគីមកចូលរួមនៅក្នុងដំណើរការនេះ។[៧៦] ជាគោលការណ៍ដើម្បីចេញសាលក្រមលើបណ្តឹង តុលាការចាំបាច់ត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[៧៧] ហេតុនេះហើយនៅពេលដែលនីតិវិធីសម្រាប់ការត្រៀមទាញហេតុផលបានបញ្ចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម។[៧៨] នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ច្បាប់មិនបានបញ្ញត្តិអំពីអំឡុងពេលប៉ុន្មាននោះទេ ប៉ុន្តែតុលាការត្រូវកំណត់កាលបរិច្ឆេទឱ្យបានឆាប់រហ័ស[៧៩] កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន។[៨០] ជាគោលការណ៍ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងលែងលះមិនត្រូវធ្វើជាសាធារណៈឡើយ។[៨១]

ក្នុងករណីដែលដល់កាលបរិច្ឆេទ ប៉ុន្តែប្រសិនបើ ភាគីដើមចោទ អវត្តមាន ដោយមិនបានចូលរួមក្នុងកាលបរិច្ឆេទនីតិវិធីរបស់តុលាការ។ ការអវត្តមាននេះ តុលាការសន្មតថា ដើមចោទ គ្មានឆន្ទៈក្នុងការធ្វើទៅតាមនីតិវិធីនៃបណ្តឹង។ នៅក្នុងករណីដែល ដើមចោទ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផល

---

[៧៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ២២២។

[៧៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១៣។

[៧៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១៤។

[៧៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១៣។

[៧៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤។

[៨០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១៥, កថាខណ្ឌទី១។

[៨១] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, មាត្រា ១៦, កថាខណ្ឌទី១។

ដោយផ្ទាល់មាត់ តុលាការត្រូវចេញសាលក្រមកំបាំងមុខច្រានចោលនូវការទាមទាររបស់ដើមចោទ។[៩២] ក្នុងករណីដែលដើមចោទ បានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុ តែមិនបានបង្ហាញនៅកាលបរិច្ឆេទបន្ត នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុទេ តុលាការមិនត្រូវចេញសាលក្រមកំបាំងទេគឺអាចបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់បាន។[៩៣]

ក្នុងករណីដែល ចុងចម្លើយ អវត្តមាននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែ ក្នុងករណីដែលចុងចម្លើយនោះបានធ្វើវិវាទលើការអះអាងរបស់ ដើមចោទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់[៩៤]ពីមុនមកចេញ នោះចុងចម្លើយត្រូវចាត់ទុកថាបានសារភាពនូវសេចក្ដីថ្លែងការណ៍អំពីអង្គហេតុរបស់ដើមចោទ។ បន្ទាប់មកប្រសិនបើយល់ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវតុលាការត្រូវចេញសាលកំបាំងមុខទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ហើយប្រសិនបើយល់ឃើញថា ការទាមទាររបស់ដើមចោទមិនត្រឹមត្រូវទេ តុលាការត្រូវចេញសាលក្រមធម្មតាច្រានចោលនូវការទាមទាររបស់ដើមចោទ។[៩៥]

### ៣.៥.១. ការថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាបឋមភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[៩៦] សេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាសេចក្ដីថ្លែងការណ៍ដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានលើកឡើងរួមគ្នាសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ដើម្បីយកមកធ្វើជាមូលដ្ឋាននៃសាលក្រមដោយចាត់ទុកថាសកម្មភាពទាំងឡាយដែលបានធ្វើក្នុងការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងតុលាការ។ នៅពេលធ្វើសេចក្ដីថ្លែងការណ៍ អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាង ដែលនឹងត្រូវធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ពោលគឺត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអង្គហេតុដែលជាចំណុចវិវាទ និងធ្វើការអះអាងបន្ថែមទៀតអំពីអង្គហេតុ និងដាក់ភស្តុតាងទៀតបាន។

[៩២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦,មាត្រា ២០០, កថាខណ្ឌទី៣។

[៩៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦,មាត្រា ២០០, កថាខណ្ឌទី២។

[៩៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦,មាត្រា ២០១, កថាខណ្ឌទី២,វាក្យខណ្ឌទី២។

[៩៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦,មាត្រា ២០១, កថាខណ្ឌទី២។

[៩៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១៦, កថាខណ្ឌទី១។

### ៣.៥.២. ការពិនិត្យភស្តុតាងដោយសម្ភាវិធី

ការពិនិត្យភស្តុតាងនៅក្នុងរឿងលែងលះ មិនខុសគ្នាទៅនឹងការពិនិត្យភស្តុតាងនៅក្នុងរឿងរដ្ឋប្បវេណីទូទៅទេ គឺតុលាការអាចធ្វើការពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។[៨៧] ការពិនិត្យភស្តុតាងមានដូចជា ការសាកសួរសាក្សី ឬសាមីភាគី និងការពិនិត្យភស្តុតាងជាឯកសារ។[៨៨] ក្រោយពីពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់ បើយល់ឃើញថាត្រូវការជាចាំបាច់ពិសេស តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីម្តងទៀតបានដោយដីកាសម្រេច។[៨៩]

ជាចុងក្រោយ តុលាការអនុញ្ញាតឱ្យភាគីនីមួយៗ ធ្វើការទាញហេតុផលផ្ទាល់មាត់ជាលើកចុងក្រោយមុនពេលបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់។[៩០] ទន្ទឹមនឹងនេះ នៅក្នុងដំណាក់កាលនីតិវិធីទាញហេតុផលផ្ទាល់មាត់ ក្រឡាបញ្ជីមានកាតព្វកិច្ចសំខាន់ណាស់ក្នុងការកត់ត្រារាល់សកម្មភាព និងហេតុការណ៍ទាំងឡាយជូនតុលាការ។ ក្រឡាបញ្ជីត្រូវតែកត់ត្រានូវសញ្ញាណនៃរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជីដែលបានចូលរួមរួមជាមួយនឹងឈ្មោះរបស់គូភាគីលែងលះ និងបុគ្គលទាំងឡាយដែលមានការពាក់ព័ន្ធផ្សេងៗទៀត ពេលវេលា និងទីកន្លែង។ ក្រុមប្រឹក្សាជំនុំជម្រះត្រូវពិនិត្យទៅលើកំណត់ត្រានោះ រួចហើយធ្វើការចុះហត្ថលេខាផងដែរ។[៩១]

លើសពីនេះទៅទៀត ក្រឡាបញ្ជីក៏ត្រូវកត់ត្រាបន្ថែមពាក់ព័ន្ធនឹងចំណុចសារធាតុមួយចំនួនដែលមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដូចជា កត់ត្រាអំពីសេចក្តីថ្លែងការណ៍របស់ភាគី សាក្សី និងសកម្មភាពផ្សេងៗទៀតដែលភាគីលែងលះបានធ្វើនៅក្នុងអំឡុងពេលនៃនីតិវិធីនោះ។[៩២] ចំណែកឯចៅក្រមវិញត្រូវកំណត់កាលបរិច្ឆេទមិនឱ្យលើសពី ៣០ថ្ងៃ ដើម្បីធ្វើការប្រកាសសាលក្រម បន្ទាប់ពីបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។[៩៣]

---

[៨៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១២៧, កថាខណ្ឌទី១។

[៨៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ២១៧, កថាខណ្ឌទី១ និងកថាខណ្ឌទី២។

[៨៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១៦, កថាខណ្ឌទី៤។

[៩០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១៦, កថាខណ្ឌទី៥។

[៩១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១៨។

[៩២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១១៩។

[៩៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១៨៧។

## ៣.៦. ការសម្រេចសេចក្តី

ក្រោយពីឆ្លងកាត់នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់រួចហើយ តុលាការនឹងធ្វើការសម្រេចសេចក្តី ដោយការចេញសាលក្រម។ នៅក្នុងការសម្រេចសេចក្តី ទៅលើរឿងក្តីលែងលះដោយគ្មានការព្រមព្រៀង តុលាការមានឆន្ទានុសិទ្ធិសម្រេចចេញសាលក្រម ឬសម្រេចបដិសេធចោលនូវបណ្តឹងលែងលះនោះ។

### ៣.៦.១. ការចេញសាលក្រមលើបណ្តឹងលែងលះ

សាលក្រម សំដៅទៅលើការសម្រេចសេចក្តីដែលតុលាការបានធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់។[៩៤] នៅក្នុងករណីបើយល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលបានពីការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យលើភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រម។[៩៥] ជាទូទៅតុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ។ ហើយតុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ។[៩៦] ក៏ប៉ុន្តែប្រសិនបើតុលាការចេញសាលក្រម ឬតុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ ហើយបើមានពាក្យសុំរបស់ភាគី ត្រូវធ្វើការសម្រេចសេចក្តីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ។[៩៧] ទាក់ទងទៅនឹងការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា ឬការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូននេះផងដែរ តុលាការត្រូវពិចារណា ថ្លឹងថ្លែងពីយោបល់របស់កូនស្របទៅតាមអាយុ និងសភាពចាស់ទុំរបស់កូននោះ។[៩៨]

នៅក្នុងលិខិតសាលក្រម តុលាការត្រូវសរសេរអំពី តុលាការដែលមានសមត្ថកិច្ច ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីដែលពាក់ព័ន្ធ អង្គហេតុ ចំណុចវិវាទ សម្អាងហេតុ និងសេចក្តីសម្រេចបញ្ចប់ផងដែរ។ ចៅក្រមដែលចេញសាលក្រមត្រូវចុះហត្ថលេខា

[៩៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១៧៩, កថាខណ្ឌទី១។

[៩៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១៨០។

[៩៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១៨២, កថាខណ្ឌទី១ និងកថាខណ្ឌទី២។

[៩៧] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, មាត្រា២២, កថាខណ្ឌទី១។

[៩៨] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, មាត្រា២២។

លើលិខិតសាលក្រមនោះផងដែរ។ សាលក្រមនឹងមានអានុភាពដោយការប្រកាស។[៩៩] ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់។[១០០] ជាក់ស្តែង សាលក្រមដែលបានសម្រេចអំពីការលែងលះត្រូវបញ្ជូនឱ្យទៅភាគីក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ដោយត្រូវគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រម។[១០១]

### ៣.៦.២. ការសម្រេចមិនឱ្យមានការលែងលះ

ទោះបីជានៅក្នុងករណីដែលមានមូលហេតុគ្រប់គ្រាន់តាមពាក្យបណ្តឹង សម្រាប់ការសម្រេចសេចក្តីឱ្យធ្វើការលែងលះគ្នាក៏ដោយ ប្រសិនបើយល់ឃើញថា ការលែងលះនោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូនក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់យ៉ាងខ្លាំងដែលពុំអាចទ្រាំទ្របាន នោះតុលាការអាចច្រានចោលការទាមទារលែងលះគ្នាដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន។[១០២]

ក្នុងករណីដែលមានមូលហេតុផ្សេងទៀត តុលាការក៏នៅតែអាចច្រានការទាមទារលែងលះគ្នាបានដែរ ប្រសិនបើយល់ឃើញថា ការទាមទារនោះផ្ទុយទៅនឹងភាពសុចរិតដោយជនដែលទាមទារឱ្យលែងលះគ្នានោះមានការធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិការ និងជួយសង្គ្រោះចំពោះសហព័ទ្ធ ហើយតុលាការអាចច្រានចោលការទាមទារលែងលះគ្នានោះដោយឆន្ទានុសិទ្ធិរបស់តុលាការបានថែមទៀតផង។[១០៣]

### ៣.៦.៣. ការចូលជាស្ថាពរនៃសាលក្រម

ជាការពិតណាស់ សាលក្រមមិនអាចចូលជាស្ថាពរ នៅមុនពេលផុតអំឡុងពេលដែលបានកំណត់សម្រាប់ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់(សាលាឧទ្ធរណ៍ និងតុលាការកំពូល)បានទេ។ ជាទូទៅនៅពេលដែលសាលក្រមត្រូវបានបញ្ជូនឱ្យទៅភាគីក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយត្រូវគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមរួចមក គូភាគីអាចប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះបានក្នុងអំឡុងពេល ១ (មួយ) ខែ ដោយគិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម។[១០៤] ហេតុនេះ បើគ្មានការប្តឹងដូចបានលើកឡើងខាងលើនេះទេ ហើយអំឡុងពេលដែលអនុញ្ញាតឱ្យប្តឹងត្រូវបានផុតកំណត់ នោះសាលក្រមនឹងចូល

[៩៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១៨៦។

[១០០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១៨៧។

[១០១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, កថាខណ្ឌទី៣។

[១០២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៨, កថាខណ្ឌទី២។

[១០៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៨, កថាខណ្ឌទី៣។

[១០៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ២៦៤, កថាខណ្ឌទី១។

ជាស្ថាពរ។ ក្នុងករណីដែលសេចក្តីសម្រេចអំពីការលែងលះ មោឃភាព ឬការលុបចោលអាពាហ៍ពិពាហ៍ បានចូលជាស្ថាពរ អ្នកដាក់ពាក្យសុំទៅតុលាការត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់ ដែលអ្នកដាក់ពាក្យសុំទៅតុលាការរស់នៅ ដោយភ្ជាប់ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសេចក្តីសម្រេចរបស់តុលាការនោះ និងសេចក្តីបញ្ជាក់អំពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការនោះ បានចូលជាស្ថាពរក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ ដោយគិតពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការ នោះបានចូលជាស្ថាពរ។[១០៥]

[១០៥] ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣, មាត្រា ៧៨, កថាខណ្ឌទី១។

# ជំពូកទី ៤

# អានុភាពនៃការលែងលះ

# ជំពូកទី៤

# អានុភាពនៃការលែងលះ

ការលែងលះមានអានុភាពគឺនាំឱ្យមានការកាត់ផ្តាច់នូវចំណងអាពាហ៍ពិពាហ៍ រវាងសហព័ទ្ធនៅពេលដែលសេចក្តីសម្រេចអំពីការលែងលះបានចូលជាស្ថាពរ។ សេចក្តីសម្រេចអំពីការលែងលះនឹងចូលជាស្ថាពរនៅពេលដែលអំឡុងពេលនៃបណ្តឹងឧបាស្រ័យបានកន្លងផុត។ បើសេចក្តីសម្រេចនេះជាសាលក្រម អំឡុងពេលប្តឹងឧទ្ធរណ៍គឺ ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលលិខិតសាលក្រម។ នៅក្នុងករណីដែលសេចក្តីសម្រេចនេះជាដីការសម្រេច គឺត្រូវប្តឹងជំទាស់ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនេះ។[១០៦] ដូច្នេះនៅពេលដែលផុតអំឡុងពេលដូចបានបញ្ជាក់ជូនខាងលើនេះ សេចក្តីសម្រេចអំពីការលែងលះនឹងចូលជាស្ថាពរ។

## ៤.១. ការកាត់ផ្តាច់ទំនាក់ទំនងញាតិ

ការរៀបអាពាហ៍ពិពាហ៍ បង្កើតបានជាចំណងទំនាក់ទំនងគតិយុត្តរបស់សហព័ទ្ធទាំងពីរ ដោយមានចំណងរវាងសហព័ទ្ធ និងទំនាក់ទំនងញាតិរបស់អ្នកទាំងពីរ។ ប៉ុន្តែនៅពេលដែលការលែងលះកើតឡើងអានុភាពនៃការលែងលះក៏កើតឡើងដូចគ្នា ដោយការលែងលះគឺជាការផ្តាច់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធ និងការផ្តាច់ទំនាក់ទំនងញាតិពន្ធ។ នៅពេលដែលមានការប្រកាសសេចក្តីសម្រេចឱ្យធ្វើការលែងលះ នោះអានុភាពនៃការរំលាយ ឬការកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងសហព័ទ្ធទាំងពីរនឹងត្រូវរលត់។ ដូច្នេះ ចំណងគតិយុត្តអំពីបុគ្គលនៃអ្នកទាំងពីរត្រូវបានកាត់ផ្តាច់លែងមានសិទ្ធិ និងករណីយកិច្ចរវាងគ្នានឹងគ្នា ដូចកាលនៅមានចំណងអាពាហ៍ពិពាហ៍នឹងគ្នាទៀតហើយ។ ការរំលាយចំណងអាពាហ៍ពិពាហ៍ គឺជាមូលហេតុធ្វើឱ្យចំណងគតិយុត្តិប្រែប្រួល និងផ្លាស់ប្តូរ ដូចជាទំនាក់ទំនងសហព័ទ្ធ នាមត្រកូល ញាតិពន្ធ ជាដើម ។

### ៤.១.១. ទំនាក់ទំនងគតិយុត្តចំពោះសហព័ទ្ធ

ការផ្តាច់ចំណងអាពាហ៍ពិពាហ៍ ឬការលែងលះធ្វើឱ្យចំណងសហព័ទ្ធត្រូវបានរលត់ នៅពេលដែលមានសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ។ ទោះបីជា មានការកាត់ផ្តាច់ចំណងប្តីប្រពន្ធហើយក៏ដោយក៏នារីពុំត្រូវឱ្យមានការរៀបអាពាហ៍ពិពាហ៍ថ្មីម្តងទៀតទេ ប្រសិនបើមិនទាន់ផុតរយៈពេល ១២០ថ្ងៃ គិតចាប់ពីថ្ងៃដែល

[១០៦] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០, មាត្រា ៤០, កថាខណ្ឌទី១។

អាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល ផ្ទុយមកវិញបើនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ហើយបានសម្រាលកូន ឬចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត[១០៧] នោះនារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដោយពុំចាំបាច់រង់ចាំរយៈពេល ១២០ថ្ងៃ។ ចំពោះបុរសវិញ ពេលបានបញ្ចប់នូវអាពាហ៍ពិពាហ៍ហើយ ហើយសាលក្រមចូលជាស្ថាពរ គឺអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន មិនចាំបាច់រង់ចាំទេ។

### ៤.១.១.១. សិទ្ធិ និងកាតព្វកិច្ចក្រោយការលែងលះរបស់សហព័ទ្ធ

សិទ្ធិ និងកាតព្វកិច្ចមួយចំនួនត្រូវបានកើតឡើងនៅពេលដែលបានរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែនៅក្រោយពេលលែងលះ សិទ្ធិ និងកាតព្វកិច្ចមួយចំនួនត្រូវបានរលត់ទៅតាមការលែងលះនោះ ហើយសិទ្ធិ និងកាតព្វកិច្ចផ្សេងទៀតក៏ត្រូវបានកើតឡើងថ្មីផងដែរ។

### ៤.១.១.២. នាមត្រកូលរបស់សហព័ទ្ធ

ប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មីដោយអាពាហ៍ពិពាហ៍អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬអាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន។[១០៨] ដោយសារតែសហព័ទ្ធមួយចំនួន ជាពិសេសស្រ្តីភាគច្រើននៅពេលដែលរៀបអាពាហ៍ពិពាហ៍រួចហើយ គឺប្រើត្រកូលខាងប្តី។ ហេតុនេះ ក្នុងករណីថានៅពេលក្រោយការលែងលះ សហព័ទ្ធណាម្ខាងដែលបានប្តូរនាមត្រកូលរបស់ខ្លួនមានសិទ្ធិក្នុងការបន្តប្រើនាមត្រកូលរបស់សហព័ទ្ធមុនរបស់ខ្លួនបាន។ ដូច្នេះនៅពេលមានការលែងលះ មិនថាសហព័ទ្ធភាគីប្តីក្តី ឬភាគីប្រពន្ធក្តីមានសិទ្ធិក្នុងការប្រើនាមត្រកូលតាមឆន្ទៈរបស់ខ្លួនដោយគ្មានការបង្ខំពីនរណាម្នាក់ឡើយ។

**ឧបមាថា៖** លោក ព្រំ បញ្ញា បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនារីម្នាក់ឈ្មោះលោកស្រី ផាន់ បូផា។ នៅក្នុងករណីនេះ លោកស្រី ផាន់ បូផា អាចប្រើប្រាស់នាមត្រកូលរបស់ប្តីនាងបាន ដោយប្តូរទៅជាលោកស្រី ព្រំ បូផាវិញ។ ក្នុងករណីបែបនេះប្រសិនបើអ្នកទាំងពីរលែងលះគ្នាវិញ លោកស្រី បូផា អាចប្រើឈ្មោះ ព្រំ បូផា ដដែលក៏បាន ឬ ក៏ចង់ប្តូរទៅប្រើឈ្មោះដើមជា ផាន់ បូផា វិញក៏បានដែរ។

---

[១០៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៥០។

[១០៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៨១។

### ៤.១.១.៣. មានសិទ្ធិទាមទារអនុវត្តការផ្តល់អាហារកាតព្វកិច្ច

ប្រសិនបើករណីមានការលែងលះ ភាគីដែលគ្មានកំហុស ឬមានការខ្វះខាត បានសេចក្តីថា ភាគីដែលគ្មានកំហុសពុំមានទ្រព្យសម្បត្តិ ឬមុខរបរជាក់លាក់សម្រាប់ចិញ្ចឹមជីវិតខ្លួន អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ទៅតាមលទ្ធភាពរបស់ភាគីនោះ ឬតាមការព្រមព្រៀងរបស់ភាគី ហើយប្រសិនបើភាគីមិនឯកភាពគ្នានោះតុលាការនឹងជាអ្នកសម្រេចអំពីអាហារកិច្ចនោះ។[109] ក្នុងករណីនេះ តុលាការត្រូវពិនិត្យពិចារណាទៅលើប្រាក់បៀវត្ស លទ្ធភាពនៃការរកប្រាក់ចំណូល អាយុ សុខភាពរបស់ជននោះ ដើម្បីកំណត់ពីកម្រិតនៃអាហារកិច្ចដែលត្រូវបង់។ ក៏ប៉ុន្តែប្រសិនបើជនដែលទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត ជននោះនឹងលែងទទួលបានអាហារកិច្ចបន្តទៀតហើយ។

### ៤.១.១.៤. សិទ្ធិទទួលបានអត្តាធីនភាព

ចំពោះករណីដែលអនីតិជន បានរៀបអាពាហ៍ពិពាហ៍ដើម្បីទទួលបាននូវអត្តាធីនភាព ហើយក្រោយមកក៏បានលែងលះគ្នាវិញ ហើយការលែងលះនោះនៅក្នុងអំឡុងពេលដែលសហព័ទ្ធនោះនៅជាអនីតិជននៅឡើយ ក៏អត្តាធីនភាពនោះនៅតែមានដដែល មានន័យថាអត្តាធីនភាពដែលទទួលបានដោយការរៀបអាពាហ៍ពិពាហ៍មិនបានរលត់ទៅវិញនៅពេលដែលលែងលះនោះទេ។[110]

### ៤.១.២. ការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ

ញាតិ សំដៅទៅលើបុគ្គលដែលមានជាប់ខ្សែលោហិតផ្ទាល់ជាមួយបុគ្គលណាម្នាក់។ ទំនាក់ទំនងញាតិពន្ធ គឺកើតឡើងដោយសារចំណងអាពាហ៍ពិពាហ៍ដែលនាំឱ្យមានការភ្ជាប់គ្នាជាសាច់ញាតិមានមនោសញ្ចេតនាស្រឡាញ់រាប់អានគ្នា ចំពោះគ្រួសាររបស់សហព័ទ្ធទាំងសងខាង។ នៅពេលភាគីទាំងសងខាងបានលែងលះគ្នារួចហើយ ដោយសម្រេចកាត់ផ្តាច់អាពាហ៍ពិពាហ៍ និងដើរផ្លូវរៀងខ្លួន នោះទំនាក់ទំនងញាតិទាំងសងខាងក៏មិនបន្តទៀតដែរ ពោលគឺទំនាក់ទំនងញាតិពន្ធ ត្រូវបានបញ្ចប់ដោយការលែងលះគ្នា។[111] បើទោះបីជាយ៉ាងណាក៏ដោយ ក៏ទំនាក់ទំនងញាតិគឺមិនត្រូវបានកាត់ផ្តាច់ទាំងស្រុងឡើយ ប្រសិនបើនារីនោះមានកូន មានន័យថាទំនាក់ទំនងរវាងញាតិ និងកូននៅតែមានដដែលទោះភាគីទាំងសងខាងបានលែងលះគ្នាហើយក៏ដោយ។

---

[109] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា ៧៦

[110] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៦៨

[111] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៤១, កថាខណ្ឌទី១។

## ៤.២. ការបែងចែកទ្រព្យសម្បត្តិ

ចំពោះការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ គឺត្រូវធ្វើទៅតាមគោលការណ៍នៃការព្រមព្រៀងរបស់ភាគីទាំងសងខាងដោយគ្មានការបង្ខិតបង្ខំ។ ការបែងចែកទ្រព្យសម្បត្តិ នៅពេលលែងលះប្រព្រឹត្តទៅតាមពីររបៀបមានដូចជា ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រពព្យសម្បត្តិដែលកំណត់ដោយច្បាប់។

### ៤.២.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬក្រោយអាពាហ៍ពិពាហ៍បាន។[១១២] ការចុះកិច្ចសន្យាលើទ្រព្យសម្បត្តិរបស់សហព័ទ្ធ ជាកិច្ចសន្យាមួយដែលបង្ហាញអំពីការទុកចិត្ត ការជឿជាក់ មានភាពច្បាស់លាស់លើទំនាក់ទំនងទ្រព្យសម្បត្តិមុនពេលរៀបអាពាហ៍ពិពាហ៍ និងក្រោយពេលរៀបអាពាហ៍ពិពាហ៍។

គោលបំណងនៃកិច្ចសន្យានេះ គឺដើម្បីឱ្យប្តី ឬប្រពន្ធមានសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិ ទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និងដើម្បីបញ្ជាក់ឱ្យច្បាស់អំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្តីប្រពន្ធ ហើយបានតម្រូវឱ្យសហព័ទ្ធទាំងសងខាងគោរពទៅតាមការកំណត់ក្នុងកិច្ចសន្យា។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ[១១៣] ហើយត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីនៅក្រសួងយុត្តិធម៌។ នៅពេលភាគីទាំងសងខាងសម្រេចចិត្តលែងលះ នោះអានុភាពនៃកិច្ចសន្យានេះត្រូវបានយកមកអនុវត្តដើម្បីបែងចែកទ្រព្យសម្បត្តិឱ្យបានត្រឹមត្រូវដោយគោរពទៅតាមការកំណត់របស់ច្បាប់។ ប្រសិនបើប្តី ឬប្រពន្ធមិនបានធ្វើតាមកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ នោះទំនាក់ទំនងទ្រព្យសម្បត្តិ គឺត្រូវអនុលោមទៅតាមបទបញ្ញត្តិនៃកថាភាគទី២ (ប្រព័ន្ធទ្រព្យសម្បត្តិ ដែលកំណត់ដោយច្បាប់)។[១១៤]

### ៤.២.២. ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

ក្នុងករណីដែលភាគីលែងលះ មិនអាចពិភាក្សាចុះសម្រុងគ្នាលើការព្រមព្រៀងបែងបែកទ្រព្យសម្បត្តិ ឬមិនបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិជាមួយគ្នានោះទេ នោះតុលាការមានសិទ្ធិបែងចែកទ្រព្យសម្បត្តិទាំងនេះតាមបណ្តឹងទាមទារដោយអនុលោមតាមការកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។ ដោយផ្អែកតាមច្បាប់ដែលបានកំណត់ការបែងចែកទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ មាន ២ ប្រភេទគឺ ទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។

[១១២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៦៩, កថាខណ្ឌទី១។

[១១៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧០, កថាខណ្ឌទី១។

[១១៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៦៩, កថាខណ្ឌទី២។

#### ៤.២.២.១. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធណាម្ខាងមានមុនពេលរៀបអាពាហ៍ពិពាហ៍។ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ឬ ជាទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីទ្រព្យដោយឡែករបស់សហព័ទ្ធ នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[១១៥] នៅពេលលែងលះ សហព័ទ្ធនីមួយៗ ត្រូវទទួលបានទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនវិញ។[១១៦]

#### ៤.២.២.២. ទ្រព្យសម្បត្តិរួម

នៅក្នុងសង្គមបច្ចុប្បន្ន ប្តីគឺជាអ្នកដែលចេញទៅប្រកបការងារនៅខាងក្រៅ ហើយប្រពន្ធជាអ្នករ៉ាប់រង ឬទទួលបន្ទុកការងារផ្ទះគ្រប់យ៉ាងទាំងអស់។ ប៉ុន្តែការងារមេផ្ទះនេះ ក៏មានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារដែលធ្វើនៅក្រៅផ្ទះដែរ។[១១៧] ហេតុនេះហើយ បានជាទ្រព្យសម្បត្តិទាំងអស់ដែលរកបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍គឺជាទ្រព្យសម្បត្តិរួម។ ហើយប្រសិនបើមានការលែងលះ ទ្រព្យសម្បត្តិរួមនេះត្រូវធ្វើការបែងចែកជាពីរចំណែកស្មើគ្នាផងដែរ។ ទ្រព្យសម្បត្តិរួម គឺជាទ្រព្យទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលមានចែងក្នុងចំណុចខ និងគ នៃមាត្រា ៩៧៣[១១៨]។ ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ នោះត្រូវបែងចែកទ្រព្យសម្បត្តិតាមចំណុចនីមួយៗដូចត្រូវបានកំណត់ដោយច្បាប់។ ក្រៅពីទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិរួមសហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ភាគ២(មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម។ ផ្ទុយមកវិញ ប្រសិនបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ការថែរក្សា ឬការបង្កើនទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។[១១៩]

[១១៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧២។

[១១៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៨០, កថាខណ្ឌទី២។

[១១៧] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/០៧០៤/០០១, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា ៣៦, កថាខណ្ឌទី៣។

[១១៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៧៣។

[១១៩] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៩៨០, កថាខណ្ឌទី២, ចំណុច ខ។

### ៤.៣. អានុភាពលែងលះចំពោះកូន

ជាគោលការណ៍ ឪពុកម្ដាយគឺជាអ្នកដែលមានអំណាចមេបាលើកូនហើយឪពុកម្ដាយត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នាដើម្បីគ្រប់គ្រង មើលថែរក្សា ផ្គត់ផ្គង់ ទំនុកបម្រុង ការពារ និងផ្ដល់ដំបូន្មានដល់កូន។ ប៉ុន្តែបើមានការលែងលះ នាំឱ្យមានការបែងចែកនូវអំណាចមេបាក្នុងការគ្រប់គ្រងកូន និងសោហ៊ុយក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន។ ប្រសិនបើការលែងលះនោះជាការលែងលះដោយការព្រមព្រៀងនោះ ការកំណត់នូវអំណាចមេបាក៏ពុំសូវជួបបញ្ហាពិបាក និងមានលក្ខណៈស្មុគស្មាញដែរ។ ផ្ទុយទៅវិញបើការលែងលះនោះ គឺជាការលែងលះដោយគ្មានការព្រមព្រៀង នោះនឹងនាំឱ្យមានការដណ្ដើមនូវសិទ្ធិក្នុងការគ្រប់គ្រងកូន។ ប្រសិនបើមានការខ្វែងគំនិតគ្នាក្នុងការកំណត់នូវអំណាចមេបា នោះឪពុក ឬម្ដាយអាចដាក់ពាក្យប្ដឹងទៅតុលាការដើម្បីកំណត់នូវអំណាចមេបានេះ។ ទោះបីជាតុលាមានសិទ្ធិសម្រេចនូវអំណាចមេបា ឬចាត់ចែងទាក់ទងនឹងការបីបាច់ថែរក្សាកូនយ៉ាងណាក្ដីក៏ប៉ុន្តែ យោបល់របស់កូនត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងសមស្របទៅតាមអាយុ និងសភាពចាស់ទុំ[១២០]ផងដែរ។

#### ៤.៣.១. ការកំណត់អំណាចមេបា

នៅពេលលែងលះគ្នា ការសម្រេចអំពីអ្នកមានអំណាចមេបាគឺត្រូវកំណត់យកឪពុក ឬ ម្ដាយណាម្ខាងតាមការពិភាក្សារបស់ឪពុកម្ដាយ[១២១]។ ប៉ុន្តែបើការពិភាក្សានោះពុំបានសម្រេចទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូន។[១២២]ម្យ៉ាងវិញទៀត តុលាការត្រូវតែកំណត់អំពីអ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ ពោលគឺទោះបីជាមិនមានពាក្យសុំពីភាគីក៏ដោយ។[១២៣] មានន័យថាក្នុងករណីដែលឪពុកម្ដាយមិនអាចស្វែងរកដំណោះស្រាយតាមរយៈការជជែកពិភាក្សាគ្នាបានទេ ឬមានការឈ្លោះដណ្ដើមកូន ឬទោះបីជាក្នុងកម្មវត្ថុនៃពាក្យបណ្ដឹងលែងលះមិនបានទាមទារឱ្យតុលាការសម្រេចអំពីអំណាចមេបាក៏ដោយ ក៏តុលាការត្រូវតែជាអ្នកកំណត់អំពីអ្នកដែលមានអំណាចមេបាដោយសម្រេចផ្អែកទៅលើផលប្រយោជន៍របស់កូន។

---

[១២០] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, មាត្រា ២២, កថាខណ្ឌទី៤។

[១២១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១០៣៧, កថាខណ្ឌទី១។

[១២២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១០៣៧, កថាខណ្ឌទី៣។

[១២៣] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, មាត្រា ២២, កថាខណ្ឌទី១។

ក្នុងការសម្រេចនេះ ជាទូទៅតុលាការតែងតែពិនិត្យមើលទៅលើចំណុចមួយចំនួនដូចជា ការងារ និងប្រាក់ចំណូល ថាតើឪពុក ឬម្តាយណាម្ខាងដែលមានការងារ និងប្រាក់ចំណូលទៀងទាត់ជាងដើម្បីធានាដល់ការចិញ្ចឹមបីបាច់ថែរក្សា និងអប់រំកូន? ផ្ទះសម្បែង ថាតើឪពុក ឬម្តាយណាម្ខាងដែលមានលំនៅដ្ឋានច្បាស់លាស់សម្រាប់ឱ្យកូនរស់នៅសមរម្យ? តើទីលំនៅខាងណាដែលទីតាំងមានអំណោយផលជាងសម្រាប់ការរៀនសូត្ររបស់កូន? បុគ្គលិកលក្ខណៈ អាកប្បកិរិយា និងមនោសញ្ចេតនាចំពោះកូនរវាងឪពុក និងម្តាយ ថាតើមានខាងណា ដែលធ្លាប់ប្រើហិង្សាលើកូនដែរឬទេកន្លងមក? តើធ្លាប់បង្ហាញពីការយកចិត្តទុកដាក់លើកូនប៉ុណ្ណា?

ដូច្នេះ បើសិនជាតុលាការមើលទៅឃើញថា ឪពុក ឬ ម្តាយណាមួយ គិតតែពីដើរផឹកស៊ី ឬ លេងល្បែងស៊ីសង គ្មានគិតគូរធ្វើការរកស៊ី គ្មានផ្ទះសម្បែងត្រឹមត្រូវ ឬ ក៏ធ្លាប់ប្រើអំពើហិង្សាលើកូន តុលាការនឹងមិនឱ្យឪពុក ឬម្តាយនោះ ជាអ្នកទទួលសិទ្ធិគ្រប់គ្រងកូនទេ គឺប្រាកដជាត្រូវឱ្យទៅម្ខាងទៀតដែលមានការងារធ្វើច្បាស់លាស់ មានផ្ទះសម្បែងត្រឹមត្រូវ មានអត្តចរិកសមរម្យ មានការយកចិត្តទុកដាក់ក្នុងការបីបាច់ថែរក្សាកូន។ ដើម្បីសម្រេចកំណត់ថាតើឪពុក ឬម្តាយខាងណាដែលមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើជាអ្នកមានអំណាចមេបា ដូចនេះ តុលាការត្រូវថ្លឹងថ្លែងអំពីលទ្ធភាពរវាងឪពុកម្តាយដែលអាចផ្តល់ផលប្រយោជន៍ដល់កូនច្រើនជាងគេ។

ក្នុងករណីដែលកូនដល់វ័យមួយសមស្របអាចយល់ដឹង នោះអាចជ្រើសរើសឪពុក ឬម្តាយជាអ្នកមានអំណាចមេបាបាន ពោលគឺយោបល់របស់កូនតុលាការត្រូវបានយកទៅពិចារណាថ្លឹងថ្លែងសមស្របទៅតាមអាយុ និងសភាពចាស់ទុំរបស់កូន។[១២៤] លើសពីនេះ នៅក្នុងករណីឪពុកម្តាយលែងលះគ្នាមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។ ប៉ុន្តែនៅក្រោយកំណើតរបស់កូនអាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយបាន។[១២៥]

ចំពោះភាគីដែលមិនមានអំណាចមេបាលើកូនភាគីនោះមានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងកូន និងករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។[១២៦] ចំពោះសេចក្តីសម្រេចស្តីពីការចូលជួប និងប្រាស្រ័យទំនាក់ទំនង គឺតុលាការពិចារណាទៅលើសុខុមាលភាពរបស់កូនជាអាទិភាព។ ពោលគឺតុលាការពិនិត្យទៅលើស្ថានភាពផ្សេងដូចជា ទំនាក់ទំនងរវាងកូន និងឪពុកម្តាយនៅពេលដែលរស់នៅ

[១២៤] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០, មាត្រា ២២, កថាខណ្ឌទី៤។

[១២៥] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១០៣៧, កថាខណ្ឌទី២។

[១២៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១០៤០, កថាខណ្ឌទី១។

ជាមួយគ្នា អាយុ សុខភាព ស្ថានភាពផ្លូវចិត្តរបស់កូន បំណងរបស់ភាគីទាំងពីរ បំណងរបស់កូន និងស្ថានភាពផ្លូវចិត្តភាគីទាំងពីរជាដើម។

### ៤.៣.២. អាហារកាតព្វកិច្ចចំពោះកូន

អាហារកាតព្វកិច្ច គឺសំដៅទៅលើកិច្ចដែលត្រូវតែបំពេញតាមផ្លូវច្បាប់ ឬតាមតាមសេចក្ដីសម្រេចរបស់តុលាការដែលតម្រូវឱ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្ដល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងញាតិនឹងគ្នា។[១២៧]

អ្នកដែលមានអំណាចមេបាមានសិទ្ធិ និងមានករណីយកិច្ច ត្រូវចិញ្ចឹមបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។[១២៨] មាតាបិតា ជាអ្នកដែលមានកាតព្វកិច្ចចិញ្ចឹម និងបីបាច់ថែរក្សា មាតាដែលចាស់ជរាតាមទំនៀមទម្លាប់។[១២៩] ឪពុកម្ដាយដែលមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា។[១៣០]

នៅក្នុងករណីដែលមានជម្លោះ រវាងឪពុកម្ដាយនៅក្នុងការអនុវត្តអំណាចមេបាលើកូនដែលជាអនីតិជន ឪពុកម្ដាយនោះ ត្រូវជ្រើសរើសយកជម្រើសណាមួយដែលល្អបំផុតសម្រាប់កូនដោយធ្វើការពិចារណាបានហ្មត់ចត់ និងស្មោះត្រង់។ ករណីដែលឪពុក ឬ ម្ដាយ មិនអាចប្រើប្រាស់អំណាចមេបាបានទេ មានករណីដែលការប្រើប្រាស់អំណាចមេបាដោយសហការគ្នា មិនអាចធ្វើទៅបានដោយសារតែ ឪពុក ឬម្ដាយ បានបង់សតិបាត់ខ្លួន ឬមិនអាចទាក់ទងបានព្រមទាំងករណីដែល ឬត្រូវបានដកហូតអំណាចមេបា។

---

[១២៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, សន្ធានុក្រម លេខ២០២។

[១២៨] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១០៣៤។

[១២៩] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/០៧០៤/០០១, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា ៤៧។

[១៣០] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១០៣៦ កថាខណ្ឌទី១។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវ និងបកស្រាយទៅលើប្រធានបទស្តីអំពី "ការលែងលះនៅកម្ពុជា" រួចមក បានបង្ហាញឱ្យឃើញថា ចំណងអាពាហ៍ពិពាហ៍ដែលស្របតាមច្បាប់ត្រូវបានបង្កើតឡើងដោយកិច្ចសន្យាដ៏ឱឡារិកមួយដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដោយរួមសុខទុក្ខ និងសង្គ្រោះគ្នាទៅវិញទៅមក ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនឡើយ។ ដូចនេះ ចំណងអាពាហ៍ពិពាហ៍ពិតជាមានសារៈសំខាន់ណាស់ ព្រោះចំណងអាពាហ៍ពិពាហ៍នេះហើយ ដែលជាអ្នកដែលបង្កើតគ្រួសារមួយថ្មីដែលមានសុភមង្គល និងបង្កើតជនជានមនុស្សសម្រាប់ចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។ ជាមួយគ្នានេះ ក៏មានគ្រួសារមួយចំនួនដែលបានបង្កើតឡើងហើយ ក៏ប៉ុន្តែពួកគេមិនអាចរស់នៅដោយមានសុភមង្គលជាមួយគ្នាឡើយ ដោយសារតែមានជម្លោះឈ្លោះទាស់ទែងគ្នានៅក្នុងគ្រួសារមិនចេះចប់មិនចេះហើយ ដែលជាហេតុធ្វើឱ្យពួកគេឈានដល់ការបែកបាក់គ្នា និងអស់មនោសញ្ចេតនាស្នេហាជាមួយគ្នាតទៅទៀត។ ហេតុដូចនេះហើយ ទើបធ្វើឱ្យពួកគេមិនអាចរួមរស់នៅជាមួយគ្នាបន្តទៀតបាន និងឈានទៅដល់ការសម្រេចចិត្តលែងលះគ្នា។

ការលែងលះ គឺជាការកាត់ផ្តាច់នូវចំណងអាពាហ៍ពិពាហ៍របស់គ្រួសារមួយ។ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នការលែងលះត្រូវបានធ្វើឡើងដោយពីររបៀប នោះគឺ ការលែងលះដោយការព្រមព្រៀង ដែលមានចែងនៅក្នុងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ និងការលែងលះដោយមិនមានការព្រមព្រៀង ដែលមានចែងនៅក្នុងមាត្រា ៩៧៨ នៃច្បាប់ដដែលនេះ។ ទោះបីជាការលែងលះទាំងពីររបៀបខាងលើ ត្រូវបានទទួលស្គាល់ដោយប្រព័ន្ធច្បាប់ដូចគ្នាក៏ពិតមែន ក៏ប៉ុន្តែ នីតិវិធីនៃការលែងលះទាំងពីរនេះ ក៏មានចំណុចខុសប្លែកគ្នាមួយចំនួនផងដែរ។ ពោលគឺនីតិវិធីនៃការលែងលះដោយការព្រមព្រៀងមិនសូវមានភាពស្មុគស្មាញខ្លាំងដូចជានីតិវិធីនៃការលែងលះដោយគ្មានការព្រមព្រៀងនោះទេ។ ជាមួយគ្នានេះ មូលហេតុដែលនាំឱ្យមានការលែងលះគឺដោយសារតែភាពមិនស្មោះត្រង់របស់ភាគី ការរៀបការវ័យក្មេងពេក ការប្រចណ្ឌ ការប្រព្រឹត្តអំពើអបាយមុខជាដើម។ ជាមួយគ្នានេះដែរ បើទោះបីជាអ្នកទាំងពីរបានលែងលះគ្នាក៏ពិតមែន ក៏ប៉ុន្តែច្បាប់នៅតែរក្សា និងការពារផលប្រយោជន៍របស់ពួកគេ ព្រមទាំងរួមបញ្ចូលនូវការការពារនូវផលប្រយោជន៍របស់កូនផងដែរ។ ដោយយោងតាមការបកស្រាយ និងសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ការលែងលះបានជះឥទ្ធិពលដល់គូភាគីទាំងផលវិជ្ជមាន និងអវិជ្ជមាន។ ចំពោះផលវិជ្ជមាន មានន័យថា ភាគីណាមួយដែលទទួលរងសម្ពាធដោយសារតែចំណងអាពាហ៍ពិពាហ៍ដោយប្រការណាមួយ អាចមានសិទ្ធិសេរីភាព និងអាចរំដោះខ្លួនចេញពីបញ្ហាទាំងនេះ។ នៅត្រង់នេះមិនមែនមានន័យថាលើកទឹកចិត្តឱ្យមានការលែងលះនោះទេ ប៉ុន្តែជាការដែលឱ្យភាគីមានការគិតគូរ និងថ្លឹងថ្លែងឱ្យបានស៊ីជម្រៅដែលកើតមានឡើងចំពោះខ្លួនតែប៉ុណ្ណោះ។ ចំណែកឯ

ផលអវិជ្ជមានវិញ ឃើញថា ចំណងអាពាហ៍ពិពាហ៍ដែលបានសាងឡើងត្រូវបានកាត់ផ្តាច់ មិនតែប៉ុណ្ណោះថែម ទាំងបានការផ្តាច់នូវទំនាក់ទំនងញាតិពន្ធ ការបែងចែកទ្រព្យសម្បត្តិ និងមានការកំណត់អំណាចមេបាសម្រាប់ កូនជាដើម ។ បើទោះបីជាការលែងលះត្រូវបានពិនិត្យមើលឃើញពីផលប៉ះពាល់ និងការពារដល់ផលប្រយោជន៍ របស់គូភាគី ជាពិសេសកូនក៏ដោយ ក៏ការលែងលះនេះនៅតែបង្ហាញពីការជះឥទ្ធិពលខ្លាំងក្លាសម្រាប់កូនដែល ជាក្មេងៗ ដោយហេតុថា ការលែងលះរបស់ឪពុកម្តាយ និងធ្វើឱ្យកូនរបស់ខ្លួនខ្វះភាពកក់ក្តៅ ខ្វះការទូន្មានពី ឪពុកម្តាយ ដែលអាចឈានដល់ការប៉ះពាល់ដល់ផ្លូវចិត្តរបស់កូន ឬធ្វើឱ្យកូនអាចដើរផ្លូវខុសក៏មាន ដោយសារ តែមិនមានអ្នកគ្រប់គ្រង និងអប់រំណែនាំបានគ្រប់គ្រាន់។ ជាមួយគ្នានេះដែរ ការលែងលះក៏បានធ្វើឱ្យប៉ះពាល់ទៅ ដល់ប្រទេសជាតិផងដែរ ជាពិសេសទាក់ទងទៅនឹងធនធានមនុស្សសម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិ។

សរុបសេចក្តីមក ការលែងលះតាមរបៀបណាក៏ដោយសុទ្ធតែមានផលទៅដល់សង្គម គ្រួសារ និង បុគ្គលផ្ទាល់ ដូចនេះមុននឹងធ្វើការសម្រេចចិត្តក្នុងការលែងលះ ស្វាមីភរិយា គួរគប្បីធ្វើការស្វែងយល់ពីមូលហេតុ និងរកដំណោះស្រាយជាមួយគ្នាជាមួយសិន ជាជាងការទម្លាក់កំហុស និងការឈ្លោះទាស់ទែងគ្នាពីរឿងតូចឱ្យ ទៅជាធំ។ ម្យ៉ាងទៀត គូស្វាមីភរិយាគួរគប្បីមានការអត់ឱន និងអធ្យាស្រ័យចំពោះគ្នាទៅវិញទៅមកផងដែរ។

# អនុសាសន៍

# អនុសាសន៍

យោងទៅតាមស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ននេះ ខ្ញុំបាទ និងនាងខ្ញុំសង្កេតឃើញថានីតិវិធីនៃការលែងលះនៅកម្ពុជាយើងពិតជាមានភាពស្មុគស្មាញ ពោលគឺការលែងលះដែលអាចប្រព្រឹត្តទៅតាមផ្លូវច្បាប់ និងមានសុពលភាពគ្រប់គ្រាន់ក្នុងការអនុវត្ត គឺត្រូវតែដាក់ពាក្យសុំលែងលះ ឬ ពាក្យបណ្តឹង ទៅកាន់តុលាការជាដាច់ខាត។ បើពុំដូច្នេះទេ គឺចំណងអាពាហ៍ពិពាហ៍នោះមិនអាចរំលាយបានឡើយ ហើយវាពិតជាបានបង្កនូវផលអវិជ្ជមាន ដែលជះឥទ្ធិពលមិនល្អដល់សកម្មភាពរស់នៅប្រចាំថ្ងៃរបស់សហព័ទ្ធទាំងសងខាង ដោយសារតែការមានទម្លាប់យល់ខុស ឬ ខ្លាចបាត់បង់កិត្តិយសមិនហ៊ានដាក់ពាក្យបណ្តឹងសុំលែងលះទៅកាន់តុលាការ។ ជាពិសេសបានជះផលវិបាកជាច្រើនចំពោះទំនាក់ទំនងសង្គម ហើយបើសិនជាសង្គមមួយសម្បូរទៅដោយការលែងលះ នោះគេនឹងជួបនូវបញ្ហាច្រើន ជាពិសេសផលពិបាកដែលមានទៅលើស្មារតីរបស់កូនដែលជាទំពាំងស្នងឫស្សី។ មូលហេតុនេះហើយ ទើបខ្ញុំបាទ និងនាងខ្ញុំសូមការអនុញ្ញាតលើកឡើងនូវសំណូមពរ ផ្តល់មតិយោបល់ផ្ទាល់ខ្លួន និងផ្តល់អនុសាសន៍មួយចំនួនដើម្បីចូលរួមជាគំនិតឱ្យមានភាពប្រសើរឡើង។

- រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងដែលពាក់ព័ន្ធ ត្រូវខិតខំប្រឹងប្រែងផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ ដើម្បីឱ្យប្រជាពលរដ្ឋមានការយល់ដឹងអំពីនីតិវិធីនៃការលែងលះ និងយល់ដឹងពីផលប៉ះពាល់ដែលបណ្តាលមកពីការលែងលះ ដោយសារតែមានប្រជាពលរដ្ឋមួយចំនួន នៅពុំទាន់ដឹងពីបញ្ញត្តិច្បាប់។
- មន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ គប្បីព្យាយាមធ្វើការផ្សះផ្សាឱ្យអស់ពីលទ្ធភាព ពោលគឺគួរតែបន្តពង្រឹង និងខិតខំទៅលើការផ្សះផ្សាគូភាគី ដែលមានបំណងលែងលះគ្នានោះឱ្យមានការត្រូវរ៉ូវ និងសះជាគ្នាវិញ។ ចំណែកឯដំណាក់កាលផ្សះផ្សា នៅតុលាការវិញ តុលាការ គួរតែរិះរកគ្រប់មធ្យោបាយដែលពាក់ព័ន្ធនឹងការផ្សះផ្សាលើគូភាគី ដែលចង់ធ្វើការលែងលះ ដើម្បីឱ្យគូភាគីប្តូរចិត្តឈប់ចង់ធ្វើការលែងលះ ហើយមករស់នៅជាមួយគ្នាជាប្តីប្រពន្ធធម្មតាវិញ។
- ប្តីប្រពន្ធគប្បីមានការអត់ឱន យោគយល់ អធ្យាស្រ័យគ្នា ពោលគឺទំនាក់ទំនងប្តីប្រពន្ធ ដើម្បីកុំឱ្យមានការកើតឡើងនៃការលែងលះ និងដើម្បីឱ្យគ្រួសារមួយមានសេចក្តីសុខ គឺលុះត្រាតែភាគីប្តីប្រពន្ធគួរពិចារណាឱ្យបានត្រឹមត្រូវ គួរតែរស់នៅដោយភាពយោគយល់គ្នា ស្តាប់គ្នាទៅវិញទៅមក ប្តីត្រូវបំពេញកាតព្វកិច្ចជាប្តីល្អ ប្រពន្ធត្រូវបំពេញកាតព្វកិច្ចជាប្រពន្ធល្អ ត្រូវចេះ សហការគ្នា សង្គ្រោះគ្នាទៅវិញទៅមកដូចដែលមានចែងនៅក្នុងច្បាប់បំពេញឱ្យបានគ្រប់ជ្រុងជ្រោយ នោះគ្រួសារនឹងជួបសុខសុភមង្គល។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/០៧០៤/០០១, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០
- ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១០០៥/០៣១, ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៥
- ច្បាប់ស្តីពី ឯកពន្ធភាព, លេខ នស/ រកម/ ១០០៦/០២៦, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៦
- អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០

## ២. សៀវភៅ និងស្នាដៃនិពន្ធផ្សេងៗ

- បណ្ឌិត ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍, ភាគ ១, បោះពុម្ពឆ្នាំ២០២១
- ឯកសារសារណាបញ្ចប់ការសិក្សា ស្តីពីអានុភាពនៃការលែងលះ រៀបចំដោយ ឆយ ចំរើន ឆ្នាំ២០២២
- សាស្ត្រាចារ្យ មេធាវី ហេង ប៉ូរ៉ា, សៀវភៅនីតិអាពាហ៍ពិពាហ៍ និងគ្រួសារ, បោះពុម្ពឆ្នាំ២០២១
- វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត
- វចនានុក្រម តម្រាច្បាប់

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ ការលែងលះដោយមានការព្រមព្រៀង

- សំបុត្រអាពាហ៍ពិពាហ៍
- កិច្ចព្រមព្រៀងលែងលះ
- ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង
- ដីកាកោះ
- លិខិតអញ្ជើញ
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

## ឧបសម្ព័ន្ធទី២៖ ការលែងលះដោយគ្មានការព្រមព្រៀង

- ពាក្យបណ្ដឹងលែងលះ
- លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ
- ពាក្យស្នើសុំរូបមន្តអនុវត្តសាលក្រម
- រូបមន្តអនុវត្តនៃសាលក្រមស្ថាពរ
- ពាក្យស្នើសុំបញ្ជាក់សាលក្រមស្ថាពរ
- លិខិតបញ្ជាប់សាលក្រមស្ថាពរ
- គម្រូដីកាសម្រេច
- សាលក្រមលែងលះ

# ឧបសម្ព័ន្ធទី១

# ការលែងលះដោយមានការព្រមព្រៀង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង..........................................
ស្រុក ខណ្ឌ..........................................
ឃុំ សង្កាត់..........................................

លេខ..........................................
សៀវភៅអាពាហ៍ពិពាហ៍លេខ......................
ឆ្នាំ..........................................

# សំបុត្រអាពាហ៍ពិពាហ៍

| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
|---|---|---|---|
| នាមត្រកូល | | | |
| នាមខ្លួន | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | |
| | នាមខ្លួន | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ | | | |
| អំពីឪពុក ម្តាយ | | ខាងប្តី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក | | | |
| ជាអក្សរឡាតាំង | | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |
| នាមត្រកូល និង នាមខ្លួនម្តាយ | | | |
| ជាអក្សរឡាតាំង | | | |
| សញ្ជាតិ | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | |

ធ្វើនៅ.............................. ថ្ងៃទី........ ខែ.......... ឆ្នាំ...............

**មន្ត្រីអត្រានុកូលដ្ឋាន**

# កិច្ចព្រមព្រៀងលែងលះ

រវាង

លោកស្រី

(ភាគី "ក")

និង

លោក

(ភាគី "ខ")

កាលបរិច្ឆេទ៖ ថ្ងៃទី ខែ ឆ្នាំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចព្រមព្រៀងលែងលះ</u>

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅថ្ងៃទី ....... ខែ ...... ឆ្នាំ..........រវាង៖

ឈ្មោះ ................. ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត:....................... មានទីលំនៅផ្ទះលេខ: ........... ផ្លូវ................ សង្កាត់ ............... ខណ្ឌ ............... រាជធនីភ្នំពេញ ភាគីប្តីតទៅនេះហៅកាត់ថា **ភាគី"ក"**។

**<u>និង</u>**

ឈ្មោះ .................. ភេទ ស្រី ថ្ងៃខែឆ្នាំកំណើត: .................... មានទីលំនៅផ្ទះលេខ: .............. ផ្លូវ ............... សង្កាត់................. ខណ្ឌ ............... រាជធានីភ្នំពេញ ។

**<u>បុព្វកថា</u>**

**ដោយហេតុថា**: **ភាគី "ក"** និង **ភាគី "ខ"** បានរៀបការជាមួយគ្នានៅឆ្នាំ ........... និងបានចុះសំបុត្ររអាពាហ៍ពិពាហ៍នៅថ្ងៃទី......... ខែ ......... ឆ្នាំ ......... នៅសាលាខណ្ឌ ........... រាជធានីភ្នំពេញ ហើយបង្កើតបានកូនចំនួន .......... នាក់ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: ២១.០១.២០០១។ ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធនេះតែងតែមានភាពរកាំរកូស ពុំមានសេចក្តីសុខក្នុងគ្រួសារ មិនអាចរស់នៅជាមួយគ្នាតទៅទៀតបាន ហើយយើងខ្ញុំក៏អស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្តីប្រពន្ធជាមួយគ្នា និង ព្រមព្រៀងលែងលះឈប់រស់នៅជាមួយគ្នាជាប្តីប្រពន្ធចាប់ពីពេលនេះតទៅ ។

**<u>ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមកភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោយ</u>**:

**<u>ប្រការ១</u>**: **ភាគី "ក"** និង **ភាគី "ខ"** ឯកភាពយល់ព្រមលែងលះឈប់រស់នៅជាមួយគ្នាជាប្តីប្រពន្ធដោយស្ម័គ្រចិត្តពីថ្ងៃចុះហត្ថលេខា និងផ្តិចមេដៃនេះតទៅ ។
ទ្រព្យសម្បិត្តរួមមាន៖
មានកូនឈ្មោះ .............. ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: ....................................................។
១-ដីទំហំ ..... ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: .....................ចុះថ្ងៃទី................ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសុរិយោដី .........................។
២-ដីទំហំ ........... ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ................. ចុះថ្ងៃទី........... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសុរិយោដី ..........................។
៣-ដីទំហំ ......... ម៉ែត្រការ៉េ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ:.................. ចុះថ្ងៃទី ................... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សុរិយោដី ................។

**<u>ប្រការ២</u>**: **ភាគី "ខ"** យល់ព្រមប្រគល់សិទ្ធិគ្រប់គ្រង និងជាអ្នកមានអំណាចមេបាលើកូនឈ្មោះ .............. ............. ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: ..........................អោយ**ភាគី "ក"** ។**ភាគី "ក"** ឯកភាពតាម**ភាគី "ខ"** ។

**<u>ប្រការ៣</u>**: **ភាគី "ក"** មិនទាមទារអោយ **ភាគី "ខ"**បង់អាហារកិច្ចចិញ្ចឹមបីបាច់កូនទេ ។ **ភាគី "ខ"** គ្មានសិទ្ធិគ្រប់គ្រង និងគ្មានអំណាចមេបាលើកូន តែមានសិទ្ធិជួលសួរសុខទុកកូនតាមច្បាប់ស្តីពីអាហ៍ពិពាហ៍ និងគ្រួសារហើយ **ភាគី "ក"** ដែលមានសិទ្ធិគ្រប់គ្រង និងជាអ្នកមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ **ភាគី "ខ"** ក្នុងការមកជួបកូន ។

<u>**ប្រការ៤**</u>: **ភាគី "ក"** និង **ភាគី "ខ"** យល់ព្រមបែងចែកទ្រព្យសម្បត្តិរួមដូចតទៅ :

-ដីទំហំ ........ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុលេខ: ........... ចុះថ្ងៃទី ........ ........... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសុរិយោដី ...................................។

(មានសិទ្ធិចាត់ចែង គ្រប់គ្រង និងអាស្រ័យផល ។

**ភាគី "ខ"** ទទួលបាន:

-ដីទំហំ ........ ម៉ែត្រការ៉េ ដែលមានសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ: .................. ចុះថ្ងៃទី........ ....................... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សុរិយោដី .....................។

(មានសិទ្ធិចាត់ចែង គ្រប់គ្រង និងអាស្រ័យផល នៅពេលមានអាយុ ៣០ ឆ្នាំ )

ក្នុងកំឡុងពេលបច្ចុប្បន្នរហូតដល់អាយុក្រោម ៣០ ឆ្នាំ **ភាគី "ក"** ជាអ្នកថែរក្សា និងជាអ្នកមើលខុសត្រូវជូស ។

ធ្វើនៅថ្ងៃទី ...... ខែ..... ឆ្នាំ.......

| **បានឃើញ និងបញ្ជាក់ថា** | **ស្នាមមេដៃស្តាំ** | **ស្នាមមេដៃស្តាំ** |
|---|---|---|
| គូភាគីពិតជាបានផ្តិចមេដៃស្តាំចំពោះ | **ភាគី "ក"** | **ភាគី "ខ"** |
| មុខមេធាវីពិតប្រាកដ ។ | | |
| **ហត្ថលេខា និងត្រា** | | |

គំរូ
ពាក្យសុំលែងលះ
ដោយព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន...............................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន...............................................................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូង**..........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖

១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សមគ្គសង្វាស់ តាមផ្លូវច្បាប់ ។

២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........

៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខ
កូនតាមច្បាប់កំណត់ ។

៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

..........................................................................................................

..........................................................................................................

៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

..........................................................................................................

..........................................................................................................

៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)..........................................................................

..........................................................................................................

៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ)..........................................................................

..........................................................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។

- ..........................................................................................................

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ យើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាសង្កាត់............................ តាមលិខិតលេខ............ ចុះថ្ងៃទី.................... ។ នៅពេលនេះ យើងខ្ញុំបានអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធនឹងគ្នាទៀតហើយ ។ យើងខ្ញុំបានព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនិងសម្រេចតាមការស្នើសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី........ ខែ........ ឆ្នាំ២០១.....

| | |
|---|---|
| ស្នាមមេដៃស្តាំចុងចម្លើយ | ស្នាមមេដៃស្តាំដើមចោទ |
| (ស្នាមមេដៃស្តាំ) | (ស្នាមមេដៃស្តាំ) |
| .................. | ..................... |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រឡាបញ្ជី

សាលាដំបូងរាជធានីភ្នំពេញ

**សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹង**

**លេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ**

# ដីកាកោះ

**យើង** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

- **អញ្ជើញ** ៖ លោកស្រី កើតថ្ងៃទី ខែ ឆ្នាំ
  ជនជាតិខ្មែរ ជាភាគីម្ខាងទៀត
- **អាសយដ្ឋាន** ៖ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ
- **ឱ្យចូលខ្លួនទៅកាន់** ៖ សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់ ជាន់ទី**
- **នៅថ្ងៃទី** ៖ ថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង និង នាទីព្រឹក
- **ដើម្បី** ៖ ចូលរួមនីតិវិធីសាកសួរ
- **ពីដំណើររឿង** ៖ សុំឱ្យតុលាការចេញដីកាសម្រេចលែងលះតាមការព្រមព្រៀង។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ កើត ខែ ឆ្នាំ ត្រីស័ក ព.ស.២៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រឡាបញ្ជី

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្តឹង

លេខ៖ ចុះថ្ងៃទី ខែ ឆ្នាំ

# លិខិតអញ្ជើញ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី ខែ ឆ្នាំ របស់លោក និងលោក ។

- អញ្ជើញ ៖ លោក និងលោក ជាមេធាវីតំណាងដោយអាណត្តិឱ្យភាគីអ្នកដាក់ពាក្យសុំ
- អាសយដ្ឋាន ៖ លេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ
- ឱ្យចូលខ្លួនទៅកាន់ ៖ សាលាដំបូងរាជធានីភ្នំពេញ **បន្ទប់ ជាន់ទី**
- នៅថ្ងៃទី ៖ ថ្ងៃទី ខែ ឆ្នាំ វេលាម៉ោង និង នាទី**ព្រឹក**
- ដើម្បី ៖ ចូលរួមនីតិវិធីសាកសួរ
- ពីដំណើររឿង ៖ សុំឱ្យតុលាការចេញដីកាសម្រេចលែងលះតាមការព្រមព្រៀង។

សាមីខ្លួនត្រូវអញ្ជើញតាមលិខិតអញ្ជើញនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

ចៅក្រម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំបាទឈ្មោះ ជនជាតិ កើតថ្ងៃទី ខែ ឆ្នាំ កាន់លិខិតឆ្លងដែន សញ្ជាតិ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានស្ថិតនៅ ផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ (**អាណត្តិទាយក**)។

## សូមប្រគល់សិទ្ធិជូន

លោកមេធាវី អត្តលេខ ជាមេធាវី នៃក្រុមមេធាវី ដែលមានការិយាល័យនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិរបស់ខ្ញុំបាទ នៅក្នុងរឿងក្តីលែងលះ។ តាមរយៈលិខិតប្រគល់សិទ្ធិនេះ លោកមេធាវី មានសិទ្ធិបំពេញរាល់កិច្ចការដូចខាងក្រោម៖

- មានសិទ្ធិអំណាចពេញលេញនៅក្នុងការធ្វើសកម្មភាពតំណាងឱ្យខ្ញុំបាទ។
- ដាក់ពាក្យបណ្តឹង ដាក់ពាក្យសុំ ដកពាក្យបណ្តឹង ដកពាក្យសុំ ផ្សះផ្សា សម្រុះសម្រួល បោះបង់ឬទទួលស្គាល់ការទាមទារ ឬ ដកខ្លួនចេញពីបណ្តឹងដែលខ្លួនចូលរួមអន្តរាគមន៍ ឬ ទទួលបណ្តឹងដើម្បីផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ។
- ការតែងតាំងអនុតំណាង។
- ការប្តឹងតវ៉ា/ការប្តឹងទាស់/ការប្តឹងជំទាស់/ការប្តឹងឧទ្ធរណ៍/ការប្តឹងសាទុក្ខ។

**បញ្ជាក់៖** រាល់សោហ៊ុយចំណាយលើការអនុវត្តភារកិច្ចនេះ និងបង់ពន្ធផ្សេងៗនៅក្នុងបណ្តឹង ឬ ពាក្យសុំនេះ ជាបន្ទុករបស់ខ្ញុំបាទ។ ក្នុងករណីមិនបានគោរពតាមកាតព្វកិច្ចនេះ ខ្ញុំបាទសុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់។

លិខិតប្រគល់សិទ្ធិនេះ មានអានុភាពចាប់ពីថ្ងៃផ្តិតស្នាមមេដៃនេះតទៅ ៕

បានឃើញ និងយល់ព្រម
ធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យ
លោក តាមនីតិវិធីច្បាប់។
ថ្ងៃទី ខែ ឆ្នាំ
**មេធាវី**

ថ្ងៃទី ខែ ឆ្នាំ
**ស្នាមមេដៃស្តាំ**

លោក

# ឧបសម្ព័ន្ធទី២

# ការលែងលះដោយគ្មានការព្រមព្រៀង

ទំរង់
ពាក្យសុំលែងលះ
គូភាគីព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹងលែងលះ

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ......... អាយុ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន.........................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ......... អាយុ...... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន.........................................................។

**សូមគោរពជូនមក**

**ឯកឧត្តមប្រធានសាលាដំបូង**........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖

១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សម្ពន្ធសង្វាស់ តាមផ្លូវច្បាប់ ។

២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ.........

៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។

៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

.............................................................................................

៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

.............................................................................................

៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ).......................................................................

៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ).......................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។
- .............................................................................................

កាលពីថ្ងៃទី.....ខែ....ឆ្នាំ..... នាងខ្ញុំ/ខ្ញុំបាទ បាចចអាពាហ៍ពិពាហ៍ ជាឈ្មោះ........................ ។ ប៉ុន្តែក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ឈ្មោះនេះ (សរសេរពីមូលហេតុដែលនាំឲ្យមានការទាមទារ) .......................
.................................................................................................................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងសម្រេចតាមការប្តឹងសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................ ថ្ងៃទី........ ខែ........ ឆ្នាំ២០១.....

ស្នាមមេដៃស្តាំចុងចម្លើយ
(ស្នាមមេដៃស្តាំ)

ស្នាមមេដៃស្តាំដើមចោទ
(ស្នាមមេដៃស្តាំ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ

**អាណត្តិទាយក៖** ឈ្មោះ.................................. ភេទ.................. កាន់អត្តសញ្ញាណប័ណ្ណលេខ..........................
ចុះថ្ងៃទី......ខែ.........ឆ្នាំ.............. មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ.................... ភូមិ..............
ឃុំ/សង្កាត់........................ ស្រុក/ខណ្ឌ.......................... រាជធានី/ខេត្ត ....................... ។

**តាមរយៈលិខិតនេះ ខ្ញុំសូមប្រគល់សិទ្ធិតំណាងដោយអាណត្តិជូនមេធាវីធ្វើសកម្មភាពតាមផ្លូវច្បាប់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធរឿងក្តីដូចមាន កំណត់ដូចខាងក្រោម៖**

**មេធាវី** : **មេធាវី នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ**
**ការិយាល័យ** : **ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ** (C.I.C LAW GROUP)
**អាសយដ្ឋាន** : អគារលេខ៤៩៣៥ ផ្លូវលេខ១០០៣ ស្ថិតក្នុងភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ ។

**១. រឿងក្តី** (..............................................)

**ក. គូភាគី:** ..............................................................................................

**ខ. យុត្តាធិការ:** ..........................................................................................

**គ. ការបង្ហាញរឿងក្តី:** ....................................................................................

**២. ចំណុចដែលត្រូវផ្ទេរផ្ដាក់ឲ្យធ្វើជាអាណត្តិ:**

ក. ប្រគល់សិទ្ធិពេញលេញក្នុងការធ្វើសកម្មភាពតំណាងឲ្យអាណត្តិទាយក ឈ្មោះ.................................។
ខ. ដាក់ និងដកពាក្យបណ្តឹង បណ្តឹងតប ពាក្យសុំ ពាក្យតវ៉ា ទាំងស្រុង ឬមួយផ្នែក។
គ. ការដាក់ ឬដកខ្លួនចេញពីបណ្តឹងអន្តរាគមន៍ ការទទួលស្គាល់ ឬការបដិសេធការទាមទារ ការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ចូលរួមចរចា ធ្វើការផ្សះផ្សា ការសះជា ឬការដោះស្រាយក្រៅប្រព័ន្ធតុលាការ។
ឃ. ការធ្វើបណ្តឹងឧបាស្រ័យ ឬបណ្តឹងតវ៉ាចំពោះការលើកចោល ឬអាចទទួលបណ្តឹងឧបាស្រ័យ។
ង. ធ្វើសេចក្តីថ្លែងការណ៍ទាមទារ ការឆ្លើយដោះសារចំពោះបណ្តឹង ឬបណ្តឹងតប។
ច. ការចាត់តាំងអនុតំណាងដោយអាណត្តិជាមេធាវី ឬ ការទទួលនូវការសង និងការទូទាត់ផ្សេងៗ។
ឆ. រាល់សកម្មភាពរបស់មេធាវីតំណាងដោយអាណត្តិ ធ្វើក្នុងនាមអាណត្តិទាយក និងដើម្បីផលប្រយោជន៍របស់អាណត្តិទាយក។

**ចំណាំ៖** ការចំណាយលើពន្ធតុលាការ និងសោហ៊ុយផ្សេងៗ ទៀតក្នុងបណ្តាកិច្ចការខាងលើ ជាបន្ទុករបស់អាណត្តិទាយកទាំងស្រុង។ក្នុងករណីមិនគោរពកាតព្វកិច្ចនេះអាណត្តិទាយកសុខចិត្តទទួលខុសត្រូវនូវរាល់ការខាតបង់ផលប្រយោជន៍នានា ដោយខ្លួនឯងផ្ទាល់ ។

ធ្វើនៅ........................ ថ្ងៃទី........ ខែ........... ឆ្នាំ...............

**បានឃើញ និងយល់ព្រម** **ស្នាមមេដៃស្ដាំអាណត្តិទាយក**

ទទួលសិទ្ធិតំណាងដោយអាណត្តិឲ្យអាណត្តិទាយក
ឈ្មោះ.............................

ធ្វើនៅ..................... ថ្ងៃទី....... ខែ.......... ឆ្នាំ...............

**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំរូបមន្តអនុវត្តសាលក្រម**

ខ្ញុំបាទ/នាងឈ្មោះខ្ញុំ.............ភេទ........ កើតថ្ងៃទី.......ខែ.........ឆ្នាំ.......មាន អាសយដ្ឋានភូមិ......... ឃុំ/សង្កាត់............ស្រុក/ខណ្ឌ.............ខេត្តកណ្ដាល។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងខេត្តកណ្ដាល**

**កម្មវត្ថុ៖** សំណើរសុំរូបមន្តសាលក្រមរដ្ឋប្បវេណីលេខ............ចុះថ្ងៃទី........ខែ.......ឆ្នាំ.........តាម លិខិតបញ្ជាក់សាលក្រមស្ថាពរលេខ.............ចុះថ្ងៃទី.......... ខែ.........ឆ្នាំ..........។

**យោង៖** -សំណុំរឿងរដ្ឋប្បវេណី លេខ........ចុះថ្ងៃទី......ខែ.......ឆ្នាំ......របស់សាលាដំបូងខេត្តកណ្ដាល

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើនេះ សូមឯកឧត្តមប្រធានមេត្តាជ្រាបថា៖ សាលក្រមរដ្ឋប្បវេណី............ចុះថ្ងៃទី........ខែ.......ឆ្នាំ..........បានចូលជាស្ថាពរហើយ តាមលិខិតបញ្ជាក់សាលក្រមស្ថាពរលេខ............ចុះថ្ងៃទី........ខែ.......ឆ្នាំ.........។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាតតាមការស្នើសុំក្នុងកម្មវត្ថុខាងលើ ដោយក្តីអនុគ្រោះ ដើម្បីឱ្យខ្ញុំបាទ/នាងខ្ញុំអាចយកទៅប្រើប្រាស់បានតាមផ្លូវច្បាប់។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ...........................ខែ................ ឆ្នាំ......... ព.ស..........

ខេត្តកណ្ដាល, ថ្ងៃទី............ ខែ............ ឆ្នាំ..........

ស្នាមមេដៃ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

## <u>រូបមន្តអនុវត្ត នៃសាលក្រមស្ថាពរ</u>

លេខ: .......................................

ចុះថ្ងៃទី....... ខែ......... ឆ្នាំ

យើង **.............**ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

-បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាដែលបាន ប្រកាសឱ្យប្រើតាមរាជក្រម លេខ **នស/រកម/០៧០៦/០២១** ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៦។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ**.........**ចុះថ្ងៃទី..... ខែ.......ឆ្នាំ......... របស់សាលាដំបូងខេត្តកណ្ដាល។

-បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ**.........**ចុះថ្ងៃទី..... ខែ.......ឆ្នាំ........របស់សាលាដំបូងខេត្តកណ្ដាល។

-បានឃើញពាក្យសុំរូបអនុវត្តនៃសាលក្រមស្ថាពរ ចុះថ្ងៃទី.... ខែ.... ឆ្នាំ.........របស់ឈ្មោះ **.................**។

សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តមានដូចខាងក្រោម៖

-ដើមចោទនៃការអនុវត្តឈ្មោះ **...........** ភេទ...... អាយុ..... មានទីលំនៅភូមិ........... ឃុំ/សង្កាត់ ............ស្រុក/ក្រុង......................ខេត្តកណ្ដាល។

អាចអនុវត្តដោយបង្ខំទារយក តាមសាលក្រមរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី......... ខែ...... ឆ្នាំ........ របស់សាលាដំបូងខេត្តកណ្ដាល។

-ចុងចម្លើយនៃការអនុវត្តឈ្មោះ **...........** ភេទ...... អាយុ..... មានទីលំនៅភូមិ........... ឃុំ/សង្កាត់ ..........ស្រុក/ក្រុង......................ខេត្តកណ្ដាល។

តាមសេចក្ដីសម្រេចបញ្ចប់ នៃសាលក្រមរដ្ឋប្បវេណីលេខ .......... ចុះថ្ងៃទី...... ខែ....... ឆ្នាំ.......របស់សាលាដំបូងខេត្តកណ្ដាល ត្រង់សេចក្ដីសម្រេចទាំងមូល អាចអនុវត្តបាន។

**សេចក្ដីនេះព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំឱ្យសម្រេចតាមសាលក្រមនេះ និងឱ្យអាជ្ញាធរសាធារណៈអនុវត្តសាលក្រមនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

ថ្ងៃ.................... ខែ........... ឆ្នាំ......... ព.ស .........

ខេត្តកណ្ដាល, ថ្ងៃទី......... ខែ............. ឆ្នាំ............

**ក្រឡាបញ្ជី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំបញ្ជាក់សាលក្រមស្ថាពរ**

ខ្ញុំបាទ/នាងឈ្មោះខ្ញុំ..........ភេទ......កើតថ្ងៃទី.........ខែ............ឆ្នាំ........មាន អាសយដ្ឋានភូមិ.............ឃុំ/សង្កាត់..............ស្រុក/ខណ្ឌ...............ខេត្តកណ្តាល។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងខេត្តកណ្តាល**

**កម្មវត្ថុះ** ស្នើសុំបញ្ជាក់លើសាលក្រមរដ្ឋប្បវេណីស្ថាពរ លេខ...........ចុះថ្ងៃទី........ខែ.......ឆ្នាំ .......របស់សាលាដំបូងខេត្តកណ្តាល។

**យោងៈ** -សំណុំរឿងរដ្ឋប្បវេណី លេខ........ចុះថ្ងៃទី.....ខែ.....ឆ្នាំ......របស់សាលាដំបូងខេត្តកណ្តាល។

-សាលក្រមរដ្ឋប្បវេណីលេខ.........ចុះថ្ងៃទី.....ខែ.......ឆ្នាំ.....របស់សាលាដំបូងខេត្តកណ្តាល។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា៖ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី........ខែ.......ឆ្នាំ....... របស់សាលាដំបូងខេត្តកណ្តាល បានបើកសវនាការ និងប្រកាសសាលក្រមរដ្ឋប្បវេណី លេខ............ចុះថ្ងៃទី.....ខែ.......ឆ្នាំ.......រួចមកហើយ ដោយបច្ចុប្បន្នពុំមានភាគីណាមួយប្តឹងតវ៉ានឹងសាលក្រមខាងលើនោះទេ។

អាស្រ័យហេតុនេះសូម **ឯកឧត្តមប្រធាន** ទទួលនូវពាក្យស្នើសុំរបស់ខ្ញុំបាទ/នាងខ្ញុំ និងចេញលិខិតបញ្ជាក់សាលក្រមស្ថាពរដើម្បីខ្ញុំបាទ/នាងខ្ញុំយកទៅប្រើប្រាស់បន្តតាមនីតិវិធី។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ............................ខែ................ ឆ្នាំ............. ព.ស...........

ខេត្តកណ្តាល, ថ្ងៃទី............. ខែ............ ឆ្នាំ.........

ស្នាមមេដៃ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

**លេខ៖** ....................

## លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម

យើង ............................ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**-បានឃើញ** មាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**-បានឃើញ** សំណុំរឿងរដ្ឋប្បវេណី លេខ ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** សាលក្រមរដ្ឋប្បវេណី លេខ ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ។

**-បានឃើញ** របាយការណ៍អំពីការបញ្ជូន ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ស្តីពីការបញ្ជូនសេចក្តីចម្លងនៃសាលក្រមរដ្ឋប្បវេណី លេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ បញ្ជាក់ថាដើមចោទឈ្មោះ ... បានទទួលនៅថ្ងៃទី ... ខែ ... ឆ្នាំ ... ។

**-បានឃើញ** ពាក្យសុំឱ្យបញ្ជាក់ការចូលស្ថាពរនៃសាលក្រម ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់លោក............ មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ដែលមានខ្លឹមសារសុំបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ។

### បញ្ជាក់ថា

**១**-សាលក្រមរដ្ឋប្បវេណី លេខ ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលជាស្ថាពរគិតចាប់ពីថ្ងៃទី ... ខែ ... ឆ្នាំ... រួចហើយ។

**២**-លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមនេះ ចេញឱ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់។

ថ្ងៃ............ ខែ........... ឆ្នាំ..... ... ស័ក ព.ស. .......
រាជធានីភ្នំពេញ ថ្ងៃទី ........ ខែ ........ ឆ្នាំ..........
**ក្រឡាបញ្ជី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

លេខ: ............................./ឈ

ចុះថ្ងៃទី......... ខែ.........ឆ្នាំ..............

## <u>លិខិតបញ្ជាក់សាលក្រមចូលជាស្ថាពរ</u>

យើង................. ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ៖................ចុះថ្ងៃទី........ ខែ..........ឆ្នាំ............ របស់សាលាដំបូង ខេត្តកណ្តាល។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ៖ ................ចុះថ្ងៃទី........ ខែ..........ឆ្នាំ.......... របស់សាលាដំបូងខេត្តកណ្តាល។

បានឃើញ ពាក្យសុំបញ្ជាក់សាលក្រមស្ថាពរ ចុះថ្ងៃទី..... ខែ..... ឆ្នាំ...........របស់ឈ្មោះ ......................... ។

**សូមបញ្ជាក់ថា សាលក្រមរដ្ឋប្បវេណីលេខ៖ ................ចុះថ្ងៃទី........ ខែ..........ឆ្នាំ............ របស់សាលាដំបូងខេត្តកណ្តាល។**

**បានចូលស្ថាពរចាប់ពីថ្ងៃទី.....ខែ......ឆ្នាំ....... នេះតទៅដោយគូភាគីមិនបានចូលមកប្តឹងតវ៉ាក្នុងកំណត់ច្បាប់។**

ថ្ងៃ..................... ខែ............. ឆ្នាំ............ ព.ស ..........

ខេត្តកណ្តាល, ថ្ងៃទី............ ខែ............ ឆ្នាំ............

ក្រឡាបញ្ជី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**ដីកាសម្រេច**

-លេខ៖.................
ចុះថ្ងៃទី....... ខែ.......... ឆ្នាំ.....
-សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង
លេខ....... ចុះថ្ងៃទី... ខែ ... ឆ្នាំ .......

## ដីកាសម្រេច
## រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

យើង ............................ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

ដោយមានលោក ............................ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**បានឃើញ** មាត្រា៣ និងមាត្រាពាក់ព័ន្ធនឹងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

**បានឃើញ** តារាងឧបសម្ព័ន្ធផ្នែកទី៤ ចំណុច៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង លេខ......... ចុះថ្ងៃទី....... ខែ ....... ឆ្នាំ ......... របស់សាលាដំបូងរាជធានីភ្នំពេញ

**បានឃើញ** ពាក្យសុំលែងលះដោយការព្រមព្រៀងចុះថ្ងៃទី....... ខែ ....... ឆ្នាំ ......... របស់មេធាវី............ ជាមេធាវីតំណាងដោយអាណត្តិឱ្យអ្នកដាក់ពាក្យសុំឈ្មោះ...................

**-អ្នកដាក់ពាក្យសុំ**៖ លោក ............ ថ្ងៃខែឆ្នាំកំណើត....................... ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ...................... ចុះថ្ងៃទី....... ខែ ....... ឆ្នាំ ......... មានអាសយដ្ឋានស្ថិតនៅ ..............................។

**-មេធាវីតំណាងដោយអាណត្តិ**៖

**-ភាគីម្ខាងទៀត**៖ លោកស្រី .......... ខែឆ្នាំកំណើត.......................... ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ...................... ចុះថ្ងៃទី....... ខែ ....... ឆ្នាំ ......... មានអាសយដ្ឋានស្ថិតនៅ ..............................។

## អង្គហេតុនិងចំណុចវិវាទ

**១. ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំឱ្យតុលាការចេញ**

១.១ ស្នើសុំលែងលះរវាងភាគីអ្នកដាក់ពាក្យសុំ ..................... និងភាគីម្ខាងទៀត................។

១.២ កំណត់យកអ្នកដាក់ពាក្យសុំ ................ ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ ................. ភេទ... ថ្ងៃខែឆ្នាំកំណើត.........................។

១.៣ បែងចែកទ្រព្យសម្បត្តិរួមឱ្យទៅភាគី ........................... ស្របតាមការព្រមព្រៀងគ្នារបស់គូភាគី។

១.៤ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់...................។

**២. អំពីរឿងក្តី**

ភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី ....... ខែ ........ ឆ្នាំ .......... និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ....... ចុះថ្ងៃទី......... ខែ......... ឆ្នាំ............ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ................។ ......................................................។

៣. **អង្គហេតុដែលអះអាងដោយអ្នកដាក់ពាក្យសុំ៖**

អ្នកដាក់ពាក្យសុំ ...................... បានអះអាងនាពេលសាកសួរថា៖......................................
......................................................................

៤. **អង្គហេតុដែលអះអាងដោយភាគីម្ខាងទៀត៖**

ភាគីម្ខាងទៀត ................... បានអះអាងនាពេលសាកសួរថា៖......................................
......................................................................

៥. **អង្គហេតុដែលគ្មានវិវាទ**

-ភាគីបានឯកភាពគ្នាលែងលះជាមួយគ្នាដោយស្ម័គ្រចិត្ត។

-ភាគីបានឯកភាពគ្នាប្រគល់សិទ្ធិអំណាចមេបាឱ្យអ្នកដាក់ពាក្យសុំ .......................... ។

-ភាគីបានឯកភាពគ្នាបែងចែកទ្រព្យសម្បត្តិឱ្យទៅភាគីអ្នកដាក់ពាក្យសុំ .....................។

## ការពិនិត្យភស្តុតាង

១-**ភស្តុតាងជាឯកសាររបស់អ្នកដាក់ពាក្យសុំ**

-សំបុត្រអាពាហ៍ពិពាហ៍លេខ ..... ចុះថ្ងៃទី....... ខែ......... ឆ្នាំ......... ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ..............។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ............................ចុះថ្ងៃទី....... ខែ......... ឆ្នាំ......... របស់អ្នកដាក់ពាក្យសុំឈ្មោះ.................................។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ............................ចុះថ្ងៃទី....... ខែ......... ឆ្នាំ......... របស់ភាគីម្ខាងទៀតឈ្មោះ.................................។

-សំបុត្រកំណើតលេខ..... ចុះថ្ងៃទី........... ខែ........... ឆ្នាំ............ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន .................................. របស់ឈ្មោះ..........................។

-សៀវភៅគ្រួសារលេខ...................... ចុះថ្ងៃទី............ ខែ............ ឆ្នាំ................ ចេញដោយស្នងការនគរបាលរាជធានីភ្នំពេញ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ............................... ចុះថ្ងៃទី............. ខែ............ ឆ្នាំ .......... ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី....................។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ............................... ចុះថ្ងៃទី............. ខែ............ ឆ្នាំ .......... ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី....................។

## សំអាងហេតុ

១-ពាក្យសុំលែងលះដោយការព្រមព្រៀងចុះថ្ងៃទី .......... ខែ............ ឆ្នាំ.......... របស់អ្នកដាក់ពាក្យសុំត្រូវនឹងផ្នែកទី៤ ចំណុច៥ នៃតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ហើយយោងតាមមាត្រា ៣ នៃច្បាប់នេះ តុលាការត្រូវសម្រេចសេចក្ដីដោយដីកាសម្រេច។

៣.២ អចលនវត្ថុជាដីនិងផ្ទះ ដែលមានទំហំ ...... ម$^2$ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ............................... ចុះថ្ងៃទី............ ខែ........... ឆ្នាំ .......... ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី.................. មានទីតាំងស្ថិតនៅភូមិ........... ឃុំ............. ស្រុក........... ខេត្ត..........។

ភាគីម្ខាងទៀត............ ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុ ដូចមាននៅក្នុងសេចក្ដីសម្រេច ចំណុច ៣.១ ដល់ចំណុច ៣.២ ឱ្យទៅភាគីអ្នកដាក់ពាក្យសុំ..................។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

**ចៅក្រម**

**ហត្ថលេខានិងត្រា**..........................

---

| **បានឃើញ** | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| --- | --- |
| **ចៅក្រម** | ថ្ងៃ........... ខែ.......... ឆ្នាំ..... ... ស័ក ព.ស. ....... |
| | រាជធានីភ្នំពេញ ថ្ងៃទី ........ ខែ ........ ឆ្នាំ.......... |
| | **ក្រឡាបញ្ជី** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង...........

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូង...........**

-សំណុំរឿងរដ្ឋប្បវេណីលេខ ...........

ចុះថ្ងៃទី........ ខែ........ឆ្នាំ........

-សញ្ញាណរឿងក្តី : បណ្តឹងសុំលែងលះប្តី

-សាលក្រមរដ្ឋប្បវេណីលេខ : .........

ចុះថ្ងៃទី........ ខែ........ឆ្នាំ........

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី..... ខែ...... ឆ្នាំ..... ។

-បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី..... ខែ...... ឆ្នាំ..... ។

-បានប្រកាសសាលក្រម នៅថ្ងៃទី..... ខែ...... ឆ្នាំ..... ។

**ចៅក្រមជំនុំជម្រះ**

លោក ........................... **ចៅក្រម** សាលាដំបូង...........................

**ក្រឡាបញ្ជី**

លោក ........................... **ក្រឡាបញ្ជី** សាលាដំបូង.........................

-ដើមចោទឈ្មោះ ................ភេទ...... កើតនៅថ្ងៃទី...... ខែ........ ឆ្នាំ...... ជនជាតិខ្មែរ មុខរបរ .............. ទីលំនៅសព្វថ្ងៃនៅភូមិ........... សង្កាត់ ........... ក្រុង........... ខេត្ត...........។

-ចុងចម្លើយឈ្មោះ ................ភេទ...... កើតនៅថ្ងៃទី...... ខែ........ ឆ្នាំ...... ជនជាតិខ្មែរ មុខរបរ .............. ទីលំនៅសព្វថ្ងៃនៅភូមិ........... សង្កាត់ ........... ក្រុង........... ខេត្ត...........។

**អង្គហេតុ និងចំណុចវិវាទ**

I-**ការទាមទាររបស់ដើមចោទ**

**+ដើមចោទបានប្តឹងសុំទាមទារឱ្យតុលាការចេញសាលក្រមសម្រេច :**

**១**-សុំលែងលះពីចុងចម្លើយឈ្មោះ ........... ។

**២**-សុំមានអំណាចមេបាលើកូនប្រុសឈ្មោះ ........... ។

**៣**-សុំឱ្យចុងចម្លើយផ្តល់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព។

II-**ការអះអាងរបស់គូភាគី :**

**ក/-ការអះអាងរបស់ដើមចោទ**

ដើមចោទឈ្មោះ ...........បានធ្វើសេចក្តីថ្លែងការណ៍ថា :

**ខ/-ការអះអាងរបស់ចុងចម្លើយ**

ចុងចម្លើយឈ្មោះ ………… បានធ្វើសេចក្ដីថ្លែងការណ៍ថា :

**III -ចំណុចវិវាទ**

-………………………………………………………………………………………។

**<u>សំអាងហេតុ</u> :**

**តាមលទ្ធផលនៃការសាកសួរសាមីភាគី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា :**

១-………………………………………………………………………………………។

២-………………………………………………………………………………………។

៣-………………………………………………………………………………………។

៤-………………………………………………………………………………………។

៥-………………………………………………………………………………………។

៦-………………………………………………………………………………………។

៧-………………………………………………………………………………………។

**<u>សេចក្ដីសម្រេចបញ្ចប់</u>**

I-ឱ្យដើមចោទឈ្មោះ ……………… លែងលះគ្នាពីចុងចម្លើយឈ្មោះ ………….ចាប់ពីពេលនេះតទៅ។

II-ឱ្យដើមចោទឈ្មោះ ……………… ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ …………………… ភេទ……កើតនៅថ្ងៃទី……ខែ…… ឆ្នាំ……។

III-ឱ្យចុងចម្លើយឈ្មោះ ………………ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន តាមលទ្ធភាព។

IV-ឱ្យចុងចម្លើយឈ្មោះ …………………… ទទួលបន្ទុកលើប្រាក់ប្រដាប់ក្ដី តាមមាត្រា **៦៤** នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា ……**

---

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

………… ថ្ងៃទី…… ខែ…… ឆ្នាំ……

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**